# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍

# បូកសរុបលទ្ធផលការងារ ១០ឆ្នាំ ២០១២-២០២១

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ និងនីតិកាលទី៦នៃរដ្ឋសភា ដែលដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងដំណាក់កាលទី៤ ដោយបានកំណត់អភិបាលកិច្ចល្អ ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ជាសសរទ្រូង ដើម្បីទ្រទ្រង់កំណើន និងកាត់បន្ថយភាពក្រីក្រ។ ក្នុងបរិការណ៍នៃកំណែទម្រង់ **រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ខ្ពស់លើការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យ**។ ក្នុងចំណោមកិច្ចការកែទម្រង់ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលនោះ មានកិច្ចការ**កែទម្រង់បីបូកមួយ** ដែលជាសសរគ្រឹះសំខាន់នៃកិច្ចការកែទម្រង់របស់រាជរដ្ឋាភិបាល ដែលរួមមាន៖ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអាទិភាពចំបង ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ហើយដែលកិច្ចការកែទម្រង់ទាំង៣នេះ មានភាពប្រទាក់ក្រឡាគ្នា និងជួយយិតយោងគ្នាទៅវិញទៅមកដែលជាគ្រឹះសំខាន់ក្នុងកិច្ចការកែទម្រង់របស់រាជរដ្ឋាភិបាល។ ចាប់ផ្ដើមពីនីតិកាលទី៥មក ដើម្បីឱ្យកិច្ចការកែទម្រង់របស់រាជរដ្ឋាភិបាលកាន់តែពេញលេញ ហើយមានប្រសិទ្ធភាព និងជួយដល់ការអភិវឌ្ឍកម្ពុជាឱ្យបានកាន់តែខ្លាំងក្លាថែមទៀត រាជរដ្ឋាភិបាលបានកំណត់យកកិច្ចការកែទម្រង់មួយទៀតដែលមានសារសំខាន់ខ្លាំងគឺកិច្ចការកែទម្រង់ច្បាប់ និងតុលាការ ដែលជាកិច្ចការកែទម្រង់បំពេញបន្ថែមទៅលើកិច្ចការកែទម្រង់៣ខាងលើបន្ថែម ដែលជាមូលដ្ឋានគ្រឹះនៅក្នុងកិច្ចការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល។

ជាសក្ខីភាព រាជរដ្ឋាភិបាលកម្ពុជារក្សាការពារបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយដែលជាបុព្វបទ ឬជាបុរេលក្ខខណ្ឌនាំឱ្យកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យយ៉ាងឆាប់រហ័សពាសពេញប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាទទួលបាននូវឯកទត្តកម្មខាងកំណើនសេដ្ឋកិច្ចក្នុងអត្រាប្រមាណក្នុងរង្វង់៧% ក្នុងមួយឆ្នាំក្នុងរយៈពេលពីរទសវត្សមុនពេលដែលជំងឺកូវីដ-១៩ផ្ទុះឡើង ដែលនាំមកនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ឥតឈប់ឈរ ហើយបានឆ្លងកាត់ដោយជោគជ័យពីចំណាត់ថ្នាក់ជាប្រទេសមានចំណូលទាប ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនាពេលកន្លងទៅនេះ។ រាជរដ្ឋាភិបាលកម្ពុជាមានការប្ដេជ្ញាចិត្តយ៉ាងមោះមុតក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការ ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ឈានទៅសម្រេចចក្ខុវិស័យជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ឆ្នាំ២០២០ គឺជាឆ្នាំដ៏លំបាកបំផុតមួយក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា ដោយសារផលប៉ះពាល់អវិជ្ជមាន បញ្ហាប្រឈម និងហានិភ័យជាច្រើនដែលបណ្ដាមកពីជំងឺកូវីដ-១៩។ ជំងឺនេះបង្កជាវិបត្តិសុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ ប៉ះពាល់យ៉ាងខ្លាំងលើវិស័យសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន។ រយៈពេលជិតពីរឆ្នាំនេះ កម្ពុជាបានឆ្លើយតបទៅនឹងវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពស្វាហាប់ជាមួយនឹងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយតាមរយៈកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រគន្លឹះ គួបផ្សំជាមួយនឹងវិធានការទប់ស្កាត់ និងរុករកការឆ្លងឱ្យបានទាន់ពេលវេលា វិធានការពង្រឹងសមត្ថភាពព្យាបាល និងប្រើថ្នាំព្យាបាលប្រកបដោយសក្ដិសិទ្ធិ វិធានការរដ្ឋបាល សុខាភិបាល និងអប់រំ ព្រមទាំងអនុវត្តនូវកញ្ចប់គោលនយោបាយអន្តរាគមន៍សង្គម និងសេដ្ឋកិច្ច

ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងធុរកិច្ចនៅក្នុងគ្រប់វិស័យ។ ការសម្រេចចិត្តត្រឹមត្រូវ ទាន់ពេលវេលាស្វះស្វែងរកទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ធ្វើឱ្យកម្ពុជាសម្រេចជោគជ័យក្នុងការបើកយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាជន។ ហេតុនេះបានធ្វើឱ្យកម្ពុជាសម្រេចបាននូវការចាក់វ៉ាក់សាំងជូនប្រជាជន ក្នុងកម្រិតខ្ពស់ជាងគេនៅក្នុងតំបន់ និងពិភពលោក។ បានធ្វើឱ្យកម្ពុជាអាចសម្រេចបាននូវភាពស៊ាំសហគមន៍នៅត្រឹមដំណាច់ខែតុលា ឆ្នាំ២០២១ កន្លងទៅនេះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការការពារអាយុជីវិតប្រជាជន និងសម្រាប់ការបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញឡើងវិញនៅក្នុងបរិបទនៃការរស់នៅជាមួយនឹងកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។

អាជ្ញាធរសវនកម្មជាតិ មានតួនាទីជាសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល និងអនុលោមតាមបេសកកម្ម តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដែលមានចែងក្នុងច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តតាមកម្មវិធីនយោបាយ គោលនយោបាយ យុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដែលមានជាអាទិ៍៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ កម្មវិធីកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យ ពិសេសកិច្ចការកែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ល។ ក្នុងន័យនេះ អាជ្ញាធរសវនកម្មជាតិផ្តោតការយកចិត្តទុកដាក់លើការធ្វើសវនកម្មដែលរួមមានជាអាទិ៍ ៖

- **ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ** ផ្តោតជាពិសេសលើការគ្រប់គ្រងហិរញ្ញវត្ថុ ធានាប្រសិទ្ធភាពនៃការប្រមូលចំណូល ការគ្រប់គ្រងចំណាយ ធានាលើប្រសិទ្ធភាពតម្លៃនៃលុយ បានន័យថា ម៉្យាងគឺការត្រួតពិនិត្យទៅលើអនុលោមភាពក្នុងការគោរពតាមវិធាននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយម៉្យាងទៀតគឺត្រួតពិនិត្យវាយតម្លៃទៅលើប្រសិទ្ធភាពតម្លៃនៃលុយ បានន័យថា ចំណាយប៉ុន្មានត្រូវធានាបានទំនិញ ឬសេវាមកវិញឱ្យត្រឹមត្រូវ ឬស្មើគ្នាជាមួយតម្លៃនៃលុយដែលបានចំណាយឬអត់។

- **ការធ្វើសវនកម្មអនុលោមភាព** គឺផ្តោតទៅលើការធ្វើសវនកម្មអំពីការអនុវត្តច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាននានាដោយកំណត់អំពីក្របខ័ណ្ឌ និងនីតិវិធីនៃប្រតិបត្តិការទាំងឡាយ រួមទាំងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងចំណូលចំណាយរបស់ជាតិផងដែរ។ មានន័យថា ជាការធ្វើសវនកម្ម (ត្រួតពិនិត្យ) អនុលោមភាពរបស់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ធៀបជាមួយនឹងការកំណត់នៃបទប្បញ្ញត្តិច្បាប់ លិខិតបទដ្ឋាន គោលការណ៍ វិធានការ នីតិវិធីនានាដែលដាក់ចេញដោយរាជរដ្ឋាភិបាល ព្រមទាំងក្រសួង ស្ថាប័នរបស់ខ្លួនផងដែរ។

- **ការធ្វើសវនកម្មទៅលើប្រព័ន្ធការងាររបស់ក្រសួង ស្ថាប័នរដ្ឋ** បានន័យថា ក្រសួង ស្ថាប័នរដ្ឋបានរៀបចំនូវយន្តការ ដើម្បីអនុវត្តការងារ រីឯអាជ្ញាធរសវនកម្មជាតិមានមុខងារត្រួតពិនិត្យលើប្រព័ន្ធ យន្តការដែលបានដាក់ចេញមានប្រសិទ្ធភាពកម្រិតណា បម្រើបានគោលដៅដែលរាជរដ្ឋាភិបាលបានដាក់ចេញ ឬក្រសួង ស្ថាប័នបានដាក់ចេញ ឆ្លើយតបទៅនឹងគោលបំណង គោលនយោបាយរបស់រាជរដ្ឋាភិបាលបានកម្រិតណា មានប្រសិទ្ធភាពគ្រប់គ្រាន់ឬយ៉ាងណា ព្រមទាំងផ្តល់អនុសាសន៍កែលម្អផងដែរ។

- **ការធ្វើសវនកម្មខាងផ្នែកសមិទ្ធកម្ម** បានន័យថា ពេលអនុវត្តការងារបានហើយ មានប្រសិទ្ធភាពហើយ ការអនុវត្តចំណាយខាងផ្នែកហិរញ្ញវត្ថុត្រឹមត្រូវហើយ ប៉ុន្តែនៅសេសសល់ប្រសិទ្ធភាពមួយទៀតគឺចង់ដឹងថា លទ្ធផល

សម្រេចបាននោះបម្រើឱ្យគោលបំណង គោលនយោបាយរបស់រដ្ឋាភិបាលបានពេញលេញគ្រប់គ្រាន់កម្រិតណា និងបម្រើផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋត្រឹមត្រូវពេញលេញតាមគោលបំណង គោលនយោបាយ ដែលបានដាក់ចេញដែរឬទេ។

ក្រៅពីនេះ នៅមានប្រភេទសវនកម្មផ្សេងៗទៀត ដែលអាជ្ញាធរសវនកម្មជាតិបានខិតខំធ្វើ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តកិច្ចការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ពិសេសកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ឆ្លើយតបនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ច សង្គមក្រោយវិបត្តិជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងឆ្លើយតបនឹងបេសកកម្ម តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួន អាជ្ញាធរសវនកម្មជាតិបានបន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ (២០១៧-២០២១) និងផែនការសកម្មភាពប្រចាំឆ្នាំនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ៥ឆ្នាំ (២០២២-២០២៦) ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ច សង្គមរបស់រាជរដ្ឋាភិបាល រួមចំណែកធ្វើឱ្យកិច្ចការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាលទទួលបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងមួយទសវត្សរ៍២០១២-២០២១ កន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបន្តពង្រឹងនូវលទ្ធផល១០ឆ្នាំ ដែលអាណត្តិ២០០១-២០១១ សម្រេចបាន។ ភារកិច្ចចំបងដំបូងគេគឺការអភិវឌ្ឍស្ថាប័ន ទាំងផ្នែករឹង និងផ្នែកទន់ ព្រមទាំងកសាងសមត្ថភាពធនធានមនុស្ស ពិសេសមន្ត្រីសវនកម្ម ដែលផ្តោតការយកចិត្តទុកដាក់លើការធ្វើបច្ចុប្បន្នភាពនូវគោលការណ៍ណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ គោលការណ៍ណែនាំស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីកែលម្អឱ្យស្របតាមការវិវឌ្ឍន៍ និងតម្រូវការនៃការងារសវនកម្មនាពេលបច្ចុប្បន្ន និងតាមស្ថានភាពជាក់ស្តែង។ ដើម្បីបំពេញតម្រូវការនៃការងារសវនកម្ម អាជ្ញាធរសវនកម្មជាតិបានបង្កើតថែមប្រភេទសវនកម្មថ្មីមួយទៀតគឺ សវនកម្មលើកិច្ចប្រតិបត្តិការដែលពីមុនមិនធ្លាប់មាន និងបានរៀបចំឱ្យមាននូវគោលការណ៍ណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ គោលការណ៍ណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសម្រាប់គម្រោងហិរញ្ញប្បទានបរទេស គោលការណ៍ណែនាំស្តីពីសវនកម្មនៅធនាគារកណ្តាល នីតិវិធីសវនកម្មលើកិច្ចប្រតិបត្តិការសម្រាប់គម្រោងហិរញ្ញប្បទានបរទេស គោលការណ៍ណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសម្រាប់ក្រុង ស្រុក ខណ្ឌ ចងក្រងឯកសារពាក់ព័ន្ធការងារសវនកម្ម បង្កើតឱ្យមានក្រុមការងារត្រួតពិនិត្យការធានាគុណភាពសវនកម្ម ព្រមទាំងបានរៀបចំគោលការណ៍ស្តីពីការធានាគុណភាពសវនកម្ម ។ល។ ដើម្បីធានារក្សាទុកដាក់ឯកសារឱ្យបានត្រឹមត្រូវគង់វង្ស អាជ្ញាធរសវនកម្មជាតិបានបង្កើតឱ្យមានបណ្ណាល័យ និងមជ្ឈមណ្ឌលគ្រប់គ្រងឯកសារមួយរបស់ខ្លួន មានការទទួលខុសត្រូវដោយចាត់ទុកថា ឯកសារទាំងនោះ ពិសេសឯកសារសវនកម្មជាឯកសាររបស់ជាតិ។

ក្នុងអាណត្តិ១០ឆ្នាំ (២០១២-២០២១) កន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបានចងក្រង និងបោះផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមឆ្នាំនីមួយៗទៀងទាត់ទាន់ពេលវេលា និងមិនដែលយឺតយូរ ឬអាក់ខានឡើយ។ ជាមួយគ្នានេះដែរតាមច្បាប់តម្រូវ អាជ្ញាធរសវនកម្មជាតិបានធ្វើរបាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងតាមឆ្នាំនីមួយៗ

បានត្រឹមត្រូវ និងទាន់ពេលវេលាមិនដែលខកខាន ដោយមានកិច្ចសហការល្អ និងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងអាណត្តិនេះផងដែរ អាជ្ញាធរសវនកម្មជាតិបានទទួលចុះធ្វើសវនកម្មតាមសំណើពីក្រសួងស្ថាប័ន ដែលពីមុនពុំធ្លាប់ដែលបានទទួលធ្វើ។ កិច្ចការនេះបានធ្វើឱ្យអាជ្ញាធរសវនកម្មជាតិ ពិសេសមន្ត្រីសវនកម្មកាន់តែមានបទពិសោធន៍ និងមានការទទួលខុសត្រូវមួយកម្រិតថែមទៀត ពិសេសលទ្ធផលដែលរកឃើញ និងផ្តល់អនុសាសន៍ត្រូវតែមានភស្តុតាងឯកសារគាំទ្រត្រឹមត្រូវ ជឿជាក់បាន ហើយធានាពីភាពត្រឹមត្រូវតាមច្បាប់។

ដើរទន្ទឹមគ្នា និងកិច្ចការត្រូវធ្វើ បាននិងកំពុងធ្វើ អាជ្ញាធរសវនកម្មជាតិនៅបានធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មកំពូលអន្តរជាតិផងដែរ ដែលមានជាអាទិ៍ ធ្វើជាសមាជិក និងជាស្ថានិកនៃស្ថាប័នសវនកម្មកំពូលនៃបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ហៅកាត់ថា "ASEANSAI"។ អាជ្ញាធរសវនកម្មជាតិមានកិត្តិយសដែលត្រូវបានមហាសន្និបាតអនុម័តតែងតាំងជាប្រធាន ASEANSAI សម្រាប់អាណត្តិ២ឆ្នាំ (២០១៦-២០១៧)។ បើគិតតាមការប្តូរវេនធ្វើប្រធានតាមលំដាប់អក្ខរក្រម សមាជិក ASEANSAI នីមួយៗ ត្រូវរង់ចាំពេលវេលា២០ឆ្នាំ ទើបបានធ្វើប្រធាន ASEANSAI ម្តងទៀត។ តាមរយៈការធ្វើប្រធាន ASEANSAI នេះ បានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាអាជ្ញាធរសវនកម្មជាតិលើកកម្ពស់បាននូវកិត្យានុភាពលើឆាកអន្តរជាតិ ចូលរួមដើរតួនាទីយ៉ាងសកម្ម ដោយស្មើសិទ្ធិ និងស្មើភាពក្នុងកិច្ចការតំបន់ និងនៅលើឆាកអន្តរជាតិ។ ព្រមជាមួយគ្នានេះផងដែរ អាជ្ញាធរសវនកម្មជាតិនៅមានទំនាក់ទំនងជាមួយស្ថាប័នសវនកម្មកំពូលនៅតំបន់អាស៊ី នៅអឺរ៉ុប និងកិច្ចសហប្រតិបត្តិការទ្វេភាគី ត្រីភាគី ជាមួយស្ថាប័នសវនកម្មកំពូលនានា ព្រមទាំងប្រទេសជាដៃគូផ្សេងទៀតផងដែរ។

បណ្តាចំណុចការងារដែលបានលើកឡើងជម្រាបជូនខាងលើនេះគ្រាន់តែរំលេចជូនជ្រាបខ្លះៗប៉ុណ្ណោះ។ រីឯការងារ និងលទ្ធផលដែលខិតខំសម្រេចបានក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ មានរៀបរាប់នៅក្នុងរបាយការណ៍នេះស្រាប់។

ជាសក្ខីភាព លទ្ធផលនៃរបាយការណ៍បូកសរុបការងារ១០ឆ្នាំ បានបង្ហាញពីការខិតខំប្រឹងប្រែង និងការប្តេជ្ញាយ៉ាងមុតមាំ ទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ ដែលបានតស៊ូប្រឹងប្រែបំពេញការងារមិនគិតពីការលំបាកឧបសគ្គនានា មិនគិតពេលវេលា ទីជិត ឬទីឆ្ងាយ នៅគ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចភារកិច្ចរបស់ខ្លួន និងរបស់អាជ្ញាធរសវនកម្មជាតិ។ ក្នុងនាមថ្នាក់ដឹកនាំ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរ និងអរគុណនូវរាល់ការខិតខំប្រឹងប្រែង និងការលះបង់ទាំងអស់កន្លងមក។

សមិទ្ធផលការងាររបស់អាជ្ញាធរសវនកម្មជាតិ១០ឆ្នាំ (២០១២-២០២១) កន្លងទៅនេះ ត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍បូកសរុបការងារនេះ ដែលសមិទ្ធផលនេះរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចដំណើរការអនុវត្តនូវគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ជាពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ របាយការណ៍នេះចែកចេញជាបួនផ្នែករួមមាន ស្ថានភាពទូទៅ លទ្ធផលការងារ១០ឆ្នាំ ទិសដៅការងារបន្ត និងសេចក្តីសន្និដ្ឋាន។

ជាមួយនេះផងដែរ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភា ព្រឹទ្ធសភា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលបានជួយលើកទឹកចិត្ត បានជួយគាំទ្រទាំងស្មារតី និងសម្ភារដល់អាជ្ញាធរសវនកម្មជាតិ តាំងពីចាប់បដិសន្ធិរហូតមកដល់បច្ចុប្បន្ននេះ។ ខ្ញុំសូមគោរពថ្លែងអំណរគុណជាពិសេស និងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ដែលតែងតែផ្តល់អនុសាសន៍ល្អៗ និងផ្តល់គោលការណ៍នានាដែលមានតម្លៃឥតគណនាសម្រាប់ធ្វើជាត្រីវិស័យក្នុងការដឹកនាំអាជ្ញាធរសវនកម្មជាតិ ព្រមទាំងជួយឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងក្នុងកិច្ចដំណើរការរបស់អាជ្ញាធរសវនកម្មជាតិ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពរងសវនកម្ម ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធដោយស្មោះ ក្នុងដំណើរការចុះធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។ ជាមួយនេះផងដែរ សូមអង្គភាពរងសវនកម្មមេត្តាយោគយល់ អធ្យាស្រ័យ ក្រែងការប្រព្រឹត្តណាមួយមិនសមរម្យពីមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរដល់ដៃគូអភិវឌ្ឍន៍ និងដល់ការគាំទ្រទាំងអស់ពីមជ្ឈដ្ឋាននានាចំពោះអាជ្ញាធរសវនកម្មជាតិ។ បើគ្មានការគាំទ្រ និងកិច្ចសហការយ៉ាងជិតស្និទ្ធទាំងអស់នេះទេ អាជ្ញាធរសវនកម្មជាតិពុំអាចសម្រេចបាននូវលទ្ធផលទាំងអស់នេះបានឡើយ។

ជាថ្មីម្តងទៀត ខ្ញុំសូមគោរពថ្លែងអំណរគុណ និងដឹងគុណនូវរាល់ការគាំទ្រ និងកិច្ចសហការកន្លងមក។ ខ្ញុំសង្ឃឹមថា ពេលខាងមុខ នៅតែបន្តគាំទ្រ និងផ្តល់កិច្ចសហការជិតស្និទ្ធជាមួយអាជ្ញាធរសវនកម្មជាតិ៕

ថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា

ទំព័រ

**សេចក្តីសង្ខេប** ........ ១
**សេចក្តីផ្តើម** ........ ៣
**ផ្នែកទី១ : ស្ថានភាពទូទៅ** ........ ៤
I- **ប្រវត្តិសង្ខេប** ........ ៤
១. ប្រវត្តិកកើត ........ ៤
២. ទីតាំង ........ ៤
៣. គោលបំណង និងទស្សនវិស័យការងារ ........ ៤
៣.១. គោលបំណង ........ ៤
៣.២. ទស្សនវិស័យការងារ ........ ៤
៣.៣. ការរួមចំណែកជួយអង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ........ ៥
II- **ប្រព័ន្ធគ្រប់គ្រង** ........ ៥
១. តួនាទី និងភារកិច្ច ........ ៥
១.១. ការតែងតាំង និងតួនាទីរបស់ថ្នាក់ដឹកនាំ ........ ៥
១.២. សិទ្ធិអំណាច និងវិសាលភាព ........ ៦
២. រចនាសម្ព័ន្ធគ្រប់គ្រង ........ ៦
**ផ្នែកទី២ : លទ្ធផលការងារ១០ឆ្នាំ (២០១២-២០២១)** ........ ១២
I- **លទ្ធផលការងារជួយគាំទ្រដល់ការងារសវនកម្ម** ........ ១២
១. ការរៀបចំឯកសារគតិយុត្ត ........ ១២
១.១. ការចេញនូវសេចក្តីសម្រេច ........ ១២
១.២. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១២-២០១៦) ........ ១២
១.៣. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) ........ ១២
១.៤. សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ........ ១៣
១.៥. សៀវភៅណែនាំស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ........ ១៣
១.៦. សៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ ........ ១៤
១.៧. សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសម្រាប់គម្រោងហិរញ្ញប្បទានបរទេស ........ ១៤
១.៨. នីតិវិធីសវនកម្មលើកិច្ចប្រតិបត្តិការសម្រាប់គម្រោងហិរញ្ញប្បទានបរទេស ........ ១៤
១.៩. សៀវភៅណែនាំស្តីពីសវនកម្មនៅធនាគារកណ្តាល ........ ១៥

១.១០. សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសម្រាប់ក្រុង ស្រុក ខណ្ឌ ........ ១៥
១.១១. កម្មវិធីសវនកម្មលើការប្រមូលចំណូលពន្ធដារ........ ១៥
១.១២. កម្មវិធីសវនកម្មលើការប្រមូលចំណូលពន្ធគយ........ ១៦
២. ការចងក្រងឯកសារពាក់ព័ន្ធការងារសវនកម្ម ........ ១៦
៣. ការងារព័តមានវិទ្យា ........ ១៧
៤. ការបោះផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ........ ១៧
៥. បណ្ណាល័យ និងមជ្ឈមណ្ឌលគ្រប់គ្រងឯកសារ ........ ១៨
៦. ការងារបណ្តុះបណ្តាល និងសិក្ខាសាលា ........ ២០
៦.១. វគ្គបណ្តុះបណ្តាល........ ២០
៦.១.១.វគ្គបណ្តុះបណ្តាលក្នុងប្រទេស ........ ២០
៦.១.២ .វគ្គបណ្តុះបណ្តាលក្រៅប្រទេស........ ២៥
៦.២. ការងារសិក្ខាសាលា........ ២៧
៦.២.១ .ការងារសិក្ខាសាលា និងកិច្ចប្រជុំក្នុងប្រទេស ........ ២៧
៦.២.២. សិក្ខាសាលា កិច្ចប្រជុំ និងទស្សនកិច្ចសិក្សានៅក្រៅប្រទេស........ ៣០
៧. ការងារសហប្រតិបត្តិការ........ ៣៧
៧.១. កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ ........ ៣៧
៧.១.១.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្បញ្ញត្តិ ........ ៣៧
៧.១.២.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្រតិបត្តិ........ ៣៨
៧.១.៣ ការរួមចំណែកក្នុងកិច្ចការសង្គម និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩........ ៤០
៧.២. កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មកំពូលអន្តរជាតិ ........ ៤០
៧.២.១ ការបំពេញមុខងារជាប្រធានASEANSAI........ ៤០
៧.២.២.សកម្មភាពទំនាក់ទំនងអន្តរជាតិ........ ៤៥
៧.២.៣.កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍........ ៧៧
៨. ការងាររដ្ឋបាលទូទៅ........ ៨៥
៨.១. ការងាររដ្ឋបាល........ ៨៥
៨.១.១.ស្ថិតិមន្ត្រីរាជការ........ ៨៥
៨.១.២.កម្រិតវប្បធម៌ ........ ៨៦
៨.១.៣.ការលើកទឹកចិត្ត ........ ៨៦
៨.១.៤.ការពង្រឹងសមត្ថភាពស្ថាប័ន........ ៨៧

៨.២. ការគ្រប់គ្រងចំណូល ចំណាយថវិកា ........ ៨៨
៨.៣. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ........ ៨៩
៨.៤. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ៨៩
៩. ការធានាគុណភាពសវនកម្ម ........ ៩១
**II- លទ្ធផលការងារសវនកម្ម** ........ ៩១
១-លទ្ធផលសវនកម្មតាមសំណើរបស់ក្រសួង ស្ថាប័ន ........ ៩១
២-សកម្មភាពចុះធ្វើសវនកម្ម ឆ្នាំ២០១២-២០២១ ........ ៩៣
**III-បញ្ហាប្រឈម** ........ ១១៦
**ផ្នែកទី៣** : **ទិសដៅបន្ត** ........ ១១៧
**ផ្នែកទី៤** : **សេចក្តីសន្និដ្ឋាន** ........ ១១៩

# សេចក្ដីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈមួយដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារអនុវត្តមុខងារជាសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងជួយរាជរដ្ឋាភិបាលឱ្យសម្រេចបាននូវការអនុវត្តក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ លើការគ្រប់គ្រងធនធានសាធារណៈដោយម៉ត់ចត់ និងជួយលើការទទួលខុសត្រូវផ្នែកសាធារណៈតាមរយៈការធ្វើសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត។ តាមរយៈការបំពេញមុខងារនេះ អាជ្ញាធរសវនកម្មជាតិបានចុះធ្វើសវនកម្ម និងផលិតចេញនូវរបាយការណ៍លទ្ធផលសវនកម្មក្នុងរយៈពេល១០ឆ្នាំ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១ ប្រមាណជា ៦៥៤ របាយការណ៍ និងតាមរយៈរបាយការណ៍ទាំងនេះបានជួយជំរុញក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មនានាឱ្យកែលម្អ និងពង្រឹងកិច្ចប្រតិបត្តិការតាមជំនាញរៀងៗខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ។

តាមរយៈលទ្ធផលសម្រេចបានក្នុងអំឡុងពេល១០ឆ្នាំកន្លងមកនេះ និងឈរលើស្មារតីយកចិត្តទុកដាក់អនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាបានខិតខំអនុវត្តកែលម្អនូវចំណុចខ្វះខាតដែលអាជ្ញាធរសវនកម្មជាតិបានកត់សម្គាល់ និងផ្ដល់អនុសាសន៍។ ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចប្រឹងប្រែងយូរឆ្នាំរបស់រាជរដ្ឋាភិបាលលើការងារកែទម្រង់ ជាពិសេសការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងមានការរួមចំណែកពីសកម្មភាពសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដែលជាបច្ច័យនាំឱ្យមានការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែប្រសើរ។

អាជ្ញាធរសវនកម្មជាតិបានខិតខំកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័នដើម្បីធ្វើឱ្យប្រសើរឡើងនូវការងារសវនកម្មប្រកបដោយគុណភាព ជឿទុកចិត្តបាន និងទាន់ពេលវេលា សម្រាប់ជាមូលដ្ឋានជួយដល់រដ្ឋសភា និងព្រឹទ្ធសភា ក្នុងការអនុម័តច្បាប់ស្ដីពីការគ្រប់គ្រងថវិកាទូទៅ និងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំ។ ដើម្បីជំនួយក្នុងការបំពេញមុខងារចម្បង អាជ្ញាធរសវនកម្មជាតិបានកសាងនូវឯកសារគតិយុត្តជាច្រើន ដោយមានការជួយគាំទ្រ និងកិច្ចសហការពីសំណាក់ដៃគូអភិវឌ្ឍន៍ ទាំងក្នុងតំបន់ និងអន្តរជាតិ។ ប្រការសំខាន់គឺអាជ្ញាធរសវនកម្មជាតិបានបង្កើត និងដាក់ឱ្យអនុវត្តនូវស្តង់ដារផ្ទាល់របស់ខ្លួនសមស្របតាមច្បាប់ជាធរមាន និងសមស្របតាមស្តង់ដារអន្តរជាតិ។ ជាមួយគ្នានេះ អាជ្ញាធរសវនកម្មជាតិដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ សម្រាប់ជាទិសដៅកសាងសមត្ថភាពស្ថាប័ន និងអនុវត្តមុខងារជាសវនករផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកជួយឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍។ ជាមួយនឹងការអនុវត្តនេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំ និងបង្កើតនូវគោលការណ៍ណែនាំសវនកម្មពិសេសសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្មលើកិច្ចប្រតិបត្តិការ។

ក្រៅពីនេះ ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងលើកកម្ពស់ការយល់ដឹងបន្ថែមស្ដីពីសវនកម្ម ស្តង់ដារសវនកម្ម នីតិវិធីសវនកម្ម និងជំនាញពាក់ព័ន្ធនានា អាជ្ញាធរសវនកម្មជាតិបានរៀបចំវគ្គបណ្ដុះបណ្ដាលជូនមន្ត្រីសវនកម្ម ចាប់ពីឆ្នាំ២០១២-២០២១ បានចំនួន ៨៣ វគ្គ/លើក និងបញ្ជូនមន្ត្រីទៅបណ្ដុះបណ្ដាល

នៅក្រៅប្រទេស ចំនួន ៣២ វគ្គ/លើក។ ដោយឡែកអាជ្ញាធរសវនកម្មជាតិ បានចាត់បញ្ជូនមន្ត្រីសវនកម្មជាច្រើនឱ្យទៅចូលរួមសិក្ខាសាលា កិច្ចប្រជុំ និងទស្សនកិច្ចសិក្សានៅក្រៅប្រទេស ចំនួន ១៣០ វគ្គ/លើក។

ជាមួយគ្នានេះ ក្នុងរយៈពេល១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិបានបើកសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈ និងសិក្ខាសាលាពាក់ព័ន្ធការងារសវនកម្មផ្សេងៗទៀត ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែច្បាស់ពីការងារសវនកម្មសាធារណៈ។ ការងារសិក្ខាសាលាផ្សព្វផ្សាយនេះត្រូវបានរៀបចំសម្រាប់បណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងបណ្តាអង្គភាពផ្សេងៗ។ លើសពីនេះ អាជ្ញាធរសវនកម្មជាតិបានចូលរួមប្រជុំ និងសិក្ខាសាលានានាជាមួយតំណាងរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ទាក់ទងនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងវិស័យផ្សេងៗទៀត។

ជាចុងក្រោយ អាជ្ញាធរសវនកម្មជាតិបានធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មកំពូលអន្តរជាតិ និងដៃគូអភិវឌ្ឍន៍រួមមាន៖ អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល(ASOSAI) ស្ថាប័នសវនកម្មកំពូលនៃបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ (ASEANSAI) ស្ថាប័នសវនម្មកំពូលនៃបណ្តាប្រទេសនានា និងដៃគូអភិវឌ្ឍន៍ GIZ, ADB និង EU/Sida ។

# សេចក្ដីផ្ដើម

សមិទ្ធផលការងាររបស់អាជ្ញាធរសវនកម្មជាតិ១០ឆ្នាំ (២០១២-២០២១) កន្លងទៅនេះ ត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍បូកសរុបការងារនេះ ដែលសមិទ្ធផលទាំងនេះរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចដំណើរការអនុវត្តនូវគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល។

របាយការណ៍នេះ ចែកចេញជាបួនផ្នែក គឺផ្នែកទី១: ស្ថានភាពទូទៅ ផ្នែកទី២: លទ្ធផលការងារ១០ឆ្នាំ ផ្នែកទី៣: ទិសដៅការងារបន្ត និងផ្នែកទី៤: សេចក្ដីសន្និដ្ឋាន។

ក្រោយពីត្រូវបានបង្កើតចាប់តាំងពីឆ្នាំ២០០១មក រហូតមកដល់បច្ចុប្បន្ន អាជ្ញាធរសវនកម្មជាតិបានជំនះគ្រប់ឧបសគ្គដើម្បីកសាងស្ថាប័ន ក៏ដូចជាកសាងសមត្ថភាពជំនាញរបស់មន្ត្រីអាជ្ញាធរសវនកម្មជាតិ ដើម្បីសម្រេចបានលទ្ធផលការងារជាផ្លែផ្កាដូចសព្វថ្ងៃនេះ។ អាជ្ញាធរសវនកម្មជាតិមានមុខងារជាសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងជួយរាជរដ្ឋាភិបាលឱ្យសម្រេចបាននូវការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ លើការគ្រប់គ្រងធនធានសាធារណៈដោយម៉ត់ចត់ និងជួយលើការទទួលខុសត្រូវផ្នែកសាធារណៈតាមរយៈការធ្វើសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត។ តាមរយៈការបំពេញមុខងារនេះ អាជ្ញាធរសវនកម្មជាតិបានចុះធ្វើសវនកម្ម និងផលិតចេញនូវរបាយការណ៍លទ្ធផលសវនកម្មជាច្រើន និងតាមរយៈរបាយការណ៍ទាំងនេះបានជួយជំរុញក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មនានាឱ្យកែលម្អ និងពង្រឹងកិច្ចប្រតិបត្តិការតាមជំនាញរៀងៗខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ។

ដើម្បីជំនួយក្នុងការបំពេញមុខងារចម្បងរបស់ខ្លួន អាជ្ញាធរសវនកម្មជាតិបានកសាងនូវឯកសារគតិយុត្តជាច្រើន ដោយមានការជួយគាំទ្រ និងកិច្ចសហការពីសំណាក់ដៃគូអភិវឌ្ឍន៍ ទាំងក្នុងតំបន់ និងអន្តរជាតិ ប្រការសំខាន់គឺអាជ្ញាធរសវនកម្មជាតិបង្កើតស្តង់ដារផ្ទាល់របស់ខ្លួនសមស្របតាមច្បាប់ជាធរមាន និងសមស្របតាមស្តង់ដារអន្តរជាតិ។ ជាមួយគ្នានេះ អាជ្ញាធរសវនកម្មជាតិដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១២-២០១៦) និង (២០១៧-២០២១) សម្រាប់ជាទិសដៅកសាងសមត្ថភាពស្ថាប័ន និងអនុវត្តមុខងារជាសវនករផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកជួយឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍។

របាយការណ៍បូកសរុបការងាររយៈពេល១០ឆ្នាំនេះ ត្រូវបានបង្កើតឡើងទុកជាជំនួយស្មារតី ដល់មន្ត្រីរបស់អាជ្ញាធរសវនកម្មជាតិជំនាន់ក្រោយៗ ក៏ដូចជាក្រសួង ស្ថាប័ន និងអង្គភាពរងសវនកម្មទាំងឡាយណាសិក្សាស្វែងយល់ និងដកស្រង់យកបទពិសោធន៍ចំណុចល្អៗនៃរបាយការណ៍នេះមកប្រើប្រាស់ទៅតាមកាលៈទេសៈ និងពេលវេលាចាំបាច់ក្នុងដំណើរវិវត្តន៍ជាក់ស្តែង ក្នុងក្របខណ្ឌកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ។

# ផ្នែកទី ១
# ស្ថានភាពទូទៅ

 រហូតមកដល់បច្ចុប្បន្ន អាជ្ញាធរសវនកម្មជាតិត្រូវបានបង្កើតឡើងបាន២០ឆ្នាំ (២០០១-២០២១) ហើយស្ថាប័ននេះ ជាស្ថាប័នសវនកម្មកំពូលដែលពុំធ្លាប់មានពីជំនាន់មុនៗ។ ការជំរុញឱ្យកើតជាស្ថាប័ននេះឡើង ដើម្បីរួមចំណែកក្នុងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចនូវគោលនយោបាយអភិបាលកិច្ចល្អ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព សមធម៌ និងកាត់បន្ថយភាពក្រីក្រ។ ឆន្ទៈជំរុញដ៏មោះមុតនេះ បានផ្តួចផ្តើមបង្កើតឡើងដោយការប្តេជ្ញាចិត្តដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅឆ្នាំ២០០១ ជាឆ្នាំទី៣ អាណត្តិទី២ នៃរាជរដ្ឋាភិបាល។

## I-ប្រវត្តិសង្ខេប

### ១-ប្រវត្តិកកើត

អាជ្ញាធរសវនកម្មជាតិ មានអក្សរកាត់ជាភាសាខ្មែរ "**អ.ស.ជ**" ជាស្ថាប័នសាធារណៈមួយ មានភាពឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ ដែលត្រូវបានបង្កើតដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។

### ២-ទីតាំង

បច្ចុប្បន្នអាជ្ញាធរសវនកម្មជាតិ មានទីតាំងស្ថិតនៅអគារលេខ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

លេខទូរស័ព្ទ/ទូរសារទំនាក់ទំនង: (៨៥៥-២៣) ៨៨៥ ៩០០, អ៊ីម៉ែល: naakh@naa.gov.kh គេហទំព័រ: www.naa.gov.kh, Facebook: facebook.com/naakhsai។

### ៣-គោលបំណង និងទស្សនវិស័យការងារ

### ៣.១.គោលបំណង

ការបង្កើតអាជ្ញាធរសវនកម្មជាតិ មានគោលបំណងដើម្បីបំពេញមុខងារជាស្ថាប័នសវនកម្មកំពូលដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការ និងទទួលខុសត្រូវអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ អគ្គសវនករ ត្រូវបានប្រគល់អំណាចជូនក្នុងការបំពេញសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយធ្វើរបាយការណ៍សវនកម្មជូនរដ្ឋសភា ព្រឹទ្ធសភា និងចម្លងជូនទៅរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដើម្បីបានជ្រាប ក្នុងគោលដៅជំរុញឱ្យមានការកែលម្អប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងទាំងឡាយ ចំណុចខ្វះខាតឬភាពមិនប្រក្រតីក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

### ៣.២.ទស្សនវិស័យការងារ

ក្នុងការធ្វើឱ្យសម្រេចបាននូវលទ្ធផលសវនកម្ម អាជ្ញាធរសវនកម្មជាតិបានបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដោយបានកំណត់នូវទស្សនវិស័យ៖

**ជួយរាជរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងជួយលើការទទួលខុសត្រូវផ្នែកសាធារណៈ តាមរយៈការធ្វើសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត**

តាមរយៈលទ្ធផលសម្រេចបានក្នុងអំឡុងពេល១០ឆ្នាំកន្លងមកនេះ និងឈរលើស្មារតីយកចិត្តទុកដាក់អនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្រសួង ស្ថាប័នមួយចំនួនបានកែលម្អនូវចំណុចខ្វះខាតរបស់ខ្លួនដែលអាជ្ញាធរសវនកម្មជាតិបានកត់សម្គាល់។

### ៣.៣.ការរួមចំណែកជួយអង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ

ក្នុងការធ្វើសវនកម្មលើរបាយការណ៍សម្រេចទូទាត់ថវិកាចំណូល-ចំណាយរបស់ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អាជ្ញាធរសវនកម្មជាតិធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និងព្រឹទ្ធសភា។ អាជ្ញាធរសវនកម្មជាតិបានខិតខំកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការងារសវនកម្មមានគុណភាព ជឿទុកចិត្តបាន និងទាន់ពេលវេលា សម្រាប់ជាមូលដ្ឋានដល់រដ្ឋសភា និងព្រឹទ្ធសភា ក្នុងការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងថវិកាទូទៅ និងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំ។




## II- ប្រព័ន្ធគ្រប់គ្រង

### ១-តួនាទី និងភារកិច្ច

### ១.១.ការតែងតាំង និងតួនាទីរបស់ថ្នាក់ដឹកនាំ

ក្នុងក្របខណ្ឌជាស្ថាប័នសវនកម្មកំពូល អាជ្ញាធរសវនកម្មជាតិត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់ស្តីពីសវនកម្ម។ អគ្គសវនករទទួលខុសត្រូវលើការអនុវត្តគោលនយោបាយគោលដៅ និងគោលបំណងរបស់អាជ្ញាធរសវនកម្មជាតិ និងមានសិទ្ធិដើម្បីធ្វើសកម្មភាពលើរាល់កិច្ចការទាំងអស់ដែល

មានចែងក្នុងច្បាប់នេះ។ អគ្គសវនករជាអ្នកតែងតាំង ផ្លាស់ប្តូរ ធ្វើកម្មវិបាក និងកំណត់បៀវត្ស អត្ថប្រយោជន៍ ប្រាក់កម្រៃ ប្រាក់រង្វាន់ដល់មន្ត្រីរាជការ និងបុគ្គលិករបស់អាជ្ញាធរសវនកម្មជាតិ។

ជាមួយនេះអគ្គសវនករ និងអគ្គសវនកររងត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល និងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ អគ្គសវនករមានឋានៈ និងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និង អគ្គសវនកររងមានឋានៈ និងបុព្វសិទ្ធិ ស្មើនឹងរដ្ឋមន្ត្រី។

### ១.២.សិទ្ធិអំណាច និងវិសាលភាព

យោងតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា១៤ ចែងថា អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាព័ត៌មាន។ មាត្រា១៥ នៃច្បាប់នេះ ចែងថា ក្នុងការបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីអនុវត្តច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានសិទ្ធិអំណាចចេញសេចក្តីសម្រេច បទបញ្ជា សារាចរ និងការណែនាំផ្សេងៗទៀត។

អាជ្ញាធរសវនកម្មជាតិ មានសិទ្ធិអំណាចក្នុងការធ្វើសវនកម្មលើបណ្តាស្ថាប័នគ្រប់គ្រង រួមមានបណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារអាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គភាពផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើដើមទុនផ្ទាល់ និងឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនផង។

អាជ្ញាធរសវនកម្មជាតិមានវិសាលភាពអំណាចទូលំទូលាយក្នុងការអនុវត្តការងារសវនកម្មលើវិស័យសាធារណៈ ដែលមានខ្លឹមសារសំអាងក្នុងក្របខណ្ឌនៃច្បាប់ចាប់ពីមាត្រា២២ ដល់មាត្រា២៩ នៃជំពូក៥ ដែលចែងអំពីរបាយការណ៍នៃសវនកម្ម និងចាប់ពីមាត្រា៣០ ដល់មាត្រា៣៤ នៃជំពូក៦ ដែលចែងអំពីសិទ្ធិអំណាចលើការប្រមូលផ្តុំព័ត៌មាន។

### ២-រចនាសម្ព័ន្ធគ្រប់គ្រង

អាជ្ញាធរសវនកម្មជាតិ មានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖

១- អគ្គលេខាធិការដ្ឋាន

២- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៣- នាយកដ្ឋានបច្ចេកទេស

៤- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

៥- នាយកដ្ឋានសវនកម្មទី១

៦- នាយកដ្ឋានសវនកម្មទី២

៧- នាយកដ្ឋានសវនកម្មទី៣

- **អគ្គលេខាធិការដ្ឋាន**

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការ០១រូប និងមានអគ្គលេខាធិការរងចំនួន៥រូបជាជំនួយការ។ អគ្គលេខាធិការមានឋានៈស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈស្មើអនុរដ្ឋលេខាធិការ ដែលតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល។

អគ្គលេខាធិការដ្ឋានបច្ចុប្បន្នមាន០៣ការិយាល័យ ជាជំនួយការ គឺការិយាល័យទី១ ការិយាល័យទី២ និងការិយាល័យទី៣។

អគ្គលេខាធិការដ្ឋានមានភារកិច្ចធ្វើជាសេនាធិការឱ្យអាជ្ញាធរសវនកម្មជាតិលើការងារៈ

- ធានានិរន្តរភាពនៃការងាររបស់អាជ្ញាធរសវនកម្មជាតិ
- គ្រប់គ្រងសម្របសម្រួល និងតាមដានកិច្ចការរបស់នាយកដ្ឋាននានា
- សម្របសម្រួលក្នុងការរៀបចំរបាយការណ៍សវនកម្ម
- លើកសំណើផ្សេងៗទាក់ទងដល់គោលនយោបាយ គោលដៅ គោលបំណង និងតាមដានការអនុវត្តភារកិច្ចទាំងនេះ
- លើកសំណើតែងតាំង ផ្លាស់ប្តូរភារកិច្ច អត្ថប្រយោជន៍ផ្សេងៗជូនអគ្គសវនករសម្រេច
- ទំនាក់ទំនង និងសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

- **នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

នាយកដ្ឋាននេះមាន០៤ការិយាល័យ និង០១មជ្ឈមណ្ឌល គឺការិយាល័យរដ្ឋបាល ការិយាល័យបុគ្គលិក ការិយាល័យហិរញ្ញវត្ថុ ការិយាល័យផ្គត់ផ្គង់ និងមជ្ឈមណ្ឌលគ្រប់គ្រងឯកសារ។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានភារកិច្ចសម្របសម្រួលលើការងាររដ្ឋបាលចរាចរឯកសារ គ្រប់គ្រងមន្ត្រីរាជការបុគ្គលិក ពិធីការ សន្តិសុខ សណ្តាប់ធ្នាប់ ថវិកា ផ្គត់ផ្គង់សម្ភារៈ តាមដានកត់ត្រា និងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងធ្វើរបាយការណ៍ស្តីពីសកម្មភាពផ្សេងៗ ព្រមទាំងរក្សាទុកនូវឯកសារសំខាន់ៗទៀតផង។

- **នាយកដ្ឋានបច្ចេកទេស**

នាយកដ្ឋាននេះមាន០៥ការិយាល័យ គឺការិយាល័យនីតិកម្មនិងបណ្ណាល័យ ការិយាល័យស្រាវជ្រាវនិងបណ្តុះបណ្តាល ការិយាល័យព័ត៌មានវិទ្យា ការិយាល័យកិច្ចការសាធារណៈ និងការិយាល័យទំនាក់ទំនងផ្ទៃក្នុង។

នាយកដ្ឋានបច្ចេកទេសមានភារកិច្ចសម្របសម្រួលរៀបចំ និងអនុវត្តភារកិច្ចលើការងារនីតិកម្ម វិវាទកម្ម បណ្ណាល័យ ព័ត៌មានវិទ្យា ស្រាវជ្រាវ និងបណ្តុះបណ្តាលមុខវិជ្ជាទាក់ទងការងារសវនកម្ម។

- **នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ**

នាយកដ្ឋាននេះមាន០៣ការិយាល័យ គឺការិយាល័យទំនាក់ទំនងទ្វេភាគី ការិយាល័យទំនាក់ទំនងពហុភាគី និងការិយាល័យអនុវត្តគម្រោងជំនួយបរទេស។

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិមានភារកិច្ចទទួលបន្ទុកសម្របសម្រួល និងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងទីភ្នាក់ងារផ្តល់ជំនួយ ព្រមទាំងរៀបចំ តាមដាន និងវាយតម្លៃលើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យការបរទេស និងកិច្ចការអន្តរជាតិ ដែលមានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗដែលបានចុះហត្ថលេខា ដើម្បីដាក់ជូនថ្នាក់ដឹកនាំ។

- **នាយកដ្ឋានសវនកម្មទី១**

នាយកដ្ឋាននេះមាន០៤ការិយាល័យ គឺការិយាល័យសវនកម្មទី១.១ ការិយាល័យសវនកម្មទី១.២ ការិយាល័យសវនកម្មទី១.៣ និងការិយាល័យសវនកម្មទី១.៤។

នាយកដ្ឋានសវនកម្មទី១មានភារកិច្ចទទួលបន្ទុកចុះធ្វើសវនកម្មតាមបណ្តាក្រសួង-ស្ថាប័ន។

- **នាយកដ្ឋានសវនកម្មទី២**

នាយកដ្ឋាននេះមាន០៤ការិយាល័យ គឺការិយាល័យសវនកម្មទី២.១ ការិយាល័យសវនកម្មទី២.២ ការិយាល័យសវនកម្មទី២.៣ និងការិយាល័យសវនកម្មទី២.៤។

នាយកដ្ឋានសវនកម្មទី២ មានភារកិច្ចទទួលបន្ទុកចុះធ្វើសវនកម្មតាមអាជ្ញាធរ ធនាគារជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ ស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន ព្រមទាំងបណ្តារដ្ឋបាលខេត្ត-ក្រុង និងរដ្ឋបាលមូលដ្ឋាន។

- **នាយកដ្ឋានសវនកម្មទី៣**

នាយកដ្ឋាននេះមាន០៤ការិយាល័យ គឺការិយាល័យសវនកម្មទី៣.១ ការិយាល័យសវនកម្មទី៣.២ ការិយាល័យសវនកម្មទី៣.៣ និងការិយាល័យសវនកម្មទី៣.៤។

នាយកដ្ឋានសវនកម្មទី៣ មានភារកិច្ចទទួលបន្ទុកចុះធ្វើសវនកម្មលើភ្នាក់ងារអ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យាកិច្ចសន្យាសម្បទាន កិច្ចសន្យាវិនិយោគ ការគ្រប់គ្រងគម្រោងឥណទាន អង្គការសមាគម គណបក្សនយោបាយ និងសវនកម្មតាមសំណើពិសេស។

# ថ្នាក់ដឹកនាំនៃអាជ្ញាធរសវនកម្មជាតិអាណត្តិទី៣ (២០១១-២០១៦)

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ

ឯកឧត្តម ឆាយ គឹម អគ្គសវនកររង
មរណភាព ៥ កញ្ញា ២០១៥

ឯកឧត្តម សួន សិទ្ធី អគ្គសវនកររង

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ

ឯកឧត្តម សួន សិទ្ធី អគ្គសវនកររង

ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង
៥ វិច្ឆិកា ២០១៥ ជំនួសឯកឧត្តម ឆាយ គឹម

# ថ្នាក់ដឹកនាំនៃអាជ្ញាធរសវនកម្មជាតិអាណត្តិទី៤ (២០១៧-២០២១)

**លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ**



**ឯកឧត្តម សួន សិទ្ធី អគ្គសវនកររង**

**ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង**

## ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

ឯកឧត្តម ឡុង អាទិច្ចបូរា
អគ្គលេខាធិការ

ឯកឧត្តម សំរិត សាត
អគ្គលេខាធិការរង

លោកជំទាវ ហ៊្វ ដារ៉ារស្មី
អគ្គលេខាធិការរង

ឯកឧត្តម គឹម សុផល
អគ្គលេខាធិការរង

ឯកឧត្តម
ព្រហ្ម វិចិត្រសុភ័ណ្ឌ
អគ្គលេខាធិការរង

ឯកឧត្តម ងី វណ្ណឌី
អគ្គលេខាធិការរង

ឯកឧត្តម ឆែម សុជាតិ
អគ្គលេខាធិការរង
ត្រឹមខែមីនា ឆ្នាំ២០១៩

# ថ្នាក់ដឹកនាំនាយកដ្ឋាន

**លោក ប៉ោ ប៊ុន**
ប្រធាននាយកដ្ឋាន
រដ្ឋបាលនិងហិរញ្ញវត្ថុ

**លោក ឆាយ នព្វគុណ**
ប្រធាននាយកដ្ឋាន
បច្ចេកទេស

**លោកស្រី អ៊ុំ សាម៉ាដែត**
ប្រធាននាយកដ្ឋាន
សវនកម្មទី១

**លោកស្រី នៃ សុខគា**
ប្រធាននាយកដ្ឋាន
សវនកម្មទី២

**លោក ហ៊ីវ តារា**
ប្រធាននាយកដ្ឋាន
សវនកម្មទី៣

**លោក ជា សុផាត**
ប្រធាននាយកដ្ឋាន
ទំនាក់ទំនងអន្តរជាតិ

# រចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ន



# ផ្នែកទី២
# លទ្ធផលការងារ១០ឆ្នាំ (២០១២-២០២១)

## I- លទ្ធផលការងារជួយគាំទ្រដល់ការងារសវនកម្ម

ក្នុងរយៈពេល១០ឆ្នាំនេះ ក្រៅពីការងារសវនកម្មដែលជាការងារស្នូល អាជ្ញាធរសវនកម្មជាតិបាន ខិតខំកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័ន ដើម្បីជួយពង្រឹង និងធានានិរន្តរភាពនៃការងារសវនកម្ម។

### ១-ការរៀបចំឯកសារគតិយុត្ត

ការរៀបចំឯកសារគតិយុត្ត គឺជាការងារស្នូលមួយយ៉ាងសំខាន់សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការអនុវត្ត ការងារសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងអាចជឿទុកចិត្តបាន។ ក្នុងរយៈពេល១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំឯកសារគតិយុត្តមួយចំនួនស្របតាមស្តង់ដារសវនកម្មទូទៅ និងស្របតាម ស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជា ដើម្បីធ្វើឱ្យអាជ្ញាធរសវនកម្មជាតិក្លាយជាស្ថាប័នសវនកម្មកំពូល មួយដែលមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ ស្របតាមការវិវត្តនៃវិស័យសវនកម្មសាធារណៈ ដែលរួមមានខាង ក្រោម ៖

#### ១.១. ការចេញនូវសេចក្តីសម្រេច

ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងសមស្របតាមច្បាប់ អាជ្ញាធរសវនកម្មជាតិបាន ចេញសេចក្តីសម្រេចនានាដើម្បីធានានិរន្តរភាពការងារ និងជាឯកសារគតិយុត្ត បានប្រមាណចំនួន២៧៤ លេខ។

#### ១.២.ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១២-២០១៦)

សេចក្តីត្រូវការនៃការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ស្ថាប័នបានជំរុញឲ្យអាជ្ញាធរសវនកម្ម ជាតិរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី២ ឆ្នាំ២០១២-២០១៦។ ផែនការយុទ្ធសាស្ត្រនេះ បង្ហាញអំពីចក្ខុវិស័យ បេសកកម្ម និងគោលបំណងយុទ្ធសាស្ត្ររបស់អាជ្ញាធរសវនកម្មជាតិ។ ក្របខណ្ឌយុទ្ធ សាស្ត្រ ដែលរួមមានការវិភាគលើកត្តាអត្តនោម័ត និងសត្យានុម័ត ដើម្បីដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ ចំនួន៣ រួមមាន ១. "**ស្តង់ដារវិជ្ជាជីវៈ**" ពង្រឹងស្តង់ដារវិជ្ជាជីវៈនៃការងារសវនកម្ម ២. "**ការកសាងសមត្ថភាព ស្ថាប័ន**" បង្កើនផលិតភាព និងប្រសិទ្ធភាពការងារដោយការពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងស្ថាប័ន និង ៣. "**ការអភិវឌ្ឍន៍ស្ថាប័ន**" សម្រេចបាននូវកេរ្តិ៍ឈ្មោះនៃស្ថាប័នសវនកម្មមួយដែលអាចជឿជាក់បាន និងមាន សមត្ថភាព។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រដែលបានបញ្ជាក់នេះ សកម្មភាពចម្បងៗចំនួន២១ ត្រូវបាន ដាក់ចេញ និងបានអនុវត្តដោយប្រុងប្រយ័ត្ន និងតាមលំដាប់លំដោយ ហើយទទួលបានជោគជ័យ និងលទ្ធ ផលជាផ្លែផ្កាគួរជាទីមោទនៈ។

#### ១.៣. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១)

សេចក្តីត្រូវការនៃការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ស្ថាប័នបានជំរុញឱ្យអាជ្ញាធរសវនកម្ម ជាតិរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលទី៣ ឆ្នាំ២០១៧-២០២១។

អាជ្ញាធរសវនកម្មជាតិបន្តការកសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈសវនកម្ម និងការអភិវឌ្ឍស្ថាប័ន តាមរយៈ ៖

-គោលបំណងទី១: កសាង និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ ព្រមទាំងគុណភាពសវនកម្ម ដោយអនុលោមតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (ISSAI)។

-គោលបំណងទី២: ពង្រឹងការគ្រប់គ្រងធនធានមនុស្ស។

-គោលបំណងទី៣: លើកកម្ពស់ការយល់ដឹងរបស់សាធារណជនលើមុខងារសវនកម្មផ្ទៃក្រៅ និងការទំនាក់ទំនងខាងក្រៅជាមួយភាគីពាក់ព័ន្ធ។

-គោលបំណងទី៤: អភិវឌ្ឍ និងថែទាំប្រព័ន្ធព័ត៌មានបច្ចេកវិទ្យាសម្រាប់ការងាររដ្ឋបាល និងការងារសវនកម្ម។

-គោលបំណងទី៥: រួមចំណែក និងចូលរួមសិក្សាអំពីវិជ្ជាជីវៈសវនកម្មក្នុងបរិបថអន្តរជាតិ។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រដែលបានបញ្ជាក់នេះ សកម្មភាពចម្បងៗចំនួន៦៣ ត្រូវបានដាក់ចេញ និងបានអនុវត្តដោយប្រុងប្រយ័ត្ន និងតាមលំដាប់លំដោយ ហើយទទួលបានជោគជ័យ និងលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ បើទោះជាមានការរំខានខ្លះបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩។

### ១.៤.សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ

អាជ្ញាធរសវនកម្មជាតិបានបង្កើតសៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនាឆ្នាំ២០១១ ហើយបានធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំនេះឱ្យកាន់តែស៊ីជម្រៅថែមទៀត ក្នុងដំណើរការធ្វើទំនើបកម្មសវនកម្មក្នុងវិស័យសាធារណៈ។ សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិត្រូវបានរៀបចំឡើងដោយសង្កត់ធ្ងន់ទៅលើដំណើរការនៃការរៀបចំផែនការសវនកម្ម ការចុះធ្វើសវនកម្ម ការធ្វើរបាយការណ៍សវនកម្ម ការតាមដានអនុសាសន៍សវនកម្ម និងការគ្រប់គ្រងគុណភាពសវនកម្ម។ សៀវភៅណែនាំនេះត្រូវបានរៀបចំដោយផ្អែកលើស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារអន្តរជាតិសម្រាប់ស្ថាប័នសវនកម្មកំពូល (ISSAI 4100)។ ការដាក់ឱ្យប្រើសៀវភៅណែនាំសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ គឺជាជំហានដ៏សំខាន់មួយក្នុងចំណោមជំហានសំខាន់ៗនានាសម្រាប់អាជ្ញាធរសវនកម្មជាតិ រៀបចំខ្លួនក្លាយទៅជាស្ថាប័នមួយមានសមត្ថភាពជំនាញវិជ្ជាជីវៈ និងគួរជាទីទុកចិត្ត ដើម្បីជំរុញឱ្យមានតម្លាភាព គណនេយ្យភាព សំដៅឈានទៅរកអភិបាលកិច្ចល្អលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងដំណើរការធ្វើទំនើបកម្មសវនកម្មក្នុងវិស័យសាធារណៈ។

### ១.៥.សៀវភៅណែនាំស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ គឺជាប្រភេទសវនកម្មដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរសវនកម្មជាតិ។ ដើម្បីឱ្យការអនុវត្តការងារសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ប្រកបដោយគុណភាព និងស្របតាមស្តង់ដារសវនកម្មអន្តរជាតិ អាជ្ញាធរសវនកម្មជាតិបានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសដោយការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត។ សៀវភៅណែនាំនេះពិពណ៌នាអំពីដំណើរការនៃការធ្វើសវនកម្ម រួមមានការរៀបចំផែនការ ការចុះធ្វើសវនកម្មជាក់ស្តែង និងការរៀបចំរបាយការណ៍ដោយផ្អែកតាមស្តង់ដារអន្តរជាតិសម្រាប់ស្ថាប័នសវនកម្មកំពូល (ISSAIs)។ ទន្ទឹមនឹងនេះ ដោយមើលឃើញនូវចំណុចខ្វះខាតក្នុងសៀវភៅណែនាំនេះតាមរយៈការអនុវត្តការងារកន្លងមក និងការកែសម្រួលខ្លឹមសារ ISSAIs មួយចំនួន អាជ្ញាធរសវនកម្មជាតិ ដោយសហការជាមួយការិយាល័យ

សវនកម្មជាតិនៃប្រទេសស៊ុយអែត និងអង្គការផ្តួចផ្តើមអភិវឌ្ឍន៍របស់ស្ថាប័នសវនកម្មកំពូលអន្តរជាតិ (INTOSAI Development Initiative- IDI) បានចាប់ផ្តើមធ្វើបច្ចុប្បន្នភាពលើសៀវភៅណែនាំនេះឱ្យស្របតាមការវិវឌ្ឍជាក់ស្តែង ដោយបានដាក់បញ្ចូលបន្ថែមនូវទម្រង់គំរូ (Templates) មួយចំនួន ដើម្បីជាជំនួយក្នុងការអនុវត្តការងារសវនកម្មរបស់សវនករឱ្យកាន់តែមានទំនួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់។

### ១.៦.សៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ

តាមរយៈគម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរសវនកម្មជាតិ និងការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត អង្គការស្ថាប័នសវនកម្មកំពូលរបស់អាហ្វ្រិកនិយាយភាសាអង់គ្លេស (AFROSAI-E) បានផ្តល់នូវសៀវភៅណែនាំសវនកម្មលើកិច្ចប្រតិបត្តិការសម្រាប់ធ្វើជាមូលដ្ឋានដល់ អ.ស.ជ ក្នុងការរៀបចំសៀវភៅណែនាំសវនកម្មលើកិច្ចប្រតិបត្តិការ។ សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងស្របតាមគោលការណ៍ណែនាំរបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល និងស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (ISSAI 3000) និងស្របតាមបរិបថកម្ពុជា។

សៀវភៅណែនាំនេះ ជាសមិទ្ធផលមួយថ្មីទៀតនៃការអនុវត្តប្រភេទសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិក្នុងចំណោមសមិទ្ធផលនានាជាច្រើនដែលសម្រេចបានក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ។ ជាមួយនឹងការរៀបចំសៀវភៅណែនាំនេះ ការចុះធ្វើសវនកម្មសាកល្បងជាច្រើនឆ្នាំ បានផ្តល់នូវជាតុចូលយ៉ាងមានសារៈសំខាន់ដល់ការរៀបចំសៀវភៅណែនាំនេះដែលជាការវិវឌ្ឍន៍រីកចម្រើនឥតឈប់ឈររបស់អាជ្ញាធរសវនកម្មជាតិ។ សៀវភៅណែនាំនេះ គឺជាមគ្គុទេសក៏ដ៏ប្រសើរសម្រាប់ផ្តល់ការណែនាំដល់សវនករនៃអាជ្ញាធរសវនកម្មជាតិ ក្នុងការអនុវត្តការងារសវនកម្មលើកិច្ចប្រតិបត្តិការឱ្យបានសមស្របតាមស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល ដើម្បីសម្រេចបាននូវលទ្ធផលសវនកម្មប្រកបដោយគុណភាព និងបានប្រកាន់ខ្ជាប់តាមក្រមសីលធម៌របស់អាជ្ញាធរសវនកម្មជាតិក៏ដូចជាក្រមសីលធម៌របស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល។

### ១.៧.សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសម្រាប់គម្រោងហិរញ្ញប្បទានបរទេស

ក្រោមគម្រោងជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អាជ្ញាធរសវនកម្មជាតិបានរៀបចំនូវសៀវភៅណែនាំស្តីពីសវនកម្មលើភាពអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសម្រាប់គម្រោងហិរញ្ញប្បទានបរទេស ដើម្បីជានាំនូវការអនុវត្តការងារសវនកម្មប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ សៀវភៅនេះបានដាក់ចេញនូវក្របខណ្ឌការងារសវនកម្ម និងរួមបញ្ចូលនូវគោលនយោបាយសវនកម្មដែលគ្រប់គ្រងរាល់ការធ្វើសវនកម្មលើគម្រោងហិរញ្ញប្បទានបរទេសទាំងអស់។

### ១.៨.នីតិវិធីសវនកម្មលើកិច្ចប្រតិបត្តិការសម្រាប់គម្រោងហិរញ្ញប្បទានបរទេស

ដើម្បីជួយដល់មន្ត្រីសវនកម្មក្នុងការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការប្រកបដោយគុណភាព និងអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិ នីតិវិធីសវនកម្មលើកិច្ចប្រតិបត្តិការសម្រាប់គម្រោងហិរញ្ញប្បទានបរទេសត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានស្តង់ដារសវនកម្មរបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល(INTOSAI) និងបទពិសោធន៍នៃការអនុវត្តដែលបានទទួលស្គាល់ដោយអាជ្ញាធរសវនកម្មជាតិ។ ការរៀបចំនូវនីតិវិធីនេះ មានការជួយជ្រោមជ្រែងពីធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ នីតិវិធីសវនកម្មលើកិច្ចប្រតិបត្តិការនេះ ផ្តល់នូវព័ត៌មានទូលំទូលាយ និងការស្រាវជ្រាវសំខាន់ៗលើប្រធានបទជាច្រើនគ្របដណ្តប់លើវិស័យនានា នៃការឈរលើទស្សនៈមូលដ្ឋាន និងអភិក្រមសម្រាប់ការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការនៃបណ្តាកម្មវិធី និងសកម្មភាពរបស់រាជរដ្ឋាភិបាល។

នីតិវិធីសវនកម្មនេះ បង្ហាញអំពីវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យសំខាន់ៗក្នុងការវាយតម្លៃលើសកម្មភាពនានា ការគ្រប់គ្រងរបស់គម្រោង រួមមានការគ្រប់គ្រងបុគ្គលិក ការរៀបចំរចនាសម្ព័ន្ធ អង្គភាព នីតិវិធី និងប្រព័ន្ធគ្រប់គ្រង ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ការត្រួតពិនិត្យផ្ទៃក្នុង លទ្ធកម្ម ការគ្រប់គ្រងកិច្ចសន្យា ការតាមដាន និងការវាយតម្លៃ និងការប្រឆាំងអំពើពុករលួយជាដើម។

### ១.៩.សៀវភៅណែនាំស្តីពីសវនកម្មនៅធនាគារកណ្តាល

ការរៀបចំសៀវភៅណែនាំនេះ អនុលោមតាមមាត្រា២ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រគល់សិទ្ធិអំណាចជូនអាជ្ញាធរសវនកម្មជាតិ ក្នុងការធ្វើសវនកម្មលើធនាគារជាតិ គ្រឹះស្ថានហិរញ្ញវត្ថុនានាដែលរាជរដ្ឋាភិបាល បានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ។

មាត្រា៥៧ថ្មីនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ចែងថា ការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ។

ដើម្បីមានភាពងាយស្រួលដល់សវនករ ក្នុងការធ្វើសវនកម្មប្រកបដោយការទទួលខុសត្រូវ និងធានាបាននូវលទ្ធផលសវនកម្មមានគុណភាពខ្ពស់ អាជ្ញាធរសវនកម្មជាតិចាំបាច់ត្រូវរៀបចំនូវសៀវភៅណែនាំស្តីពីសវនកម្មនៅធនាគារកណ្តាល។ សៀវភៅនេះ បានផ្តួចផ្តើមរៀបចំឡើងដោយមានការជ្រោមជ្រែងពីសំណាក់អង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GIZ)។ សៀវភៅនេះ ជាត្រីវិស័យសម្រាប់ពង្រឹងសមត្ថភាពសវនករ និងស្ថាប័នប្រកបដោយវិជ្ជាជីវៈ និងបង្កើនជំនឿទុកចិត្តពីអង្គភាពរងសវនកម្ម ក៏ដូចជាពីសំណាក់សាធារណជន និងភាគីពាក់ព័ន្ធ។ ជាងនេះទៀត ការបង្កើតបានសៀវភៅនេះ គឺជាជំហានដ៏សំខាន់មួយសម្រាប់អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មលើវិស័យធនាគារសាធារណៈ។ អាជ្ញាធរសវនកម្មជាតិនឹងរៀបចំបំពេញបន្ថែមទៀតនូវរាល់សកម្មភាពណាដែលជាក់ស្តែងមានការប្រែប្រួល ដើម្បីសម្រួលដល់ការអនុវត្តការងារសវនកម្ម។

### ១.១០.សៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិលើក្រុង ស្រុក ខណ្ឌ

សៀវភៅណែនាំសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិលើក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ក្នុងគោលបំណងលើកកម្ពស់គុណភាពសវនកម្មឱ្យកាន់តែប្រសើរឡើង និងជាមគ្គុទ្ទេសក៍ ព្រមទាំងផ្តល់នូវការណែនាំអំពីដំណើរការនៃការរៀបចំផែនការសវនកម្ម ការចុះធ្វើសវនកម្ម ការធ្វើរបាយការណ៍សវនកម្ម និងការតាមដានអនុសាសន៍សវនកម្ម ព្រមទាំងបរិយាយអំពីតួនាទី និងភារកិច្ច និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សៀវភៅណែនាំនេះត្រូវបានរៀបចំដោយផ្អែកលើស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងសៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសវនកម្មជាតិ។

### ១.១១. កម្មវិធីសវនកម្មលើការប្រមូលចំណូលពន្ធដារ

អាជ្ញាធរសវនកម្មជាតិ បានរៀបចំកម្មវិធីសវនកម្មលើការប្រមូលចំណូលពន្ធដារ និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០។ កម្មវិធីសវនកម្មនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងមិនគ្រាន់តែផ្តល់ជាចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យពន្ធដារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយដល់

មន្ត្រីសវនករបស់អាជ្ញាធរសវនកម្មជាតិ ឱ្យធ្វើសវនកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់តាមរយៈកម្មវិធីសវនកម្មច្បាស់លាស់លើប្រភេទពន្ធនីមួយៗ និងវិធីសាស្ត្រក្នុងការធ្វើសវនកម្មជាដើម។

### ១.១២. កម្មវិធីសវនកម្មលើការប្រមូលចំណូលគយ

អាជ្ញាធរសវនកម្មជាតិ បានរៀបចំកម្មវិធីសវនកម្មលើការប្រមូលចំណូលគយ និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២១។ កម្មវិធីសវនកម្មនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងការពារលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ប្រមូលចំណូលពន្ធគយដែលបណ្តាលមកពីកំហុសចេតនា ឬអចេតនាលើការប្រមូលពន្ធគយដែលបានបង្ហាញក្នុងរបាយការណ៍ និងតួលេខបង់ចំណូលចូលថវិកាជាតិប្រចាំឆ្នាំនីមួយៗ ដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលមានលក្ខណៈសមស្របតាមស្ថានភាពជាក់ស្តែង។

## ២-ការចងក្រងឯកសារពាក់ព័ន្ធការងារសវនកម្ម

ក្នុងរយៈពេល១០ឆ្នាំនេះ ក្រៅពីការងារសវនកម្ម អាជ្ញាធរសវនកម្មជាតិបានរៀបចំ និងចងក្រងជាឯកសារស្រាវជ្រាវពាក់ព័ន្ធជំនាញសវនកម្មមួយចំនួន រួមមាន៖

- បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ស្តីពីការប្រើប្រាស់នូវកម្មវិធី TeamMate។
- រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឯកសាររបស់អាជ្ញាធរសវនកម្មជាតិ។
- បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយស្តីពីទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១។
- បានពិនិត្យ និងចងក្រងឯកសាររបាយការណ៍សវនកម្មផ្ទៃក្នុងរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន រួមមាន៖
    - ➢ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
    - ➢ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
    - ➢ ក្រសួងមុខងារសាធារណៈ
    - ➢ ក្រសួងមហាផ្ទៃ
    - ➢ ក្រសួងផែនការ
    - ➢ ក្រសួងពាណិជ្ជកម្ម
    - ➢ ក្រសួងសាធារណការ និងដឹកជញ្ជូន
    - ➢ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
    - ➢ ក្រសួងធនធានទឹក និងឧតុនិយម
    - ➢ ក្រសួងទេសចរណ៍
    - ➢ ក្រសួងអភិវឌ្ឍន៍ជនបទ
    - ➢ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
    - ➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
    - ➢ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
    - ➢ រដ្ឋាករស្វយ័តក្រុងភ្នំពេញ
    - ➢ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

## ៣-ការងារព័ត៌មានវិទ្យា

ការងារព័ត៌មានវិទ្យា គឺជាការងារមួយដ៏សំខាន់សម្រាប់អភិវឌ្ឍន៍នូវចំណេះដឹងនានាជូនដល់មន្ត្រី និងទំនើបកម្មការងារសវនកម្មដើម្បីឱ្យទាន់សភាពការណ៍វិវត្តន៍នៃវិស័យសវនកម្មសាធារណៈ។ ជាក់ស្តែង ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបានរៀបចំការងារព័ត៌មានវិទ្យាដែលទាក់ទង ទៅនឹងការងារសវនកម្ម ដូចខាងក្រោម៖

### ៣.១. គោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

តាមរយៈការទទួលបានការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងសហភាពអឺរ៉ុប (EU) និងជំនួយបច្ចេកទេសពីការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត គោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ប.គ.ព) ត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩។ គោលនយោបាយនេះបង្ហាញអំពីមគ្គុទេសក៍ និងទិសដៅរបស់អាជ្ញាធរសវនកម្មជាតិស្តីពីការគ្រប់គ្រងប្រព័ន្ធ ប.គ.ព ដើម្បីជួយឱ្យអាជ្ញាធរសវនកម្មជាតិ សម្រេចបាននូវចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់ខ្លួន តាមរយៈការផ្តល់នូវដំណោះស្រាយ ប.គ.ព ប្រកបដោយគុណភាព។

### ៣.២. ការថែទាំ និងការគាំទ្របច្ចេកវិទ្យាព័ត៌មានជាប្រចាំ

- បញ្ចូលព័ត៌មានស្តីពីការងាររបស់អាជ្ញាធរសវនកម្មជាតិ ដែលបានអនុវត្តកន្លងមកចូលក្នុងគេហទំព័ររបស់អាជ្ញាធរសវនកម្មជាតិ និងបានធ្វើបច្ចុប្បន្នភាព។
- គ្រប់គ្រង និងថែរក្សាបណ្តាញកុំព្យូទ័រ អ៊ីនធឺណែត សារអេឡិចត្រូនិច ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនបញ្ចាំងស្លាយ និងប្រព័ន្ធកុំព្យូទ័រមេ ឱ្យសមស្របតាមកម្រិតស្តង់ដារអន្តរជាតិ។
- តំឡើង ថែទាំ និងជួសជុលកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រជាប្រចាំតាមបណ្តានាយកដ្ឋាននានា។
- បានបណ្តុះបណ្តាលមន្ត្រីអាជ្ញាធរសវនកម្មជាតិ ពីការប្រើប្រាស់ និងថែទាំកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រជារៀងរាល់ឆ្នាំ។

## ៤-ការបោះផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រយៈពេល១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិ បានរៀបចំ និងផ្សព្វផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានចំនួន១៣លេខ គឺចាប់ពីលេខ០៣ ដល់លេខ១៥ ដែលរួមមាន៖

- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០០៨
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០០៩
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១០
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១១
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១២
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៣
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៤
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៥
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៦
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៧
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៨
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០១៩
- របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០២០

ទោះបីនៅក្នុងអាណត្តិមុន មិនទាន់បានរៀបចំឱ្យបានទាន់ពេលវេលាក៏ដោយ តែចាប់ពីអាណត្តិទី៣ អាជ្ញាធរសវនកម្មជាតិបានខិតខំរៀបចំចងក្រងរបាយការណ៍សវនកម្ម និងធ្វើការផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។ អាជ្ញាធរសវនកម្មជាតិបានចាត់ទុកថា ការផ្សព្វផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមឆ្នាំនីមួយៗ ជាការអនុវត្តច្បាប់ ជាការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរសវនកម្មជាតិ។

លោកជំទាវ សោម គឹមសួគ៌ អគ្គសវនករ ធ្វើសន្និសីទសារព័ត៌មាន
ផ្សព្វផ្សាយរបាយករណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ៥-បណ្ណាល័យ និងមជ្ឈមណ្ឌលគ្រប់គ្រងឯកសារ

អាជ្ញាធរសវនកម្មជាតិបានបង្កើតបណ្ណាល័យតាំងពីឆ្នាំ២០០៣ ដោយបានស្រាវជ្រាវថែរក្សាសៀវភៅ និងឯកសារសំខាន់ៗជាច្រើន ដើម្បីទុកឱ្យសវនករ និងមន្ត្រីជំនាញដទៃទៀតចូលសិក្សាស្រាវ ជ្រាវ និងស្វែងយល់អំពីសមិទ្ធផលសវនកម្មតាមបណ្តាឆ្នាំនីមួយៗ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបានទទួលឯកសារ និងសៀវភៅជាច្រើនមកពីបណ្តាស្ថាប័ននីតិប្បញ្ញត្តិ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាដូចជា៖

(១) លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរដ្ឋបាលខេត្ត និងបណ្តាមន្ទីរជំនាញចំណុះរដ្ឋបាលខេត្ត
(២) លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
(៣) លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
(៤) លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចលទ្ធកម្មសាធារណៈ
(៥) លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសារពើពន្ធកម្ពុជា

(៦) លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

(៧) ឯកសារគតិយុត្ត របាយការណ៍ស្តីពីការវាយតម្លៃស្ថាប័ន ផែនការយុទ្ធសាស្ត្រព្រឹទ្ធសភា

(៨) រាជកិច្ចប្រចាំខែនីមួយៗជារៀងរាល់ខែពីអគ្គនាយកដ្ឋានរាជកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

(៩) សៀវភៅថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០២-២០០៣ កម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

(១០) ព្រឹត្តិបត្រប្រចាំសប្តាហ៍ ព័ត៌មានពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម

(១១) ព្រឹត្តិបត្រសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

(១២) របាយការណ៍វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាពីអាជ្ញាធរអគ្គិសនីកម្ពុជា

(១៣) ព្រឹត្តិបត្រស្ថិតិជញ្ជីងទូទាត់កម្ពុជា និងព័ត៌មានស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំខែពីធនាគារជាតិនៃកម្ពុជា

(១៤) ទស្សនាវដ្តីរបស់អាជ្ញាធរទន្លេសាប

(១៥) សៀវភៅក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

(១៦) គម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ជាមួយអាជ្ញាធរសវនកម្មជាតិ(GIZ-NAA)

(១៧) គម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរសវនកម្មជាតិនិងការិយាល័យសវនកម្មជាតិប្រទេសស៊ុយអ៊ែត ។ល។

ដោយឡែក មជ្ឈមណ្ឌលគ្រប់គ្រងឯកសារ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤ ក្រោមគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) ដោយបានបំពាក់នូវឧបករណ៍ និងសម្ភារគាំទ្រដល់ការរៀបចំ ការគ្រប់គ្រង ការទុកដាក់ និងការថែរក្សាឯកសារគ្រប់ប្រភេទរបស់អាជ្ញាធរសវនកម្មជាតិ ឱ្យមានរបៀបរៀបរយតាមក្បួនខ្នាតបច្ចេកទេសត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការរៀបចំ ការគ្រប់គ្រង ការទុកដាក់ និងការថែរក្សាឯកសារ ជាពិសេសផែនការសកម្មភាព របាយការណ៍សវនកម្ម និងកម្រងឯកសារសវនកម្ម មានសារៈសំខាន់ណាស់សម្រាប់ផ្តល់ឯកសារទាន់ពេលវេលាដល់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិ។ ជារួម មជ្ឈមណ្ឌលគ្រប់គ្រងឯកសារបានរក្សាទុកឯកសារពាក់ព័ន្ធការងារសវនកម្មចំនួន ២៨១ច្បាប់។

## ៦-ការងារបណ្តុះបណ្តាល និងសិក្ខាសាលា

### ៦.១.វគ្គបណ្តុះបណ្តាល

#### ៦.១.១.វគ្គបណ្តុះបណ្តាលក្នុងប្រទេស

អាជ្ញាធរសវនកម្មជាតិបានរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីសវនកម្ម ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងលើកកម្ពស់ការយល់ដឹងបន្ថែម ស្តីពីសវនកម្ម ស្តង់ដារសវនកម្ម និងនីតិវិធីសវនកម្ម ចាប់ពីឆ្នាំ ២០១២-២០២១ បានចំនួន ៨៣ វគ្គ រួមមាន៖

**<u>តារាងទី១៖ បណ្តុះបណ្តាលក្នុងប្រទេសពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦</u>**

| ល.រ | ប្រភេទបណ្តុះបណ្តាល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|---|
| ១ | បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ លក្ខន្តិកៈដោយឡែកក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម | ១១២រូប | ១១៧រូប | ១២៤រូប | ១៣០រូប | ១២០រូប | **៦០៣រូប** |
| ២ | ការសរសេរលក្ខខណ្ឌការងារ | ១៥រូប | | ១២៤រូប | | | **១៣៩រូប** |
| ៣ | កម្មវិធី TeamMate | ២៥រូប | | | | | **២៥រូប** |
| ៤ | ការប្រើប្រាស់កុំព្យូទ័រ | ៣០រូប | | | | | **៣០រូប** |
| ៥ | ការយល់ដឹងពីការក្លែងបន្លំ | ៥០រូប | | | | | **៥០រូប** |
| ៦ | គោលការណ៍ណែនាំអំពីរបៀបធ្វើរបាយការណ៍សវនកម្មប្រចាំឆ្នាំសម្រាប់ផ្សព្វផ្សាយជាសាធារណៈ | ៥៥រូប | | | | | **៥៥រូប** |
| ៧ | ការចែករំលែកបទពិសោធន៍ និងលទ្ធផលដែលទទួលបានពីការចុះកម្មសិក្សានៅស្ថាប័នសវនកម្មកំពូលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ | | ៦០រូប | | | | **៦០រូប** |
| ៨ | ការចែករំលែកបទពិសោធន៍ និងលទ្ធផលពីការប្រើប្រាស់ពុម្ពអក្សរយូនីកូដ និងប្លង់ក្តារចុចយូនីកូដខ្មែរ | | ២៥រូប | | | | **២៥រូប** |
| ៩ | ការចែករំលែកបទពិសោធន៍ និងលទ្ធផលពីការធានានាគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុពីប្រទេសឥណ្ឌូនេស៊ី | | ៥២រូប | | | | **៥២រូប** |
| ១០ | ការចែករំលែកបទពិសោធន៍ និងលទ្ធផលពីការធានានាគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុពីប្រទេសឥណ្ឌូនេស៊ី | | ១៤៨រូប | | | | **១៤៨រូប** |
| ១១ | ការអនុវត្តការងារសវនកម្មនៅធនាគារកណ្តាល | | ២៥រូប | | | | **២៥រូប** |
| ១២ | ការធ្វើសវនកម្មលើគម្រោងហិរញ្ញប្បទានក្រៅប្រទេស | | ៣០រូប | | | | **៣០រូប** |
| ១៣ | ការណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធអ៊ីម៉ែលផ្លូវការសម្រាប់មន្ត្រីអាជ្ញាធរសវនកម្មជាតិ | | ៥០រូប | | | | **៥០រូប** |

| ល.រ | ប្រភេទបណ្តុះបណ្តាល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|---|
| ១៤ | ការគ្រប់គ្រងបណ្ណាល័យ | | ០៥រូប | | | | **០៥រូប** |
| ១៥ | ការគ្រប់គ្រងមជ្ឈមណ្ឌលគ្រប់គ្រងឯកសារ | | ០៥រូប | ០៥រូប | ០៥រូប | | **១៥រូប** |
| ១៦ | សវនកម្មលើកិច្ចប្រតិបត្តិការដោយគណៈប្រតិភូពីក្រុមប្រឹក្សាសវនកម្មឥណ្ឌូនេស៊ី | | | ៣០រូប | | | **៣០រូប** |
| ១៧ | សវនកម្មលើបរិស្ថាន និងកសិកម្មដោយគណៈប្រតិភូពីក្រុមប្រឹក្សាសវនកម្មឥណ្ឌូនេស៊ី | | | ៣០រូប | | | **៣០រូប** |
| ១៨ | ស្តង់ដារសវនកម្មសាធារណៈសម្រាប់មន្ត្រីអ.ស.ជឧទ្ទេសនាមដោយថ្នាក់ដឹកនាំនៃអាជ្ញាធរសវនកម្មជាតិ | | | ៧៧រូប | ៧០រូប | | **១៤៧រូប** |
| ១៩ | ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដោយគ្រូបង្គោលអាជ្ញាធរសវនកម្មជាតិ | | | | ៥០រូប | | **៥០រូប** |
| ២០ | ការគ្រប់គ្រងបន្ទប់រក្សាឯកសារសវនកម្មក្រោមការជួយឧបត្ថម្ភពីគម្រោង GIZ | | | | ០៥រូប | | **០៥រូប** |
| ២១ | សវនកម្មលើបរិស្ថាន និងការបង្ហាត់បង្ហាញពីការរៀបចំសៀវភៅណែនាំបច្ចេកទេសលើការធ្វើសវនកម្មលើបរិស្ថានក្រោមកិច្ចសហការជាមួយស្ថាប័នសវនកម្មកំពូលឥណ្ឌូនេស៊ី | | | | ៣០រូប | | **៣០រូប** |
| ២២ | ការធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | | | | | ១៥រូប | **១៥រូប** |
| ២៣ | លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល | | | | | ២៥រូប | **២៥រូប** |
| ២៤ | មូលដ្ឋានគ្រឹះនៃការធ្វើសវនកម្មសន្និធិ | | | | | ២៥រូប | **២៥រូប** |
| ២៥ | ស្តង់ដារសវនកម្ម និងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | | | | | ២៥រូប | **២៥រូប** |
| ២៦ | មូលដ្ឋានគណនេយ្យ និងការត្រួតពិនិត្យការអនុវត្តថវិកា | | | | | ២៥រូប | **២៥រូប** |
| ២៧ | សវនកម្មលើការអនុលោមតាមបទប្បញ្ញត្តិ | | | | | ២៥រូប | **២៥រូប** |
| ២៨ | សវនកម្មលើកិច្ចប្រតិបត្តិការ | | | | | ២៥នាក់ | **២៥រូប** |
| ២៩ | សវនកម្មតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យា | | | | | ២៥នាក់ | **២៥រូប** |

## តារាងទី២៖ បណ្តុះបណ្តាលក្នុងប្រទេសចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១

| ល.រ | ប្រធានបទបណ្តុះបណ្តាល | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| | | សិក្ខាកាម | | | | | |
| ១ | បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិលក្ខន្តិកៈដោយឡែកក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម | ១១០ | ៩៥ | ២០០ | ២០០ | ២០០ | **៨០៥** |
| ២ | ច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈសម្រាប់មន្ត្រីអ.ស.ជ | ៥៩ | ១១០ | ២០០ | ២០០ | ២០០ | **៧៦៩** |
| ៣ | គណនេយ្យ និងសវនកម្មទ្រព្យសកម្មរោងចក្រ អចលនទ្រព្យរូបីយ៍ អរូបីយ និងប្រភពធនធានធម្មជាតិ | ៤០ | - | - | - | - | **៤០** |
| ៤ | សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលរបស់អាជ្ញាធរសវនកម្មជាតិ | ៣៤ | - | - | - | - | **៣៤** |
| ៥ | ការចែករំលែកបទពិសោធន៍ស្តីពីភាពជាអ្នកដឹកនាំ | ៣០ | - | - | - | - | **៣០** |
| ៦ | សវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ | ៥១ | ៣០ | ៣០ | ៣០ | ៣០ | **១៧១** |
| ៧ | សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ៥១ | - | - | - | - | **៥១** |
| ៨ | - បែបបទរដ្ឋបាល<br>- ការគ្រប់គ្រងធនធានមនុស្ស<br>- មជ្ឈមណ្ឌលគ្រប់គ្រងឯកសារ | - | ៩៥ | ២០០ | - | - | **២៩៥** |
| ៩ | ការរៀបចំរបាយការណ៍សវនកម្មផ្សព្វផ្សាយជាសាធារណៈ | - | - | ៣០ | ៣០ | - | **៦០** |
| ១០ | គោលការណ៍ណែនាំសវនកម្មធនាគារកណ្តាល | - | ៣០ | - | - | - | **៣០** |
| ១១ | សវនកម្មតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យា | - | ៣០ | ៣០ | - | - | **៦០** |
| ១២ | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | - | ៣០ | - | - | - | **៣០** |
| ១៣ | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | - | ៣០ | - | - | - | **៣០** |
| ១៤ | គោលបំណងទូទៅនៃស្តង់ដារសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | - | ៣០ | - | - | - | **៣០** |
| ១៥ | ការរៀបចំផែនការសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | - | ៣០ | - | - | - | **៣០** |

| ល.រ | ប្រធានបទបណ្ដុះបណ្ដាល | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| | | សិក្ខាកាម | | | | | |
| ១៦ | ចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅ | - | ៣០ | - | - | - | ៣០ |
| ១៧ | ច្បាប់ស្ដីពីសារពើពន្ធ-ពន្ធលើប្រាក់បៀវត្ស & VAT | - | ៣០ | - | - | - | ៣០ |
| ១៨ | ស្តង់ដារសវនកម្ម១៣២០ | - | ៣០ | ៣០ | - | - | ៦០ |
| ១៩ | ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | - | ៣០ | ៣០ | ៥៨ | ៦០ | ១៧៨ |
| ២០ | ការកំណត់ហានិភ័យ | - | ៣០ | - | - | - | ៣០ |
| ២១ | ការឆ្លើយតបហានិភ័យ | - | ៣០ | - | - | - | ៣០ |
| ២២ | ភស្តុតាងសវនកម្ម | - | ៣០ | - | - | - | ៣០ |
| ២៣ | ស្តង់ដារ IFRS-IAS1 IAS15 & IAS 18 | - | ៣០ | ៣០ | ៥៨ | | ១១៨ |
| ២៤ | នីតិវិធីវិភាគ | - | ៣០ | - | - | - | ៣០ |
| ២៥ | ការរៀបចំឯកសារសវនកម្ម | - | ៣០ | - | - | - | ៣០ |
| ២៦ | ការបញ្ជ្រាបការយល់ដឹងអំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | - | ៦០ | - | - | - | ៦០ |
| ២៧ | ប្រភេទ និងវិធីសាស្ត្រលទ្ធកម្មសាធារណៈ | - | - | ៣០ | ៥៨ | ៦០ | ១៤៨ |
| ២៨ | ការរៀបចំផែនការលទ្ធកម្ម | | | ៣០ | - | - | ៣០ |
| ២៩ | នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ | - | - | ៣០ | - | - | ៣០ |
| ៣០ | ថវិកាកម្មវិធី | - | - | ៣០ | ៥៨ | ៦០ | ១៤៨ |
| ៣១ | ពន្ធដារ (ពន្ធស្លាកយីហោ និងអាករពិសេស) | - | - | ៣០ | ៥៨ | ៦០ | ១៤៨ |
| ៣២ | ស្តង់ដារសវនកម្ម១៣១៥ (ការកំណត់ហានិភ័យ) | - | - | ៣០ | ៥៨ | ៦០ | ១៤៨ |
| ៣៣ | ស្តង់ដារសវនកម្ម១៣២០ (ការកំណត់ភាពជាសារវ័ន្ត) | - | - | ៣០ | ៥៨ | ៦០ | ១៤៨ |
| ៣៤ | ស្តង់ដារសវនកម្ម១២៣០ (ការរៀបចំឯកសារសវនកម្ម) | - | - | ៣០ | ៥៨ | - | ៨៨ |
| ៣៥ | ស្តង់ដារសវនកម្ម១៣៣០ (ការឆ្លើយតបនឹងហានិភ័យ) | - | - | - | ៥៨ | ៦០ | ១១៨ |
| ៣៦ | ស្តង់ដារសវនកម្ម១៥០០ (ភស្តុតាងសវនកម្ម) | - | - | ៣០ | ៥៨ | - | ៨៨ |
| ៣៧ | ស្តង់ដារសវនកម្ម១៥២០ (នីតិវិធីវិភាគ) | - | - | ៣០ | ៥៨ | - | ៨៨ |
| ៣៨ | ស្តង់ដារសវនកម្ម១៥៣០ (ការជ្រើសរើសគំរូ) | - | - | ៣០ | - | ៦០ | ៩០ |

| ល.រ | ប្រធានបទបណ្តុះបណ្តាល | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| | | សិក្ខាកាម | | | | | |
| ៣៩ | ស្តង់ដារសវនកម្ម១៦២០ (ការប្រើប្រាស់អ្នកជំនាញ) | - | - | ៣០ | - | - | ៣០ |
| ៤០ | ស្តង់ដារសវនកម្ម១២៦០ និង ១២៦៥ (ការទំនាក់ទំនងជាមួយថ្នាក់ដឹកនាំ) | - | - | ៣០ | - | - | ៣០ |
| ៤១ | ស្តង់ដារសវនកម្ម១៤៥០ (ការវាយតម្លៃកំហុសឆ្គង) | - | - | ៣០ | - | - | ៣០ |
| ៤២ | ស្តង់ដារសវនកម្ម១៧០០ និង ១៧០៥ (ការបញ្ចេញមតិ) | - | - | ៣០ | - | - | ៣០ |
| ៤៣ | ចំណូលមិនមែនសារពើពន្ធ | - | - | ៣០ | - | - | ៣០ |
| ៤៤ | ស្តង់ដារគណនេយ្យសម្រាប់សហគ្រាសសាធារណៈ IAS2-សន្និធិ | - | - | ៣០ | - | - | ៣០ |
| ៤៥ | ស្តង់ដារគណនេយ្យសម្រាប់សហគ្រាសសាធារណៈ IAS16-ឧបករណ៍ គ្រឿងចក្រ និង អចលនទ្រព្យ | - | - | ៣០ | - | - | ៣០ |
| ៤៦ | ស្តង់ដារគណនេយ្យសម្រាប់សហគ្រាសសាធារណៈ IAS7-របាយការណ៍ចលនាសាច់ប្រាក់ | - | - | ៣០ | - | - | ៣០ |
| ៤៧ | ការធ្វើសវនកម្មអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋបាលក្រុងស្រុក- ខណ្ឌ | - | - | ៣០ | - | - | ៣០ |
| ៤៨ | ការភ្ជាប់ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងអ៊ីនធឺណែត អ៊ីម៉ែលក្នុង អសជ | - | - | ៣០ | ១២០ | - | ១៥០ |
| ៤៩ | គោលនយោបាយលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអ.ស.ជ | - | - | ៣០ | ១២០ | - | ១៥០ |
| ៥០ | ការភ្ជាប់ប្រព័ន្ធបណ្តាញកុំព្យូទ័រ កម្មវិធីកំចាត់មេរោគ និងការប្រើប្រាស់គេហទំព័រ អ.ស.ជ | - | - | - | ១២០ | - | ១២០ |
| ៥១ | ការប្រើប្រាស់កម្មវិធី Microsoft Word, Excel 2016 | - | - | - | ៥០ | - | ៥០ |
| ៥២ | ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | - | - | ៣០ | - | - | ៣០ |
| ៥៣ | កម្មវិធី និងឯកសារបណ្តុះបណ្តាលសវនកម្មលើកិច្ចប្រតិបត្តិការ | - | - | - | ៣០ | - | ៣០ |
| ៥៤ | សំណេរការងារសវនកម្ម ការប្រមូលភស្តុតាងសវនកម្ម និងលទ្ធផលសវនកម្ម | - | - | - | - | ១៩០ | ១៩០ |

### ៦.១.២.វគ្គបណ្តុះបណ្តាលក្រៅប្រទេស

អាជ្ញាធរសវនកម្មជាតិបានចាត់បញ្ជូនមន្ត្រីសវនកម្មឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១ បានចំនួន ៣២ វគ្គ មានដូចខាងក្រោម៖

**<u>តារាងទី៣៖ បណ្តុះបណ្តាលក្រៅប្រទេសចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦</u>**

| ល.រ | ប្រភេទបណ្តុះបណ្តាល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ប្រទេស |
|---|---|---|---|---|---|---|---|
| ១ | សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងភាពប្រក្រតី | ០២រូប | | | | | ឥណ្ឌា |
| ២ | កម្មសិក្សាសវនកម្ម | ០៤រូប | | | | | អាល្លឺម៉ង់ |
| ៣ | ការគ្រប់គ្រងសវនកម្មសាធារណៈ | ០២រូប | | | | | កូរ៉េ |
| ៤ | សវនកម្មលើវិស័យសង្គម | ០២រូប | | | | | ឥណ្ឌា |
| ៥ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០១រូប | | | | | ឥណ្ឌា |
| ៦ | សវនកម្មលើកិច្ចប្រតិបត្តិការ | | ០១រូប | ០១រូប | ០២រូប | ០១រូប | ម៉ាឡេស៊ី |
| ៧ | E-Learning ស្តីពីសវនកម្មហិរញ្ញវត្ថុផ្អែកលើហានិភ័យ | ០៦រូប | | | | | អនឡាញ |
| ៨ | E-Learning ស្តីពីការអនុវត្ត ISSAI | ០៤រូប | | | | | អនឡាញ |
| ៩ | សវនម្មលើបរិស្ថាន | | ០២រូប | | | | ឥណ្ឌា |
| ១០ | ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | | ០១រូប | | | | ឥណ្ឌា |
| ១១ | សវនកម្មលើព័ត៌មានវិទ្យា | | ០១រូប | ០១រូប | | ០១រូប | ម៉ាឡេស៊ី |
| ១២ | អ្នកសម្របសម្រួលលើការអនុវត្តឧបករណ៍វាយតម្លៃសុចរិតភាពរបស់ស្ថាប័នសវនកម្មកំពូល | | | ០៣រូប | | | វៀតណាម |
| ១៣ | សវនកម្មលើសហគ្រាសសាធារណៈ | | | ០២រូប | | | ឥណ្ឌា |
| ១៤ | ការផ្សព្វផ្សាយ និងការទំនាក់ទំនងសាធារណៈសម្រាប់ស្ថាប័នសវនកម្មកំពូលនៃប្រទេសអាស៊ាន | | | | ០១រូប | | ថៃ |
| ១៥ | ការវាយតម្លៃការអនុវត្តនៃការគ្រប់គ្រងបំណុល | | | | ០២រូប | | វៀតណាម |
| ១៦ | ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបទពិសោធន៍ | | | | | ០១រូប | ចិន |
| ១៧ | សវនកម្មលើកិច្ចប្រតិបត្តិការរៀបចំដោយ ASOSAI | | | | | ០១រូប | ចិន |
| សរុប | | ២១រូប | ០៥រូប | ០៧រូប | ០៥រូប | ០៤រូប | |

## តារាងទី៤៖ បណ្តុះបណ្តាលក្រៅប្រទេសចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១

| ល.រ | ប្រភេទបណ្តុះបណ្តាល | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ប្រទេស |
|---|---|---|---|---|---|---|---|
| ១ | កម្មវិធីថ្នាក់ក្រោយឧត្តមសិក្សាសម្រាប់ជំនាញសវនកម្ម | ០១ រូប | | | | | ចិន |
| ២ | សវនកម្មក្នុងបរិយាកាសព័ត៌មានវិទ្យា | ០១ រូប | | | | | ម៉ាឡេស៊ី |
| ៣ | វគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រ | ០១ រូប | | | | | ស៊ុយអែត |
| ៤ | ក្របខណ្ឌវាយតម្លៃការអនុវត្តរបស់ស្ថាប័នសវនកម្មកំពូល | | ០២ រូប | | | | ឥណ្ឌូនេស៊ី |
| ៥ | ជំនាញសម្របសម្រួល | | ១៥ រូប | | | | ស៊ុយអែត |
| ៦ | (១) សវនកម្មលើចំណូលរដ្ឋ (២) សវនកម្មលើបំណុលសាធារណៈ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធ/វិនិយោគសាធារណៈ (៣)សវនកម្មក្នុងបរិយាកាសព័ត៌មានវិទ្យា និងសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា | | ២០ រូប | | | | ចិន |
| ៧ | សវនកម្មលើកិច្ចប្រតិបត្តិការ | | ១៥ រូប | | | | ឥណ្ឌូនេស៊ី |
| ៨ | សវនកម្មលើកិច្ចប្រតិបត្តិការ | | ០២ រូប | | | | ម៉ាឡេស៊ី |
| ៩ | សវនកម្មលើសហគ្រាសសាធាណៈ និងសវនកម្មលើកិច្ចប្រតិបត្តិការ | | ០២ រូប | | | | ឥណ្ឌា |
| ១០ | ការធានាគុណភាពសវនកម្ម | | | ០៤ រូប | | | ស៊ុយអែត |
| ១១ | សវនកម្មលើអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច (Audit of e-Governance) | | | ០១ រូប | | | ឥណ្ឌា |
| ១២ | សវនកម្មលើកិច្ចប្រតិបត្តិការ | | | ០១ រូប | | | ឥណ្ឌា |
| ១៣ | ការអប់រំវិជ្ជាជីវៈរបស់ IDI សម្រាប់សវនករនៃស្ថាប័នសវនកម្មកំពូល | | | | ០១ រូប | | អនឡាញ |
| ១៤ | ប្រព័ន្ធវាយតម្លៃ និងត្រួតពិនិត្យ | | | | | ០២ រូប | អនឡាញ |
| ១៥ | ការអប់រំវិជ្ជាជីវៈសវនករសម្រាប់ស្ថាប័នសវនកម្មកំពូល | | | | | ១១ រូប | អនឡាញ |
| សរុប | | ០៣ រូប | ៥៦ រូប | ០៦ រូប | ០១ រូប | ១៣ រូប | |

## ៦.២.ការងារសិក្ខាសាលា

### ៦.២.១.ការងារសិក្ខាសាលា និងកិច្ចប្រជុំក្នុងស្រុក

ក្នុងរយៈពេល១០ឆ្នាំនេះ អាជ្ញាធរសវនកម្មជាតិបានបើកសិក្ខាសាលាផ្សព្វផ្សាយស្តង់ដារសវនកម្មសាធារណៈ និងសិក្ខាសាលាពាក់ព័ន្ធការងារសវនកម្មផ្សេងៗទៀតជូនដល់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងបណ្តាអង្គភាពផ្សេងៗ ដូចខាងក្រោម៖

- **ឆ្នាំ២០១២**

សិក្ខាសាលា ស្ថិតក្រោមគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) និងដៃគូអភិវឌ្ឍន៍ ADB ៖

- ផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជានៅខេត្តកែប
- ការធ្វើសវនកម្មលើគម្រោងជំនួយក្រៅប្រទេស
- ស្តង់ដារគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSAS)
- សិក្ខាសាលាស្តីពីការប្រមូលផ្តុំមតិដើម្បីកែលម្អខ្លឹមសារសេចក្តីព្រាងប្រកាស និងសារាចរណែនាំស្តីពីបង្កាន់ដៃបង់ប្រាក់។

- **ឆ្នាំ២០១៣**

សិក្ខាសាលា ស្ថិតក្រោមគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) និងដៃគូអភិវឌ្ឍន៍ ADB ៖

- ស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា
- សិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង។

- **ឆ្នាំ២០១៤**

សិក្ខាសាលា ស្ថិតក្រោមគម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) និងដៃគូអភិវឌ្ឍន៍ ADB ៖

- សិក្ខាសាលាផ្សព្វផ្សាយស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជាដល់មន្ត្រីរាជការ ក្នុងខេត្តព្រះសីហនុ
- សិក្ខាសាលា ស្តីពីភាពជាសារវន្តសវនកម្ម នៅសណ្ឋាគារហ៊ីមាវ៉ារី
- សិក្ខាសាលា ស្តីពីសវនកម្មលើធនាគារជាតិនៅសណ្ឋាគារភ្នំពេញ
- សិក្ខាសាលា ស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការដោយភាគីអាល្លឺម៉ង់ នៅខេត្តសៀមរាប
- សិក្ខាសាលា ស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ជូនថ្នាក់ដឹកនាំ និងសវនករ នៅក្រុងព្រះសីហនុ។

- **ឆ្នាំ២០១៥**

- សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជានៅខេត្តសៀមរាប

- **ឆ្នាំ២០១៧**

- កិច្ចប្រជុំពិនិត្យសកម្មភាពការងារប្រចាំឆ្នាំ២០១៧ និងផែនការសកម្មភាពការងារឆ្នាំ២០១៨ របស់អាជ្ញាធរសវនកម្មជាតិ
- សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជានៅខេត្តរតនគីរី និងរាជធានីភ្នំពេញ។

● ឆ្នាំ២០១៨

– កិច្ចប្រជុំ និងពិធីសំណេះសំណាលជាមួយមន្ត្រីថ្មី
– សិក្ខាសាលាស្តីពីក្រមសីលធម៌មន្ត្រី រាជការសវនកម្ម និងបទបញ្ជាផ្ទៃក្នុងអាជ្ញាធរសវនកម្មជាតិ
– សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជានៅខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ។

● ឆ្នាំ២០១៩

– សិក្ខាសាលាពិភាក្សាស្តីពីសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ
– កិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១
– សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជានៅខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។

● ឆ្នាំ២០២០

– កិច្ចប្រជុំពិភាក្សាការងារ និងរៀបចំឯកសារបណ្តុះបណ្តាលសវនកម្មលើកិច្ចប្រតិបត្តិការ
– សិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំ និងចែករំលែកបទពិសោធន៍ ស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ
– សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជានៅខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង និងខេត្តឧត្តរមានជ័យ។

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ចូលរួមបើកសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ រាជធានីភ្នំពេញ

សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្ដីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ រាជធានីភ្នំពេញ

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមកិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តផែនការ
យុទ្ធសាស្ត្រអភិវឌ្ឍន៍ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែសីហា
ឆ្នាំ២០១៩ សណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមសិក្ខាសាលាផ្សព្វផ្សាយ
សៀវភៅណែនាំ និងចែករំលែកបទពិសោធន៍ ស្ដីពីសវនកម្មលើកិច្ចប្រតិបត្តិការ
ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ សណ្ឋាគារអេមព្រីស អង្គរខេត្តសៀមរាប

### ៦.២.២.សិក្ខាសាលា ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំក្រៅប្រទេស

អាជ្ញាធរសវនកម្មជាតិបានចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញឱ្យទៅចូលរួមសិក្ខាសាលា ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំនៅក្រៅប្រទេសចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១ បានចំនួន១៣០ វគ្គ/លើក មានដូចខាងក្រោម៖

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| | ឆ្នាំ ២០១២ (ចំនួន១៧វគ្គ) | | |
| ១ | សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការធ្វើសវនកម្មស្របគ្នាលើការគ្រប់គ្រងបរិស្ថានទន្លេមេគង្គ | ០៤រូប | ថៃ |
| ២ | សិក្ខាសាលាស្ដីពីការវាយតម្លៃអំពីតម្រូវការរបស់ស្ថាប័ន | ០៤រូប | វៀតណាម |
| ៣ | សិក្ខាសាលាស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ | ០១រូប | ម៉ាឡេស៊ី |
| ៤ | សិក្ខាសាលាស្ដីពីការពិនិត្យឡើងវិញលើការអនុវត្តកម្មវិធីសហប្រតិបត្តិការស្ដីពីការធានាគុណភាពសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០៣រូប | ឥណ្ឌូនេស៊ី |
| ៥ | សិក្ខាសាលាលើកទី៤របស់ក្រុមការងារនៃអង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (ASOSAI) ស្តីពីសវនកម្មលើបរិស្ថាន | ០១រូប | ម៉ាឡេស៊ី |
| ៦ | សិក្ខាសាលាស្តីពីរបៀបនៃការសរសេររបាយការណ៍សវនកម្ម (សវនកម្មលើបរិស្ថាន) | ០៤រូប | ថៃ |
| ៧ | សិក្ខាសាលារៀបចំដោយស្ថាប័នសវនកម្មកំពូលអាស៊ាន (ASEANSAI) ស្តីពីសន្ទស្សន៍គណនេយ្យ និងសវនកម្មលើការគ្រប់គ្រងទឹកដែលមិនមានចំណូល | ០២រូប | ម៉ាឡេស៊ី |

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| ៨ | សិក្ខាសាលាស្តីពីការប្រឆាំងការក្លែងបន្លំ និងអំពើពុករលួយ | ០១រូប | ហ្វីលីពីន |
| ៩ | ទស្សនកិច្ចសិក្សានៅការិយាល័យសវនកម្មជាតិនៃប្រទេសចិន ស្តីពីសវនកម្មលើគម្រោងហិរញ្ញប្បទានក្រៅប្រទេស | ១០រូប | ចិន |
| ១០ | ទស្សនកិច្ចសិក្សាស្តីពីការងាររៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាល | ០៣រូប | ឥណ្ឌូនេស៊ី |
| ១១ | កិច្ចប្រជុំជាមួយក្រុមការងាររបស់អង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល (INTOSAI) លើកទី២១ស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា | ០២រូប | ម៉ាឡេស៊ី |
| ១២ | កិច្ចប្រជុំជាមួយក្រុមការងារចែករំលែកចំណេះដឹងរបស់ ASEANSAI | ០២រូប | ម៉ាឡេស៊ី |
| ១៣ | សិក្ខាសាលា ស្តីពីទំនាក់ទំនងជាយុទ្ធសាស្ត្ររបស់ស្ថាប័នសវនកម្មកំពូលពាក់ព័ន្ធ ពិសេសជាមួយគណៈកម្មាធិការគណនេយ្យសាធារណៈ នៃរដ្ឋសភា | ០៣រូប | ម៉ាឡេស៊ី |
| ១៤ | សិក្ខាសាលាស្តីពីការវាយតម្លៃតម្រូវការសម្រាប់គម្រោងកិច្ចសហប្រតិបត្តិការតំបន់ | ០២រូប | ថៃ |
| ១៥ | សិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ | ០៤រូប | ម៉ុងហ្គោលី |
| ១៦ | កិច្ចប្រជុំស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ(IFRS) | ០២រូប | ស្វីស |
| ១៧ | សិក្ខាសាលាស្តីពីអភិបាលកិច្ចល្អ | ០១រូប | ព្រុយណេ |
| | **ឆ្នាំ ២០១៣ (ចំនួន៦វគ្គ)** | | |
| ១ | សិក្ខាសាលាស្តីពីវិធីសាស្ត្រសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើហានិភ័យ | ០២រូប | ម៉ាឡេស៊ី |
| ២ | សិក្ខាសាលាស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការដែលរៀបចំដោយអង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (ASOSAI) | ០១រូប | ថៃ |
| ៣ | ទស្សនកិច្ចការងារ ស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ ការគ្រប់គ្រងកិច្ចសន្យា និងសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យានៅស្ថាប័នសវនកម្មកំពូល នៃប្រទេសម៉ាឡេស៊ី | ១០រូប | ម៉ាឡេស៊ី |
| ៤ | ទស្សនកិច្ចសិក្សានៅអាល្លឺម៉ង់ និងការពិភាក្សាវាយតម្លៃគម្រោងកិច្ចសហប្រតិបត្តិការនៅការិយាល័យសវនកម្មជាតិស៊ុយអែត | ០៤រូប | អាល្លឺម៉ង់ និងស៊ុយអែត |
| ៥ | ទស្សនកិច្ចសិក្សានៅស្ថាប័នសវនកម្មកំពូលឥណ្ឌូនេស៊ីដើម្បីពិភាក្សាការងារ និងកំណត់សកម្មភាពសម្រាប់ឆ្នាំ២០១៣ | ០៣រូប | ឥណ្ឌូនេស៊ី |
| ៦ | កិច្ចសហប្រតិបត្តិការសម្រាប់ការធ្វើសវនកម្មស្របគ្នា (Parallel Audit) លើការគ្រប់គ្រងបរិស្ថានទន្លេមេគង្គ | ០៤រូប | ថៃ |
| | **ឆ្នាំ ២០១៤ (ចំនួន១០វគ្គ)** | | |
| ១ | សិក្ខាសាលាស្តីពីការវាយតម្លៃការអនុវត្តការគ្រប់គ្រងបំណុល | ០២រូប | វៀតណាម |
| ២ | សិក្ខាសាលាស្តីពីសវនកម្មសហប្រតិបត្តិការលើអាងទន្លេមេគង្គ | ០៣រូប | វៀតណាម |
| ៣ | សិក្ខាសាលាស្តីពីការកសាងប្រព័ន្ធត្រួតពិនិត្យសម្រាប់ ASEANSAI | ០២រូប | វៀតណាម |
| ៥ | សិក្ខាសាលាស្តីពីការរៀបចំវគ្គបណ្តុះបណ្តាល និងបច្ចេកទេសនៃការបង្រៀន | ០៤រូប | ម៉ាឡេស៊ី |
| ៦ | សិក្ខាសាលាស្តីពីការចែករំលែកចំណេះដឹងលើការអនុវត្តស្តង់ដារអន្តរនៃស្ថាប័នសវនកម្មកំពូល (ISSAI) | ០២រូប | ឥណ្ឌូនេស៊ី |

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| ៧ | សិក្ខាសាលា ស្តីពីការរៀបចំផែនការសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន ដែលរៀបចំ ដោយអង្គការគំនិតផ្តួចផ្តើមនៃអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (IDI) ASOSAI | ០៣រូប | ឥណ្ឌា |
| ៨ | សិក្ខាសាលាស្តីពីជំនាញអ្នកសម្របសម្រួល ដែលរៀបចំដោយ IDI ASOSAI | ០៣រូប | បង់ក្លាដេស |
| ៩ | សិក្ខាសាលាស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុក្នុងបរិយាកាសបច្ចេកវិទ្យាព័ត៌មាន ដែលរៀបចំដោយ ASOSAI | ០១រូប | ចិន |
| ១០ | ទស្សនកិច្ចផ្តោតលើការរៀបចំឯកសារបណ្តុះបណ្តាល ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅការិយាល័យសវនកម្មជាតិស៊ុយអ៊ែត | ០៦រូប | ស៊ុយអ៊ែត |
| | **ឆ្នាំ ២០១៥ (ចំនួន៩វគ្គ)** | | |
| ១ | សិក្ខាសាលាស្តីពីសវនកម្មលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង | ០១រូប | ម៉ាឡេស៊ី |
| ២ | សិក្ខាសាលាស្តីពីការគ្រប់គ្រងស្ថាប័នសវនកម្មកំពូល | ០១រូប | ឥណ្ឌា |
| ៣ | សិក្ខាសាលាស្តីពីការផ្សព្វផ្សាយប្រព័ន្ធត្រួតពិនិត្យសម្រាប់ASEANSAI | ០២រូប | ឥណ្ឌូនេស៊ី |
| ៤ | សិក្ខាសាលាស្តីពីវិធីសាស្ត្រសវនកម្មផ្អែកតាមហានិភ័យនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០៥រូប | វៀតណាម |
| ៥ | សិក្ខាសាលារបស់គណៈកម្មការចែករំលែកចំណេះដឹង ASEANSAI ស្តីអំពីសវនកម្មលើការគ្រប់គ្រងទឹក | ០១រូប | ឥណ្ឌូនេស៊ី |
| ៦ | ទស្សនកិច្ចការងារស្តីពីការធានាគុណភាពសវនកម្មនៅប្រទេសស៊ុយអែត | ០៤រូប | ស៊ុយអែត |
| ៧ | កិច្ចប្រជុំស្ថាប័នសវនកម្មកំពូលតំបន់អាស៊ីអាគ្នេយ៍ ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ទាក់ទងនឹងការអនុវត្តល្អ | ០២រូប | ចិន |
| ៨ | កិច្ចប្រជុំពិភាក្សា ស្តីពីទម្រង់ស្រាវជ្រាវសម្រាប់សវនកម្មលើកិច្ចលទ្ធកម្មដែលរៀបចំដោយគណៈកម្មការចែករំលែកចំណេះដឹង | ០១រូប | ម៉ាឡេស៊ី |
| ៩ | កិច្ចប្រជុំគណៈកម្មាធិការដឹកនាំ (SCM) ទាក់ទងនឹងកិច្ចសហប្រតិបត្តិការរវាងអ.ស.ជ និង NAO ស៊ុយអែត | ០៥រូប | ស៊ុយអែត |
| | **ឆ្នាំ ២០១៦ (ចំនួន១០វគ្គ)** | | |
| ១ | សិក្ខាសាលាលើកទី១សម្រាប់ស្ថាប័នសវនកម្មកំពូលនៃរដ្ឋសមាជិករដ្ឋអង្កេតការនិងដៃគូសន្ទនានៃអង្គការសហប្រតិបត្តិសៀងហៃ | ០២រូប | ចិន |
| ២ | ការធ្វើឱ្យប្រសើរឡើងនូវតួនាទីរបស់ស្ថាប័នសវនកម្មកំពូលនៅក្នុងប្រទេសអាស៊ាន | ០១រូប | វៀតណាម |
| ៣ | រៀបចំឯកសារសម្រាប់ប្រធានបទ "គោលការណ៍អភិវឌ្ឍន៍ចីរភាព ថាតើ INTOSAI រួមចំណែកចំពោះរបៀបវារៈរបស់អង្គការសហប្រជាជាតិឆ្នាំ២០៣០ រួមមានអភិបាលកិច្ចល្អ និងពង្រឹងការប្រឆាំងអំពើពុករលួយ" | ០១រូប | ម៉ាឡេស៊ី |
| ៤ | ទស្សនកិច្ចការងារ ស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំនៅប្រទេសស៊ុយអែត | ០៧រូប | ស៊ុយអែត |
| ៥ | កិច្ចប្រជុំត្រួតពិនិត្យឡើងវិញសម្រាប់កម្មវិធីអនុវត្ត ISSAI | ០៥រូប | ថៃ |
| ៦ | កិច្ចប្រជុំគណៈកម្មាធិការផែនការយុទ្ធសាស្ត្ររបស់ ASEANSAI | ០១រូប | វៀតណាម |
| ៧ | កិច្ចប្រជុំត្រីភាគីលើកទី៧ រវាងស្ថាប័នសវនកម្មកំពូលកម្ពុជា ឡាវ និងវៀតណាម | ០៤រូប | វៀតណាម |

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| ៨ | សិក្ខាសាលា ស្តីពីបទពិសោធន៍ និងយុទ្ធសាស្ត្រនៃការអនុវត្ត ISSAI រៀបចំដោយ ASOSAI | ០១រូប | ប៊ូតាន |
| ៩ | សិក្ខាសាលា ស្តីពីសវនកម្មលើវិស័យសុខាភិបាលដែលរៀបចំដោយគណៈកម្មាធិការចែករំលែកចំណេះដឹង ASEANSAI | ០២រូប | ព្រុយណេ |
| ១០ | កិច្ចប្រជុំពិភាក្សាលើគម្រោងស្រាវជ្រាវស្តីពីសវនកម្មលើចំណូល | ០២រូប | ឡាវ |
| **ឆ្នាំ ២០១៧ (ចំនួន ២៣វគ្គ)** | | | |
| ១ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (ASOSAI) លើកទី៥១ | ៤ រូប | ឥណ្ឌូនេស៊ី |
| ២ | សិក្ខាសាលាស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការក្របខណ្ឌ ASOSAI | ០១ រូប | ម៉ាឡេស៊ី |
| ៣ | សិក្ខាសាលាស្តីពីការធ្វើឱ្យប្រសើរឡើង និងការរកឃើញថ្មីក្នុងដំណើរការសវនកម្ម រួមទាំងសវនកម្មលើការត្រៀមដាស្រេចសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្របខណ្ឌASOSAI | ០១ រូប | គុយវ៉ែត |
| ៤ | កិច្ចប្រជុំរបស់គណៈកម្មាធិការផែនការយុទ្ធសាស្ត្ររបស់ស្ថាប័នសវនកម្មកំពូលអាស៊ាន (ASEANSAI) លើកទី៨ | ០១ រូប | ឥណ្ឌូនេស៊ី |
| ៥ | សិក្ខាសាលាស្តីពីការធានាគុណភាពសវនកម្ម | ០២ រូប | ហ្វីលីពីន |
| ៦ | សិក្ខាសាលាជំនាញសម្របសម្រួលសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្តស្តង់ដារ ISSAI | ០៣ រូប | ឡាវ |
| ៧ | សន្និសីទជំនាញរវាងអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) ជាមួយអង្គការសហប្រជាជាតិលើកទី២៤ ស្តីពីឌីជីថលភាវូបនីយកម្ម | ០១ រូប | អូទ្រីស |
| ៨ | សិក្ខាសាលាស្តីពីសវនកម្មលើលិខិតបណ្តឹង និងការប្រឆាំងអំពើពុករលួយ | ០១ រូប | ថៃ |
| ៩ | កិច្ចប្រជុំប្រចាំឆ្នាំរវាង IDI ជាមួយក្រុមការងារថ្នាក់តំបន់របស់ INTOSAI | ០១ រូប | ន័រវេស |
| ១០ | មហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៣៨ | ០១ រូប | ហ្វីលីពីន |
| ១១ | សិក្ខាសាលាសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ០៣ រូប | វៀតណាម |
| ១២ | កិច្ចប្រជុំកំពូលរបស់ASEANSAI លើកទី៤ និងកិច្ចប្រជុំពាក់ព័ន្ធ | ០៥ រូប | ឡាវ |
| ១៣ | សិក្ខាសាលាសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ០១ រូប | មីយ៉ាន់ម៉ា |
| ១៤ | កម្មវិធីសម្រាប់អ្នកជំនាញបណ្តុះបណ្តាលតាមអនឡាញ | ០១ រូប | អនឡាញ |
| ១៥ | កិច្ចប្រជុំស្តីពីការត្រៀមដាស្រេចសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | ០១ រូប | អាមេរិក |
| ១៦ | ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំគណៈកម្មការដឹកនាំរវាង អ.ស.ជ ជាមួយ SNAO | ០៥ រូប | ស៊ុយអែត |
| ១៧ | សិក្ខាសាលាស្តីពីសវនកម្មសម្រាប់ស្ថាប័នសវនកម្មកំពូលនៃបណ្តាប្រទេសសមាជិកនៃគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយ ផ្លូវមួយ | ០២ រូប | ចិន |
| ១៨ | ទស្សនកិច្ចសិក្សា និងដកស្រង់បទពិសោធន៍ការងារទាក់ទងនឹងសវនកម្មលើកិច្ចប្រតិបត្តិការ | ១៥ រូប | វៀតណាម |
| ១៩ | សន្និសីទថ្នាក់តំបន់ស្តីពីការអនុវត្តការតាមដានហេតុសនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ | ០១ រូប | ថៃ |

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| ២០ | វេទិកាស្តីពីចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) នៃការងារសម្រាប់តំបន់អាស៊ី និងវេទិកាប្រតិបត្តិការប៉ាស៊ីហ្វិក និងសិក្ខាសាលាស្តីពីការអនុវត្ត PEFA | ០១ រូប | ហ្វីលីពីន |
| ២១ | សិក្ខាសាលាថ្នាក់តំបន់ស្តីពីការគ្រប់គ្រងហានិភ័យអំពើពុករលួយក្នុងកិច្ចលទ្ធកម្ម | ០១ រូប | ថៃ |
| ២២ | សិក្ខាសាលាគ្រប់គ្រងសកម្មភាពរបស់ASEANSAI | ០១ រូប | ម៉ាឡេស៊ី |
| ២៣ | ទស្សនកិច្ចសិក្សារួមគ្នារវាងគណៈប្រតិភូនៃព្រឹទ្ធសភា អាជ្ញាធរសវនកម្មជាតិ និងវិទ្យាស្ថានសភានៃកម្ពុជា | ០៦ រូប | ស៊ុយអែត |
| **ឆ្នាំ ២០១៨ (ចំនួន ២២ វគ្គ)** | | | |
| ១ | កិច្ចប្រជុំលើកទី១៨ របស់ក្រុមការងារ INTOSAI ស្តីពីសវនកម្មលើបរិស្ថាន | ០១ រូប | ឥណ្ឌូនេស៊ី |
| ២ | មហាសន្និបាតASOSAI លើកទី១៤ និងសន្និសីទជំនាញលើកទី៧ | ០៥ រូប | វៀតណាម |
| ៣ | កិច្ចប្រជុំលើកទី៦ និងសិក្ខាសាលាលើកទី៧ របស់ក្រុមការងារ ASOSAI ស្តីពីសវនកម្មលើបរិស្ថាន | ០១ រូប | ថៃ |
| ៤ | កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន និងកិច្ចប្រជុំរៀបចំផែនការសវនកម្ម | ០៣ រូប | អនឡាញ និងម៉ាឡេស៊ី |
| ៥ | សិក្ខាសាលាASEANSAI ស្តីពីការបង្កើនការយល់ដឹងស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកិច្ចប្រជុំសម្របសម្រួលរវាង ASEANSAI ជាមួយម្ចាស់ជំនួយ | ០៣ រូប | ឥណ្ឌូនេស៊ី |
| ៦ | សិក្ខាសាលាវាយតម្លៃស្តីពីសវនកម្មលើកិច្ចលទ្ធកម្មសាធារណៈ | ០២ រូប | ហ្វីលីពីន |
| ៧ | សិក្ខាសាលា ASEANSAI ស្តីពីការបង្កើនការយល់ដឹងអំពីឯករាជ្យភាពរបស់ស្ថាប័នសវនកម្មកំពូល | ០១ រូប | ថៃ |
| ៨ | កិច្ចប្រជុំបូកសរុបលទ្ធផលសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ០៤ រូប | ម៉ាឡេស៊ី |
| ៩ | កិច្ចប្រជុំចាប់ផ្តើម និងចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ស្តីពីការប្តេជ្ញាចិត្តសម្រាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់ ASEANSAI ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០២ រូប | ម៉ាឡេស៊ី |
| ១០ | សិក្ខាសាលាស្តីពីការស៊ើបអង្កេតសវនកម្មលើកំហុសចេតនា | ០២ រូប | ឥណ្ឌូនេស៊ី |
| ១១ | កិច្ចប្រជុំសម្រាប់ការរៀបចំឯកសារបណ្តុះបណ្តាលស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០១ រូប | ហ្វីលីពីន |
| ១២ | សិក្ខាសាលារបស់ ASEANSAI ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០៣ រូប | ឡាវ |
| ១៣ | សិក្ខាសាលាស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុIDI-ASEANSAI | ០២ រូប | ឡាវ |
| ១៤ | សិក្ខាសាលាត្រួតពិនិត្យឡើងវិញស្តីពីទំនាក់ទំនងរបស់ស្ថាប័នសវនកម្មកំពូលជាមួយភាគីពាក់ព័ន្ធ | ០៣ រូប | ហ្វីលីពីន |
| ១៥ | កិច្ចប្រជុំរៀបចំ និងត្រួតពិនិត្យរបាយការណ៍សវនកម្មសម្រាប់កម្មវិធីសវនកម្មលើកិច្ចប្រតិបត្តិការនៃការត្រៀមជាស្រេចសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | ០៣ រូប | ចិន |

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| ១៦ | កិច្ចប្រជុំស្តីពីការរួមចំណែករបស់ស្ថាប័នសវនកម្មកំពូលចំពោះការអនុវត្ត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) | ០១ រូប | អាមេរិក |
| ១៧ | សិក្ខាសាលាស្តីពីទំនាក់ទំនងរបស់ស្ថាប័នសវនកម្មកំពូលជាមួយភាគីពាក់ព័ន្ធ | ០១ រូប | ថៃ |
| ១៨ | កិច្ចប្រជុំត្រួតពិនិត្យឡើងវិញស្តីពីទំនាក់ទំនងរបស់ស្ថាប័នសវនកម្មកំពូល ជាមួយភាគីពាក់ព័ន្ធ | ០១ រូប | អាហ្វ្រិក ខាងត្បូង |
| ១៩ | សន្និសីទអន្តរជាតិស្តីពីវិស័យសាធារណៈរបស់ ACCA | ០១ រូប | សឹង្ហបុរី |
| ២០ | សិក្ខាសាលាថ្នាក់តំបន់លើកទី៤ ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ផ្អែកលើ ISSAI និងសវនកម្មស៊ើបអង្កេត | ០២ រូប | សឹង្ហបុរី |
| ២១ | សិក្ខាសាលាថ្នាក់តំបន់ស្តីពីការរៀបចំផែនទីបង្ហាញផ្លូវ និងយុទ្ធសាស្ត្រចាកចេញសម្រាប់ការអនុលោមតាមស្តង់ដារ ISSAI រៀបចំដោយគម្រោងADB ថ្នាក់តំបន់ | ០២ រូប | ថៃ |
| ២២ | កម្មវិធី 2018 Asian Evaluation Week (AEW) | ០១ រូប | ចិន |
| **ឆ្នាំ ២០១៩ (ចំនួន ១៨ វគ្គ)** | | | |
| ១ | កិច្ចប្រជុំលើកទី១២ របស់ក្រុមការងារ INTOSAI ស្តីពីតម្លៃ និងអត្ថប្រយោជន៍ របស់ SAI | ០១ រូប | អូទ្រីស |
| ២ | កិច្ចប្រជុំលើកទី១៩ របស់ក្រុមការងារ INTOSAI ស្តីពីសវនកម្មលើបរិស្ថាន | ០៣ រូប | ថៃ |
| ៣ | មហាសន្និបាតលើកទី២៣ របស់ INTOSAI | ០៥ រូប | រុស្ស៊ី |
| ៤ | កិច្ចប្រជុំត្រួតពិនិត្យឡើងវិញថ្នាក់តំបន់ | ០១ រូប | ថៃ |
| ៥ | សិក្ខាសាលាស្តីពីការត្រួតពិនិត្យគុណភាព និងការធានាគុណភាព | ០១ រូប | នេប៉ាល់ |
| ៦ | សិក្ខាសាលារួមគ្នារវាងអាស៊ាន ស្ថាប័នសវនកម្មកំពូលអាស៊ាន និងមហាសន្និបាតអន្តរសភាអាស៊ាន | ០២ រូប | ឥណ្ឌូនេស៊ី |
| ៧ | សិក្ខាសាលាស្តីពីប្រព័ន្ធគ្រប់គ្រងការចែករំលែកចំណេះដឹងរបស់ ASEANSAI | ០២ រូប | ឥណ្ឌូនេស៊ី |
| ៨ | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ ASEANSAI លើកទី៥ | ០៣ រូប | ឡាវ |
| ៩ | សិក្ខាសាលាស្តីពីការចូលរួមរបស់ម្ចាស់ជំនួយ និងស្ថាប័នសវនកម្មកំពូល | ០១ រូប | ហ្វីលីពីន |
| ១០ | កិច្ចប្រជុំកំពូលរបស់ASEANSAIលើកទី៥ | ០៦ រូប | ម៉ាឡេស៊ី |
| ១១ | សិក្ខាសាលានៃកម្មវិធីកិច្ចសហប្រតិបត្តិការ IDI-ASEANSAI ស្តីពីការវាយតម្លៃតម្រូវការការអនុវត្ត ISSAI សម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០៥ រូប | ថៃ |
| ១២ | កិច្ចប្រជុំគណៈកម្មការដឹកនាំរវាងអាជ្ញាធរសវនកម្មជាតិជាមួយការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត | ០៥ រូប | ស៊ុយអែត |
| ១៣ | ទស្សនកិច្ចសិក្សានៅការិយាល័យសវនកម្មជាតិនៃប្រទេសចិន | ១២ រូប | ចិន |
| ១៤ | ទស្សនកិច្ចសិក្សាទៅកាន់ខេត្ត Yokyakarta នៃសាធារណរដ្ឋឥណ្ឌូនេស៊ី | ១៣ រូប | ឥណ្ឌូនេស៊ី |
| ១៥ | កិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវ លើកទី១៣ | ០១ រូប | ឡាវ |
| ១៦ | សិក្ខាសាលាលើកទី៨ ក្របខណ្ឌគណៈកម្មការទទួលបន្ទុកគណនេយ្យសាធារណៈនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម | ០២ រូប | ឡាវ |

| ល.រ | បរិយាយ | ចំនួនមន្ត្រី | ទីកន្លែង |
|---|---|---|---|
| ១៧ | សិក្ខាសាលាលើកទី១៣ក្រោមប្រធានបទសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា | ០១ រូប | កូរ៉េ |
| ១៨ | សិក្ខាសាលាស្តីពីការបង្កើនតម្លាភាព និងសុចរិតភាពនៃលទ្ធកម្មសាធារណៈក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | ០១ រូប | ថៃ |
| **ឆ្នាំ ២០២០ (ចំនួន ៤ វគ្គ)** | | | |
| ១ | កិច្ចប្រជុំលើកទី២របស់គណៈកម្មាធិការចែករំលែកចំណេះដឹងរបស់ ASEANSAI | ១០ រូប | អនឡាញ |
| ២ | សិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពីការអនុវត្តគោលនយោបាយទំនាក់ទំនងរវាងស្ថាប័នសវនកម្មកំពូលជាមួយភាគីពាក់ព័ន្ធ | ៤ រូប | អនឡាញ |
| ៣ | សិក្ខាសាលារួមគ្នារវាង IDI និង ASEANSAI ស្តីពីការយល់ដឹងរបស់ ASEANSAI លើគំរូសវនកម្មរបស់ IDI លើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ( IDI's SDGs Audit Model - ISAM ) | ៣០ រូប | អនឡាញ |
| ៤ | សិក្ខាសាលារបស់ ASOSAI ស្តីពីសវនកម្មលើការអនុវត្ត SDGs និងការឆ្លើយតបរបស់ស្ថាប័នសវនកម្មកំពូលចំពោះជំងឺកូវីដ-១៩ | ០២ រូប | អនឡាញ |
| **ឆ្នាំ ២០២១ (ចំនួន ១១ វគ្គ)** | | | |
| ១ | កិច្ចប្រជុំរបស់ក្រុមការងារ INTOSAI ស្តីពីសវនកម្មលើបរិស្ថាន | ០៣ រូប | អនឡាញ |
| ២ | កិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្ររបស់ASEANSAI សម្រាប់ឆ្នាំ ២០២២ ដល់ឆ្នាំ២០២៥ | ០២ រូប | អនឡាញ |
| ៣ | សន្និសីទជំនាញរវាង INTOSAI ជាមួយអង្គការសហប្រជាជាតិលើកទី២៥ ស្តីពីការកសាងស្ថាប័នសវនកម្មកំពូលសម្រាប់ការពង្រឹងប្រសិទ្ធភាពស្ថាប័ន និងការសម្រេចបាននូវសង្គមមានចីរភាព | ០៥ រូប | អនឡាញ |
| ៤ | សិក្ខាសាលាស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ | ០៣ រូប | អនឡាញ |
| ៥ | សិក្ខាសាលាស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ០៣ រូប | អនឡាញ |
| ៦ | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ស្ថាប័នសវនកម្មកំពូលអាស៊ានលើកទី៦ | ០៦ រូប | អនឡាញ |
| ៧ | សិក្ខាសាលាស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ | ០៣ រូប | អនឡាញ |
| ៨ | សិក្ខាសាលារបស់គណៈកម្មាធិការចែករំលែកចំណេះដឹង ASEANSAI ស្តីពីការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការលើការនេសាទបែបទំនើប | ០៤ រូប | អនឡាញ |
| ៩ | កិច្ចប្រជុំត្រីភាគីលើកទី៩ ក្របខណ្ឌស្ថាប័នសវនកម្មកំពូល កម្ពុជា ឡាវ និងវៀតណាម | ២៤ រូប | អនឡាញ |
| ១០ | មហាសន្និបាតរបស់អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល ( ASOSAI ) លើកទី១៥ | ១៤ រូប | អនឡាញ |
| ១១ | កិច្ចប្រជុំកំពូលរបស់ស្ថាប័នសវនកម្មកំពូលអាស៊ាន( ASEANSAI ) លើកទី៦ | ១១ រូប | អនឡាញ |

## ៧-ការងារសហប្រតិបត្តិការ

### ៧.១.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ

#### ៧.១.១.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្បញ្ញត្តិ

- បានចូលរួមប្រជុំនានាជាមួយតំណាងរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ទាក់ទងនឹងវិស័យសេដ្ឋកិច្ចជាតិ និងវិស័យផ្សេងៗទៀត។
- បានចូលរួមប្រជុំជាមួយគណៈកម្មការទី២នៃរដ្ឋសភា និងគណៈកម្មការទី២នៃព្រឹទ្ធសភា ទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំ។
- បានចូលរួមក្នុងសិក្ខាសាលាស្វែងយល់ជាមួយរដ្ឋសភា អំពីក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។
- ទំនាក់ទំនងជាប្រចាំជាមួយគណៈកម្មការទី២នៃរដ្ឋសភា និងព្រឹទ្ធសភា។




លោកជំទាវ សោម គីមសួគ៌ ចូលរួមសិក្ខាសាលាស្តីពីក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង
គោលនយោបាយហិរញ្ញវត្ថុសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៩
នាថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅវិមានរដ្ឋសភា

## ៧.១.២.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននីតិប្រតិបត្តិ

- បានចូលរួមប្រជុំពិភាក្សាលើការងាររៀបចំឯកសារគតិយុត្តពាក់ព័ន្ធការងារហិរញ្ញវត្ថុសាធារណៈ។
- បានចូលរួមប្រជុំពិភាក្សាការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- បានចូលរួមសិក្ខាសាលាអំពីក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។
- សហការជាប្រចាំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ និងអនុវត្តដំណាក់កាលទី៣។
- បានចូលរួមប្រជុំពិភាក្សាការងារជាមួយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រប់ដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- បានចូលរួមសកម្មភាពសម្ពោធសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល
- ចូលរួមពិធីចែកសញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

លោកជំទាវ សោម គីមសួគ៌ ចូលរួមមហាសន្និបាតវិសាមញ្ញកាយរឹទ្ធិជាតិកម្ពុជា
នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ

លោកជំទាវ សោម គីមសួគ៌ ចូលរួមសន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ

លោកជំទាវ សោម គីមសួគ៌ ចូលរួមពិធីអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៩
នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ

### ៧.១.៣.ការរួមចំណែកក្នុងកិច្ចការសង្គម និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩

- បានចូលរួមបរិច្ចាគថវិការបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិជូនដល់កាកបាទក្រហមកម្ពុជា និងមូលនិធិគន្ធបុប្ផា ។
- ការបរិច្ចាគបៀវត្សផ្ទាល់ខ្លួនរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់អាជ្ញាធរសវនកម្មជាតិដោយស្ម័គ្រចិត្តជូនដល់គណៈកម្មការអន្តរក្រសួងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ចំនួន ពីរលើក៖
    - លើកទី១ ក្នុងឆ្នាំ២០២០ មានទឹកប្រាក់សរុបចំនួន ៖ ១៦៥ លានរៀល
    - លើកទី២ ក្នុងឆ្នាំ២០២១ មានទឹកប្រាក់សរុបចំនួន ៖ ១៣០ លានរៀល។

## ៧.២.កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មកំពូលអន្តរជាតិ

### ៧.២.១.ការបំពេញមុខងារជាប្រធានASEANSAI

ស្ថាប័នសវនកម្មកំពូលអាស៊ាន (ASEANSAI) ត្រូវបានបង្កើតនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ នាមហាសន្និបាតលើកទី១ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ដែលជាគោលបំណងរួមរបស់បណ្ដាស្ថាប័នសវនកម្មកំពូលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ASEANSAI គឺជាអង្គការមួយដែលមានមុខងារជួយសម្របសម្រួលការចែករំលែកចំណេះដឹង និងបទពិសោធន៍លើវិស័យសវនកម្មសាធារណៈ។ អាជ្ញាធរសវនកម្មជាតិជាស្ថាបនិកក្នុងការបង្កើត ASEANSAI ។ ASEANSAI បានបង្កើតនូវគណៈកម្មាធិការបច្ចេកទេសចំនួន០៥ រួមមាន៖ គណៈកម្មាធិការផែនការយុទ្ធសាស្ត្រ គណៈកម្មាធិការវិធាន និងនីតិវិធី គណៈកម្មាធិការចែករំលែកចំណេះដឹង គណៈកម្មាធិការបណ្តុះបណ្តាល និងលេខាធិការដ្ឋាន។

ការបង្កើតស្ថាប័នសវនកម្មអាស៊ាននៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី

ចាប់តាំងពីការបង្កើតមក ASEANSAIបានអនុវត្តនូវសកម្មភាពជាច្រើន ពិសេសគណៈកម្មការទាំងអស់របស់ ASEANSAI បានបំពេញការងារស្របទៅតាមផែនការការងារ។ នៅក្នុងឆ្នាំ២០១៥ ASEANSAI មានពិធីផ្ទេរតំណែងប្រធាន ASEANSAI អគ្គសវនករនៃស្ថាប័នសវនកម្មកំពូលនៃប្រទេសព្រុយណេ មកអគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អាណត្តិពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ ហើយប្រធានស្ថាប័នសវនកម្មរដ្ឋនៃប្រទេសឡាវត្រូវបានតែងតាំងជាអនុប្រធានASEANSAI សម្រាប់រយៈពេលដូចគ្នា។ សកម្មភាពសំខាន់ៗចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ មានដូចខាងក្រោម៖

(១) អាជ្ញាធរសវនកម្មជាតិចូលរួមប្រជុំកំពូលASEANSAI លើកទី២ នៅប្រទេសព្រុយណេ នាថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៣។ អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិទទួលការតែងតាំងជាអនុប្រធាន ASEANSAI។

(២) អាជ្ញាធរសវនកម្មជាតិ រៀបចំកិច្ចប្រជុំកំពូល ASEANSAI លើកទី៣ នៅសណ្ឋាគារសុខាភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលមានប្រតិភូចូលរួមសរុបចំនួន៥៥រូប ។

- អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិត្រូវបានមហាសន្និបាតអនុម័តតែងតាំងជាប្រធាន ASEANSAI សម្រាប់អាណត្តិ២ឆ្នាំ ២០១៦-២០១៧។
- មហាសន្និបាត បានសម្រេចលើរបៀបវារៈ
  - អនុម័តបង្កើតជាបណ្តោះអាសន្ននូវមុខងាររដ្ឋបាល និងមុខងារលេខាធិការដ្ឋានរបស់ ASEANSAI សម្រាប់រយៈពេលឆ្នាំ២០១៦-២០១៧ រហូតដល់មានការចុះហត្ថលេខាលើវិសោធនកម្មកិច្ចព្រមព្រៀង ASEANSAI ដោយមុខងាររដ្ឋបាលដឹកនាំដោយអាជ្ញាធរសវនកម្មជាតិ និងមុខងារលេខាធិការដ្ឋានដឹកនាំដោយស្ថាប័នសវនកម្មប្រទេសឥណ្ឌូនេស៊ី។
  - អនុម័តលើប្រធាន និងសមាជិកគណៈកម្មការ ASEANSAI
  - អនុម័តលើស្ថាប័នសវនកម្មថៃជាសវនករ ASEANSAI សម្រាប់ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ASEANSAI សម្រាប់ការិយបរិច្ឆេទ២០១៤ និង២០១៥។
  - អនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០១៣-២០១៤របស់ASEANSAI។
  - អនុម័តលើផែនការការងារឆ្នាំ២០១៦-២០១៧ របស់ ASEANSAI។
- ប្រធានគណៈប្រតិភូនៃសមាជិក ASEANSAI ត្រូវបានអនុញ្ញាតឱ្យចូលរួមសំដែងការគួរសមជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានសន្តិភាព នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥។

កិច្ចប្រជុំកំពូលស្ថាប័នសវនកម្មកំពូលអាស៊ានលើកទី៣ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ និងជាប្រធាន ASEANSAI ដឹកនាំកិច្ចប្រជុំកំពូលASEANSAIលើកទី៣

ប្រធានគណៈប្រតិភូ ASEANSAI ចូលជួបសម្តែងការគួរសមជាមួយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

(៣) លោកជំទាវ អគ្គសវនករ បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ASOSAI លើកទី៥១ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី។

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករនៃ អ.ស.ជ និងជាប្រធាន ASEANSAI ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការ ASOSAI លើកទី៥១

(៤) អាជ្ញាធរសវនកម្មជាតិបានរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ASEANSAI លើកទី៤ និងការងារត្រៀមផ្សេងៗ ចាប់ពីថ្ងៃទី៣១ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៧ នៅខេត្តសៀមរាប។

**លោកជំទាវ សោម គីមសួគ៌ អគ្គសវនករនៃ អ.ស.ជ និងជាប្រធាន ASEANSAI ចូលរួមពិធីបើកកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ ASEANSAI លើកទី៤ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា**

(៥) លោកជំទាវ បណ្ឌិត អគ្គសវនករ ចូលរួមកិច្ចប្រជុំកំពូលរបស់ASEANSAI លើកទី៤ និងកិច្ចប្រជុំពាក់ព័ន្ធចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

(៦) អាជ្ញាធរសវនកម្មជាតិបានរៀបចំ និងបោះពុម្ពសៀវភៅអំពីព័ត៌មានរបស់ASEANSAI កិច្ចប្រជុំ និងសកម្មភាពរបស់ASEANSAI សហគមអន្តរជាតិ និងASEANSAI សកម្មភាពរបស់គណៈកម្មការនានារបស់ASEANSAI មតិលើកទឹកចិត្តរបស់ប្រធានស្ថាប័នសវនកម្មកំពូលនៃប្រទេសជាសមាជិក ព្រមទាំងឯកសារនានារបស់ASEANSAI ដែលបានអនុវត្តក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ខែតុលា ឆ្នាំ២០១៧។

វឌ្ឍនភាពសំខាន់ៗរបស់ ASEANSAI ចាប់តាំងពីមហាសន្និបាតលើកទី៣ កាលខែវិច្ឆិកា ឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៧ មានដូចតទៅ៖

- សមាជិកទាំងអស់បានឯកភាពលើសេចក្តីព្រាងវិសោធនកម្មពិធីសារនៃកិច្ចព្រមព្រៀង ASEANSAI ដោយអនុញ្ញាតឱ្យមានការរៀបចំរចនាសម្ព័ន្ធលេខាធិការដ្ឋានឡើងវិញ ដោយមានអាណត្តិ៦ឆ្នាំ។ វិសោធនកម្មពិធីសារនេះត្រូវបានចុះហត្ថលេខា ដោយអគ្គសវនករនៃប្រទេសជាសមាជិក ASEANSAI នាខែធ្នូ ឆ្នាំ២០១៦។
- ASEANSAI បានរៀបចំ និងផ្ញើជូនអគ្គលេខាធិការអាស៊ាន នូវរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០១៥ របស់ ASEANSAI។
- ASEANSAI បានទទួល និងបន្តចូលរួមក្នុងការអនុវត្តផែនការសហគមន៍នយោបាយសន្តិសុខ ASEAN (APSC) ឆ្នាំ២០២៥ ។
- ASEANSAI បានរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ ASEANSAI និងបានបានអនុម័តផែនការយុទ្ធសាស្ត្ររបស់ ASEANSAI ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២១។

- គណៈកម្មាធិការចែករំលែកចំណេះដឹងរបស់ ASEANSAI បានសិក្សាស្រាវជ្រាវ ស្តីពីសវនកម្មលើចំណូល។ នៅឆ្នាំ២០១៦ ASEANSAI បានបង្កើតជារបាយការណ៍ស្តីពីការអនុវត្តល្អ និងគោលការណ៍ណែនាំស្តីពីសវនកម្មលើចំណូលសម្រាប់ជាប្រយោជន៍ដល់សមាជិកASEANSAI ក្នុងការពិចារណាបានយកអនុវត្តស្របតាមបរិបថរបស់ប្រទេសរៀងៗខ្លួន។
- គណៈកម្មាធិការបណ្តុះបណ្តាល បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យឡើងវិញសម្រាប់កម្មវិធីនៃការអនុវត្ត ISSAI សិក្ខាសាលាស្តីពីសវនកម្មលើកិច្ចសន្យាជាដើម។
- សមាជិក ASEANSAI បានឯកភាពឱ្យប្រធាន ASEANSAI តំណាងហត្ថលេខីលើកិច្ចព្រមព្រៀងរវាង ASEANSAI ជាមួយធនាគារពិភពលោក ដើម្បីគាំទ្រលើសកម្មភាពនៃការអនុវត្តកម្មវិធី ISSAI របស់ ASEANSAI ។
- ASEANSAI បានទំនាក់ទំនង និងសហប្រតិបត្តិការជាមួយ IDI ការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត។ ASEANSAI បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយការិយាល័យសវនកម្មជាតិស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការលើកម្មវិធីនៃការអនុវត្ត ISSAI។

សរុបជារួម ចាប់តាំងពីការបង្កើត ASEANSAI រហូតមកដល់ឆ្នាំ២០១៧ ASEANSAI បានបោះជំហានទៅមុខ តាមរយៈការធ្វើវិសោធនកម្មពិធីសារនៃកិច្ចព្រមព្រៀង ASEANSAI និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។ លើសពីនេះ ASEANSAI បានអភិវឌ្ឍសមត្ថភាពរបស់សមាជិកខ្លួន តាមរយៈសកម្មភាពនានារបស់គណៈកម្មាធិការចែករំលែកចំណេះដឹង និងគណៈកម្មាធិការបណ្តុះបណ្តាល។ សកម្មភាពត្រូវបានបង្កើន និងកែលម្អ សម្រាប់ជាប្រយោជន៍ដល់សមាជិក។ សកម្មភាពទាំងឡាយត្រូវបានរៀបចំដោយភាគច្រើនស្របតាមការអភិវឌ្ឍអន្តរជាតិលើផ្នែកសវនកម្មសាធារណៈ ការអនុវត្តស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល ដែលមានកម្មវិធីរយៈពេលវែងរបស់ ASEANSAI ស្តីពីការអនុវត្ត ISSAI (LTAP II) សិក្ខាសាលាចែករំលែកចំណេះដឹង និងគម្រោងស្រាវជ្រាវនានាជាដើម។

### ៧.២.២.សកម្មភាពទំនាក់ទំនងអន្តរជាតិ

ចាប់ពីឆ្នាំ២០១២ មកដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិបានចូលរួមក្នុងសកម្មភាពទំនាក់ទំនងអន្តរជាតិដូចខាងក្រោម៖

**ក. អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល**

អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) គឺជាស្ថាប័នស្វយ័ត ឯករាជ្យ ប្រកបដោយវិជ្ជាជីវៈ និងមិនពាក់ព័ន្ធនឹងនយោបាយដែលត្រូវបានបង្កើតឡើងជាស្ថាប័នអចិន្ត្រៃយ៍ដែលមានបេសកកម្មដូចខាងក្រោម៖

- ផ្តល់ការគាំទ្រទៅវិញទៅមកដល់ស្ថាប័នសវនកម្មកំពូល (SAI)
- ជំរុញការផ្លាស់ប្តូរគំនិត ចំណេះដឹង និងបទពិសោធន៍
- ជាអ្នកទំនាក់ទំនងសាធារណៈសកលដែលត្រូវបានទទួលស្គាល់របស់ SAIs នៅក្នុងសហគមន៍អន្តរជាតិ
- កំណត់ស្តង់ដារសម្រាប់ការធ្វើសវនកម្មលើវិស័យសាធារណៈ
- លើកកម្ពស់អភិបាលកិច្ចជាតិល្អ និង

- គាំទ្រការអភិវឌ្ឍសមត្ថភាពSAI កិច្ចសហប្រតិបត្តិការ និងការពង្រឹងការអនុវត្តជាបន្តបន្ទាប់។

អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិកអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) នៅក្នុងខែធ្នូ ឆ្នាំ២០០២ ដែលបច្ចុប្បន្នអង្គការនេះមានសមាជិកសរុបចំនួន ១៩៥ ប្រទេស។ ការចូលជាសមាជិកនៃ INTOSAI ផ្តើមចេញពីការប្រមូលផ្តុំ នៃស្ថាប័នសវនកម្មកំពូលតាមបណ្តាប្រទេសសំដៅពង្រឹងគោលការណ៍សវនកម្ម ស្តង់ដារសវនកម្ម និងផ្តល់នូវបទពិសោធន៍តាមរយៈការបំពេញទស្សនកិច្ចសិក្សា ការបណ្តុះបណ្តាល និងកិច្ចសហប្រតិបត្តិការនានាលើវិស័យសវនកម្មផ្ទៃក្រៅ ដើម្បីរួមចំណែកថែរក្សានូវសុវត្ថិភាពការងារជំនាញឱ្យសមស្របតាមកម្រិតស្តង់ដារអន្តរជាតិ។

អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) បានបង្កើតឡើងនៅឆ្នាំ១៩៥៣ និងមានក្រុមការងារតាមតំបន់ ឬសហគមន៍ចំនួន ៧ ដូចជា៖

- Organization of Latin American and Caribbean Supreme Audit Institutions (OLACEFS) បង្កើតឡើងនៅឆ្នាំ១៩៦៥
- African Organization of Supreme Audit Institutions (AFROSAI) បង្កើតឡើងនៅឆ្នាំ ១៩៧៦
- Arab Organization of Supreme Audit Institutions (ARABOSAI) បង្កើតឡើងនៅឆ្នាំ ១៩៧៦
- Asian Organization of Supreme Audit Institutions (ASOSAI) បង្កើតឡើងនៅឆ្នាំ ១៩៧៨
- Pacific Association of Supreme Audit Institutions (PASAI) បង្កើតឡើងនៅឆ្នាំ ១៩៨៧
- Caribbean Organization of Supreme Audit Institutions (CAROSAI) បង្កើតឡើងនៅឆ្នាំ ១៩៨៨
- European Organization of Supreme Audit Institutions (EUROSAI) បង្កើតឡើងនៅឆ្នាំ ១៩៩០។

ជាមួយនេះ អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិកក្រុមការងារបច្ចេកទេសនៃការធ្វើសវនកម្មតាមប្រព័ន្ធព័ត៌មានវិទ្យា (Working Group on IT audit) នៃអង្គការ INTOSAI និងចូលជាសមាជិកក្រុមការងារបច្ចេកទេសនៃការចងក្រងឯកសារស្តីពីតម្លៃ និងអត្ថប្រយោជន៍របស់បណ្តាស្ថាប័នសវនកម្មកំពូលនានា (Working Group in Value and Benefit of SAIs) នៃអង្គការ INTOSAI។

សម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិបានចូលរួមកិច្ចប្រជុំក្រុមការងារ សន្និសីទ និងមហាសន្និបាត មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | សកម្មភាព | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ១. | ២០១២ | កិច្ចប្រជុំក្រុមការងារស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យាលើកទី២១ | ថ្ងៃទី២៤-២៧ ខែមករា ឆ្នាំ ២០១២ | ម៉ាឡេស៊ី |
| ២. | ២០១៣ | មហាសន្និបាត INTOSAI លើកទី២១ | ថ្ងៃទី២២-២៧ ខែតុលា ឆ្នាំ២០១៣ | ចិន |
| | | កិច្ចប្រជុំក្រុមការងារស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យាលើកទី២២ | ថ្ងៃទី២១-២៨ ខែមេសា ឆ្នាំ ២០១៣ | Lithuania |
| | | កិច្ចប្រជុំក្រុមការងារ ស្តីពីតម្លៃ និងអត្ថប្រយោជន៍របស់SAI លើកទី៦ | ថ្ងៃទី០៣-០៥ ខែកក្កដា ឆ្នាំ ២០១៣ | ប៉េរូ |
| ៣. | ២០១៤ | កិច្ចប្រជុំក្រុមការងារ INTOSAI ស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យាលើកទី២២ | ថ្ងៃទី១០-១៣ ខែកុម្ភៈ ឆ្នាំ២០១៤ | គុយវ៉ែត |
| | | កិច្ចប្រជុំក្រុមការងារ INTOSAI ស្តីពីតម្លៃ និងអត្ថប្រយោជន៍របស់ SAI លើកទី៧ | ថ្ងៃទី១០-១២ ខែកញ្ញា ឆ្នាំ២០១៤ | ម៉ិចស៊ិច |
| ៤. | ២០១៧ | កិច្ចប្រជុំក្រុមការងារស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យាលើកទី២៦ | ថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ | កូរ៉េ |
| | | សន្និសីទជំនាញរវាងអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូលជាមួយអង្គការសហប្រជាជាតិលើកទី២៤ ស្តីពីឌីជីថលភាវូបនីយកម្ម | ថ្ងៃទី៣១ ខែឧសភា ដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧ | អូទ្រីស |
| ៥. | ២០១៨ | កិច្ចប្រជុំលើកទី១៨ របស់ក្រុមការងារស្តីពីសវនកម្មលើបរិស្ថាន | ថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ | ឥណ្ឌូនេស៊ី |
| ៦. | ២០១៩ | កិច្ចប្រជុំរបស់ក្រុមការងារស្តីពីតម្លៃ និងអត្ថប្រយោជន៍របស់ SAI លើកទី១២ | ថ្ងៃទី១ ដល់ថ្ងៃទី២ ខែមេសា ឆ្នាំ ២០១៩ | អូទ្រីស |
| | | កិច្ចប្រជុំរបស់ក្រុមការងារស្តីពីសវនកម្មលើបរិស្ថាន លើកទី១៩ | ថ្ងៃទី៦ ដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១៩ | ថៃ |
| | | ចូលរួមមហាសន្និបាតលើកទី២៣ របស់អង្គការ INTOSAI | ថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៩ | ប្រទេសរុស្ស៊ី |
| ៧. | ២០២០ | កិច្ចប្រជុំរបស់ក្រុមការងារស្តីពីតម្លៃ និងអត្ថប្រយោជន៍របស់ SAI លើកទី១៣ | ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ | អនឡាញ |
| ៨. | ២០២១ | សន្និសីទជំនាញរវាង INTOSAI និងអង្គការសហប្រជាជាតិលើកទី២៥ ស្តីពីការកសាងបទពិសោធន៍នៃស្ថាប័នសវនកម្មកំពូល សម្រាប់ការពង្រឹងប្រសិទ្ធភាពស្ថាប័ន និងការសម្រេចបាន នូវសង្គមដែលមាននិរន្តរភាព | ថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | អនឡាញ |

មហាសន្និបាត INTOSAI លើកទី២១ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ នៅប្រទេសចិន

មហាសន្និបាតលើកទី២៣ របស់អង្គការ INTOSAI ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៩
នៅទីក្រុងម៉ូស្គូ សាធារណរដ្ឋសហព័ន្ធរុស្ស៊ី

## ខ. អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល

អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (ASOSAI) គឺជាសហគមន៍មួយរបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI)។ ASOSAI ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧៨ ដែលមកដល់បច្ចុប្បន្ននេះ ASOSAI មានសមាជិកសរុបចំនួន ៤៧ ប្រទេស។ អាជ្ញាធរសវនកម្មជាតិបានចូលជាសមាជិករបស់ ASOSAI នៅក្នុងខែមីនា ឆ្នាំ២០០៤។ គោលបំណងរបស់ ASOSAI គឺ៖

- លើកកម្ពស់ការយល់ដឹង និងកិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិក តាមរយៈការផ្លាស់ប្តូរគំនិត និងបទពិសោធន៍នៅក្នុងវិស័យសវនកម្មសាធារណៈ
- ផ្តល់ឯកសារសម្រាប់ការបណ្តុះបណ្តាល និងការសិក្សាជាបន្តសម្រាប់សវនកររដ្ឋាភិបាល ដោយមានទស្សនៈកែលម្អគុណភាព និងការអនុវត្ត
- ដើរតួជាមជ្ឈមណ្ឌលព័ត៌មាន និងតំណភ្ជាប់ក្នុងតំបន់ជាមួយស្ថាប័ន និងផ្នែកដទៃទៀតនៃពិភពលោកនៅក្នុងវិស័យសវនកម្មសាធារណៈ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាតរភាពជិតស្និតក្នុងចំណោមសវនករក្នុងការជួយ រដ្ឋាភិបាលនៃស្ថាប័នជាសមាជិករៀងៗខ្លួន និងក្នុងចំណោមក្រុមការងារថ្នាក់តំបន់។

អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (ASOSAI) មានមុខងារ៖

- លើកទឹកចិត្ត និងលើកកម្ពស់ការស្រាវជ្រាវ និងការអនុវត្តការបោះពុម្ពផ្សាយឯកសារស្រាវជ្រាវ និងអត្ថបទវិជ្ជាជីវៈក្នុងវិស័យសវនកម្ម និងវិស័យពាក់ព័ន្ធ។
- រៀបចំសន្និសីទ និងសិក្ខាសាលា សម្រាប់ផ្លាស់ប្តូរគំនិត និងបទពិសោធន៍នៅក្នុងវិស័យសវនកម្មសាធារណៈ។

សម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិបានចូលរួមកិច្ចប្រជុំក្រុមការងារ សិក្ខាសាលា សន្និសីទ និងមហាសន្និបាត មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | សកម្មភាព | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ១. | ២០១២ | មហាសន្និបាតASOSAI លើកទី១២ | ថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ | ទីក្រុងចាយពួរ ប្រទេសឥណ្ឌា |
| ២. | ២០១៥ | មហាសន្និបាត ASOSAI លើកទី១៣ និងសន្និសីទអ្នកជំនាញលើកទី៧ | ថ្ងៃទី១០-១៣ ខែកុម្ភៈឆ្នាំ២០១៥ | ម៉ាឡេស៊ី |
| ៣. | ២០១៦ | ប្រជុំក្រុមប្រឹក្សាភិបាល ASOSAI លើកទី៥១ | ថ្ងៃទី១៥-១៧ ខែកុម្ភៈ ឆ្នាំ២០១៦ | ថៃ |
| ៤. | ២០១៧ | ប្រជុំក្រុមប្រឹក្សាភិបាល ASOSAI លើកទី៥១ | ថ្ងៃទី១៣-១៥ ខែកុម្ភៈ ឆ្នាំ២០១៧ | កោះបាលី ឥណ្ឌូនេស៊ី |
| | | សិក្ខាសាលាស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ | ថ្ងៃទី១០-២១ ខែកក្កដា ឆ្នាំ២០១៧ | ម៉ាឡេស៊ី |
| | | សិក្ខាសាលាស្តីពីការធ្វើឱ្យប្រសើរឡើង និងការរកឃើញថ្មីក្នុងដំណើរការសវនកម្ម រួមទាំងសវនកម្មលើការត្រៀមជា | ថ្ងៃទី១០-១៤ ខែធ្នូ ឆ្នាំ២០១៧ | គុយវ៉ែត |

| | | | | |
|---|---|---|---|---|
| | | ស្រេចសម្រាប់ការអនុវត្តគោលដៅ<br>អភិវឌ្ឍន៍ប្រកបដោយចីរភាព | | |
| ៥. | ២០១៨ | កិច្ចប្រជុំលើកទី៦ និងសិក្ខាសាលាលើកទី៧ របស់ក្រុមការងារ ASOSAI ស្ដីពីសវនកម្មលើបរិស្ថាន | ថ្ងៃទី២៩-៣១ ខែមករា ឆ្នាំ២០១៨ | ថៃ |
| | | មហាសន្និបាត ASOSAI លើកទី១៤ និងសន្និសីទជំនាញលើកទី៧ | ថ្ងៃទី១៩-២២ ខែកញ្ញា ឆ្នាំ២០១៨ | ទីក្រុងហាណូយ វៀតណាម |
| ៦. | ២០១៩ | សិក្ខាសាលាស្ដីពីការត្រួតពិនិត្យគុណភាព និងការធានាគុណភាព | ថ្ងៃទី២-៦ ខែធ្នូ ឆ្នាំ២០១៩ | នេប៉ាល់ |
| ៧. | ២០២០ | សិក្ខាសាលាស្ដីពីសវនកម្មលើការអនុវត្ត SDGs និងការឆ្លើយតបរបស់ស្ថាប័នសវនកម្មកំពូលចំពោះជំងឺកូវីដ១៩- | ថ្ងៃទី១-៤ ខែធ្នូ ឆ្នាំ ២០២១ | អនឡាញ |
| ៨. | ២០២១ | មហាសន្និបាត ASOSAI លើកទី១៥ និងសន្និសីទជំនាញលើកទី៨ | ថ្ងៃទី៦-៨ ខែកញ្ញា ឆ្នាំ២០២១ | អនឡាញ |

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ និងប្រធានASEANSAI ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ ASOSAI លើកទី៥១ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសាធារណរដ្ឋឥណ្ឌូនេស៊ី

មហាសន្និបាត ASOSAI លើកទី១៤ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨
នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

## គ. ស្ថាប័នសវនកម្មកំពូលអាស៊ាន

ស្ថាប័នសវនកម្មកំពូល (SAIs) នៃបណ្ដាប្រទេសជាសមាជិកអាស៊ាន បានចូលរួមសកម្មភាពដែលផ្ដល់ដោយ INTOSAI និង ASOSAI ក្នុងការកសាងក្របខណ្ឌស្ថាប័ន និងការពង្រឹងសមត្ថភាពរបស់ SAIs។ ទោះជាយ៉ាងណា ជាមួយនឹងការកើនឡើងនៃតម្រូវការដែល SAIs នៃប្រទេសជាសមាជិកអាស៊ានត្រូវបានគេហៅឱ្យបំពេញនោះ ពួកគេមានអារម្មណ៍ថាចាំបាច់ត្រូវមានវេទិកាដែលផ្ដោតទៅលើការជំរុញកិច្ចសហប្រតិបត្តិការបច្ចេកទេសនៅក្នុងការធ្វើសវនកម្មក្នុងវិស័យសាធារណៈ ការផ្លាស់ប្ដូរព័ត៌មាន ឧត្តមានុវត្តន៍ និងបទពិសោធន៍ ដែលកំពុងដោះស្រាយបញ្ហាទូទៅដែលប្រឈមមុខនៅក្នុងតំបន់អាស៊ាន។ ដោយសារតម្រូវការនេះ SAIs ទាំង១០ នៃប្រទេសជាសមាជិកអាស៊ានបានសម្រេចចិត្តបង្កើតអង្គការថ្មីមួយដែលមានឈ្មោះថា "ស្ថាប័នសវនកម្មកំពូលអាស៊ាន (ASEANSAI)" ។

ASEANSAI ត្រូវបានរំពឹងថានឹងលើកទឹកចិត្ត និងលើកកម្ពស់អភិបាលកិច្ចល្អក្នុងចំណោមតំបន់អាស៊ាន។ ដូចនេះ ASEANSAI នឹងផ្ដោតលើការអភិវឌ្ឍសមត្ថភាពសម្រាប់ SAIs នៃប្រទេសជាសមាជិកអាស៊ាន និងដោះស្រាយកិច្ចសហប្រតិបត្តិការបច្ចេកទេសទាក់ទងនឹងបញ្ហាសវនកម្មសំខាន់ និងរួមគ្នានៅក្នុងតំបន់អាស៊ាន។ ការបង្កើត ASEANSAI គឺស្របជាមួយនឹងការប្ដេជ្ញាចិត្តរបស់ប្រទេសជាសមាជិកអាស៊ានក្នុងការបង្កើតសហគមន៍អាស៊ានមួយនៅឆ្នាំ២០១៥ ដោយមានគោលការណ៍អភិបាលកិច្ចល្អដូចមានចែងក្នុងបុព្វបទនៃធម្មនុញ្ញអាស៊ាន។ ដើម្បីសម្រេចបានគោលដៅនេះ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អ និងជិតស្និតថែមទៀតក្នុងចំណោម SAIs នៃសមាជិកអាស៊ាន។ ដូច្នេះ ASEANSAI ក៏នឹងរួមចំណែកជាវិជ្ជមាន និងប្រកបដោយភាពធ្វេប្រឌិតក្នុងនាមជាដៃគូឯករាជ្យរបស់អាស៊ានទាក់ទងនឹងការលើកកម្ពស់អភិបាលកិច្ចល្អដើម្បីមានរដ្ឋាភិបាលដ៏ល្អប្រសើរ។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ SAIs ចំនួន១០ បានជួបប្រជុំគ្នានៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី រួមមានៈ ស្ថាប័នសវនកម្មនៃប្រទេសព្រុយណេ អាជ្ញាធរសវនកម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាសវនកម្មនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្ថាប័នសវនកម្មកំពូលនៃប្រទេសម៉ាឡេស៊ី ការិយាល័យអគ្គសវនករនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា គណៈកម្មការសវនកម្មនៃសាធារណរដ្ឋហ្វីលីពីន ការិយាល័យអគ្គសវនករសិង្ហបុរី ការិយាល័យសវនកម្មរដ្ឋនៃព្រះរាជាណាចក្រថៃ និងការិយាល័យសវនកម្មរដ្ឋនៃសាធារណរដ្ឋសង្គមនិយមប្រទេសវៀតណាម ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការបង្កើត ASEANSAI។

សម្រាប់ឆ្នាំ២០១៣ ដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិបានចូលរួមកិច្ចប្រជុំក្រុមការងារ សិក្ខាសាលា និងកិច្ចប្រជុំកំពូល មានដូចខាងក្រោមៈ

| ល.រ | ឆ្នាំ | សកម្មភាព | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ១. | ២០១៣ | មហាសន្និបាត ASEANSAI លើកទី២ | ថ្ងៃទី០៤-០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ | ព្រុយណេ |
| ២. | ២០១៤ | កិច្ចប្រជុំថ្នាក់បច្ចេកទេស និងកិច្ចប្រជុំ ASEANSAI សន្និសីទជំនាញ ASEANSAI ស្តីពីគណនេយ្យភាពក្នុងអាស៊ាន | ថ្ងៃទី១៧-២០ ខែមករា ឆ្នាំ២០១៤ | ឥណ្ឌូនេស៊ី |
| ៣. | ២០១៥ | កិច្ចប្រជុំ ASEANSAI | ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៥ | ម៉ាឡេស៊ី |
| | | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី៣ និងកិច្ចប្រជុំត្រៀមរៀបចំផ្ទេរប្រធាន ASEANSAI | ថ្ងៃទី២៧-២៩ ខែកក្កដា ឆ្នាំ២០១៥ | ព្រុយណេ |
| | | ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូល ASEANSAI លើកទី៣ | ថ្ងៃទី០៤-០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ | កម្ពុជា |
| ៤. | ២០១៦ | កិច្ចប្រជុំបច្ចេកទេស ASEANSAI | ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ | ថៃ |
| ៥. | ២០១៧ | កិច្ចប្រជុំរបស់គណៈកម្មាធិការផែនការយុទ្ធសាស្ត្រ លើកទី៨ | ថ្ងៃទី១៦-១៨ ខែកុម្ភៈ ឆ្នាំ២០១៧ | កោះបាលី ឥណ្ឌូនេស៊ី |
| | | វគ្គបណ្តុះបណ្តាលស្តីពីការធានាគុណភាពសវនកម្ម | ថ្ងៃទី២៤-២៨ ខែមេសា ឆ្នាំ២០១៧ | ហ្វីលីពីន |
| | | សិក្ខាសាលាសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ថ្ងៃទី៨-១៩ ខែឧសភា ឆ្នាំ២០១៧ | ឡាវ |
| | | រៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី៤ និងកិច្ចប្រជុំត្រៀម | ថ្ងៃទី៣១ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៧ | ខេត្តសៀមរាប កម្ពុជា |
| | | សិក្ខាសាលាស្តីពីសវនកម្មលើលិខិតបណ្តឹង និងការប្រឆាំងអំពើពុករលួយ | ថ្ងៃទី២៩-៣១ ខែសីហា ឆ្នាំ២០១៧ | ថៃ |
| | | កិច្ចប្រជុំប្រចាំឆ្នាំរវាង IDI ជាមួយក្រុមការងារថ្នាក់តំបន់របស់ INTOSAI | ថ្ងៃទី៤-៦ ខែកញ្ញា ឆ្នាំ២០១៧ | ន័រវេ |

| | | | | |
|---|---|---|---|---|
| | | សិក្ខាសាលាសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ថ្ងៃទី២៨ ខែតុលា ដល់ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ | វៀតណាម |
| | | កិច្ចប្រជុំកំពូលរបស់ASEANSAI លើកទី៤ និងកិច្ចប្រជុំពាក់ព័ន្ធ | ថ្ងៃទី៤- ៧ ខែវិច្ឆិកា ឆ្នាំ២០១៧ | ទីក្រុងវៀងច័ន្ទ ឡាវ |
| | | សិក្ខាសាលាសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ថ្ងៃទី១៣-១៥ ខែធ្នូ ឆ្នាំ២០១៧ | មីយ៉ាន់ម៉ា |
| ៦. | ២០១៨ | សិក្ខាសាលាស្តីពីការបង្កើនការយល់ដឹងស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកិច្ចប្រជុំសម្របសម្រួលរវាង ASEANSAI ជាមួយម្ចាស់ជំនួយ | ថ្ងៃទី១-២ ខែមេសា ឆ្នាំ២០១៨ | ឥណ្ឌូនេស៊ី |
| | | សិក្ខាសាលាវាយតម្លៃស្តីពីសវនកម្មលើកិច្ចលទ្ធកម្មសាធារណៈ | ថ្ងៃទី១៧ -១៩ ខែមេសា ឆ្នាំ២០១៨ | ហ្វីលីពីន |
| | | សិក្ខាសាលាស្តីពីការបង្កើនការយល់ដឹងអំពីឯករាជ្យភាពរបស់ស្ថាប័នសវនកម្មកំពូល | ថ្ងៃទី១៥ -១៧ ខែឧសភា ឆ្នាំ២០១៨ | ថៃ |
| | | កិច្ចប្រជុំបូកសរុបលទ្ធផលសម្រាប់កម្មវិធីរយៈពេលវែងស្តីពីការអនុវត្ត ISSAI | ថ្ងៃទី២២-២៥ ខែកក្កដា ឆ្នាំ២០១៨ | ម៉ាឡេស៊ី |
| | | កិច្ចប្រជុំចាប់ផ្តើមសម្រាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់ASEANSAI ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៨ | ម៉ាឡេស៊ី |
| | | សិក្ខាសាលាស្តីពីការស៊ើបអង្កេតសវនកម្មលើកំហុសចេតនា | ថ្ងៃទី២៧-៣១ ខែសីហា ឆ្នាំ២០១៨ | ឥណ្ឌូនេស៊ី |
| | | កិច្ចប្រជុំសម្រាប់ការរៀបចំឯកសារបណ្តុះបណ្តាលស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ថ្ងៃទី៨-១៧ ខែតុលា ឆ្នាំ២០១៨ | ហ្វីលីពីន |
| | | ចូលរួមសិក្ខាសាលារបស់ ASEANSAI អំពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | ថ្ងៃទី១៩ -២៣ ខែវិច្ឆិកា ឆ្នាំ២០១៨ | ឡាវ |
| | | សិក្ខាសាលាអំពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ IDI-ASEANSAI | ថ្ងៃទី៣-៧ ខែធ្នូ ឆ្នាំ២០១៨ | ឡាវ |
| | | សិក្ខាសាលារួមគ្នារវាងអាស៊ាន ស្ថាប័នសវនកម្មកំពូលអាស៊ាន និងមហាសន្និបាតអន្តរសភាអាស៊ាន | ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ | ឥណ្ឌូនេស៊ី |
| ៧. | ២០១៩ | សិក្ខាសាលាស្តីពីប្រព័ន្ធគ្រប់គ្រងការចែករំលែកចំណេះដឹងរបស់ ASEANSAI | ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៩ | ឥណ្ឌូនេស៊ី |

| | | | | |
|---|---|---|---|---|
| | | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ ASEANSAI លើកទី៥ | ថ្ងៃទី៤-៦ ខែកក្កដា ឆ្នាំ២០១៩ | ឡាវ |
| | | សិក្ខាសាលាស្តីពីការចូលរួមរបស់ម្ចាស់ជំនួយ និងស្ថាប័នសវនកម្មកំពូល | ថ្ងៃទី១៦-១៨ ខែកញ្ញា ឆ្នាំ២០១៩ | ហ្វីលីពីន |
| | | កិច្ចប្រជុំកំពូលរបស់ ASEANSAI លើកទី៥ | ថ្ងៃទី៤-៧ ខែវិច្ឆិកា ឆ្នាំ២០១៩ | ម៉ាឡេស៊ី |
| ៨. | ២០២០ | កិច្ចប្រជុំលើកទី២របស់គណៈកម្មាធិការចែករំលែកចំណេះដឹងរបស់ ASEANSAI | ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២០ | អនឡាញ |
| ៩. | ២០២១ | កិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្ររបស់ASEANSAI | | អនឡាញ |
| | | សិក្ខាសាលាស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ | ថ្ងៃទី២៨-៣០ ខែមិថុនា ឆ្នាំ២០២១ | អនឡាញ |
| | | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ស្ថាប័នសវនកម្មកំពូលអាស៊ានលើកទី៦ | ថ្ងៃទី២៨-២៩ ខែកក្កដា ឆ្នាំ២០២១ | អនឡាញ |
| | | កិច្ចប្រជុំកំពូលរបស់ស្ថាប័នសវនកម្មកំពូលអាស៊ាន លើកទី៦ | | អនឡាញ |

ឯកឧត្តម សួន សិទ្ធី អគ្គសវនករវេង ដឹកនាំគណៈប្រតិភូអ.ស.ជ ចូលរួមកិច្ចប្រជុំកំពូល ASEANSAI លើកទី៣ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅប្រទេសកម្ពុជា

ក្រុមការងាររៀបចំកិច្ចប្រជុំកំពូល ASEANSAI លើកទី៣ នៅប្រទេសកម្ពុជា

កិច្ចប្រជុំកំពូល ASEANSAI លើកទី៤ ថ្ងៃ៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងវៀងច័ន្ទ
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ចូលរួមកិច្ចប្រជុំកំពូលរបស់ASEANSAI លើកទី៥
ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅប្រទេសម៉ាឡេស៊ី

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ និងគណៈប្រតិភូអ.ស.ជ ចូលរួមការដាក់តាំងបង្ហាញសមិទ្ធផលការងារ
របស់អាជ្ញាធរសវនកម្មជាតិ នាកិច្ចប្រជុំកំពូលរបស់ASEANSAI លើកទី៥
ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅប្រទេសម៉ាឡេស៊ី

## ឃ. ស្ថាប័នផ្ដួចផ្ដើមការអភិវឌ្ឍរបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (IDI)

ស្ថាប័នផ្ដួចផ្ដើមការអភិវឌ្ឍរបស់អង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (IDI) គឺជាអង្គភាពមួយរបស់អង្គការ INTOSAI ដែលមាននីតិបុគ្គលដាច់ដោយឡែក ដែលគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នសវនកម្មកំពូល (SAI) ជាចម្បងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

IDI ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៦ ។ ស្ថាប័នសវនកម្មកំពូលនៃប្រទេសកាណាដា ជាអ្នកគ្រប់គ្រង IDI ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ២០០០។ ចាប់តាំងពីឆ្នាំ២០០១ មក ការិយាល័យសវនកម្ម នៃប្រទេសន័រវេសបានទទួលគ្រប់គ្រងស្ថាប័នIDI ដែលត្រូវបានអនុម័តដោយសភាន័រវេស។ IDI នៅប្រទេសន័រវែសត្រូវបានបង្កើតឡើងជាមូលនិធិមួយក្រោមច្បាប់ន័រវែសដែលផ្ដល់នូវឯករាជ្យភាពស្ថាប័ន និងសេដ្ឋកិច្ច។ IDI គឺជាផ្នែកមួយនៃអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) និងធ្វើការរួមគ្នាជាមួយគណៈកម្មាធិការគោលបំណងរបស់ INTOSAI អង្គការក្នុងតំបន់ស្ថាប័នសវនកម្មកំពូល និងដៃគូដទៃទៀតសម្រាប់ឯករាជ្យ អភិបាលកិច្ចល្អ ប្រកបដោយវិជ្ជាជីវៈ និងភាពទាក់ទង SAI។

សម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិបានសហការ និងចូលរួមអនុវត្តសកម្មភាពនានារបស់ IDI មានដូចខាងក្រោម៖

(១) សម្របសម្រួល និងរៀបចំកិច្ចប្រជុំត្រួតពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្រ និងសិក្ខាសាលា ស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រ ដែលបានប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី១០-២១ ខែធ្នូ ឆ្នាំ២០១២ នៅព្រះរាជាណាចក្រកម្ពុជា។

(២) ចូលរួមសិក្ខាសាលា ស្ដីពី 3i Program បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(៣) កម្មវិធីសហប្រតិបត្តិការស្ដីពីសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន ក្រោមការរៀបចំរបស់ IDI និងក្រុមការងារ INTOSAI ស្ដីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា នាខែឧសភា ឆ្នាំ២០១៤។ កម្មវិធីនេះមានរយៈពេលពីឆ្នាំ២០១៤-២០១៦។

(៤) ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំ SAI ជាមួយ IDI ASOSAI និងភាគីពាក់ព័ន្ធចាប់ពីថ្ងៃទី០៩-១១ ខែធ្នូ ឆ្នាំ២០១៥ នៅប្រទេសឥណ្ឌូនេស៊ី។

(៥) កម្មវិធីសហប្រតិបត្តិការ ស្ដីពីកម្មវិធីសវនកម្មសហប្រតិបត្តិការ 3i របស់ ASOSAI IDI ស្ដីពីសវនកម្មលើការគ្រប់គ្រងគ្រោះមហន្តរាយ និងបានចូលរួមវគ្គតាមអនឡាញ ស្ដីពីសវនកម្មលើការគ្រប់គ្រងគ្រោះមហន្តរាយ។

(៦) កម្មវិធីស្ដីពីការធ្វើឱ្យប្រសើរនូវបច្ច័យវិជ្ជមាននៃលទ្ធផលសវនកម្ម។

កម្មវិធីនេះមានគោលបំណងជំរុញបច្ច័យវិជ្ជមាននៃលទ្ធផលសវនកម្ម (Audit Impact) តាមរយៈការលើកកំពស់ទំនាក់ទំនងរវាងស្ថាប័នសវនកម្មកំពូលជាមួយភាគីពាក់ព័ន្ធ ។ ដើម្បីអនុវត្តកម្មវិធីនេះ IDI បានបង្កើត និងផ្ដល់នូវសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងកិច្ចប្រជុំនានា ក្នុងគោលបំណងផ្ដល់ជូនអ្នកចូលរួមទាំងអស់នូវចំណេះដឹង និងបទពិសោធន៍នានាទាក់ទងនឹងការបង្កើតនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ។ អាជ្ញាធរសវនកម្មជាតិបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាស្ដីពីការធ្វើឱ្យប្រសើរនូវបច្ច័យវិជ្ជមាននៃលទ្ធផលសវនកម្ម តាមរយៈការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធសម្រាប់ក្របខណ្ឌ ASOSAI និង PASAI ចាប់ពីថ្ងៃទី២៧ ខែវិច្ឆិកា ដល់ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ។

សិក្ខាសាលានេះមានគ្រូឧទ្ទេសនាមចំនួន ៧ រូប និងអ្នកចូលរួមសរុបចំនួន ៣០ រូប មកពីស្ថាប័នសវនកម្មកំពូលនៃប្រទេស១៦ រួមមាន អាប់កានីស្ថាន កម្ពុជា ប៊ូតាន Cook Islands ឡាវ Guam ម៉ាល់ឌីវ មីយ៉ាន់ម៉ា នេប៉ាល់ ហ្វីលីពីន Papua New Guinea ស្រីលង្កា Samoa តុងកា Tuvalu និង Vanuatu ។

ក្រោយការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាបន្តបន្ទាប់ អាជ្ញាធរសវនកម្មជាតិបានបង្កើត និងដាក់ឱ្យអនុវត្តនូវគោលនយោបាយស្តីពីទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធសម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២១។

(៧)កម្មវិធីសវនកម្មលើកិច្ចប្រតិបត្តិការនៃការត្រៀមលក្ខណៈសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍។

(៨) កម្មវិធីស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការនៃការត្រៀមលក្ខណៈសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

កម្មវិធីនេះត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការចែករំលែកចំណេះដឹង INTOSAI (KSC) INTOSAI Development Initiative (IDI) និងASOSAI ស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការនៃការត្រៀមលក្ខណៈសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (សវនកម្មលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព-Auditing SDGs)។ កម្មវិធីនេះមានរយៈពេលបីឆ្នាំពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ ក្នុងគោលបំណងជួយគាំទ្រដល់ស្ថាប័នសវនកម្មកំពូលក្នុងការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការនៃការត្រៀមលក្ខណៈសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្របតាមបរិបថរបស់ប្រទេសនីមួយៗ។

កម្មវត្ថុនៃការធ្វើសវនកម្មនេះ គឺដើម្បី (១) ថាតើរដ្ឋាភិបាលបានអនុម័តរបៀបវារៈឆ្នាំ២០៣០ ទៅជារបៀបវារៈថ្នាក់ជាតិបានកម្រិតណា (២) តើរដ្ឋាភិបាលបានកំណត់ និងធានានូវធនធាន និងសមត្ថភាព (មធ្យោបាយនៃការអនុវត្ត) ដែលចាំបាច់ដើម្បីអនុវត្តរបៀបវារៈឆ្នាំ២០៣០ និង (៣) តើរដ្ឋាភិបាលបានបង្កើតយន្តការដើម្បីពិនិត្យ តាមដាន ត្រួតពិនិត្យ និងរាយការណ៍អំពីវឌ្ឍនភាពចំពោះការអនុវត្ត នៃរបៀបវារៈឆ្នាំ២០៣០។

អាជ្ញាធរសវនកម្មជាតិបានចូលរួម និងចាត់មន្ត្រីជំនាញចំនួន ៤ រូប ដើម្បីចូលរួមអនុវត្តកម្មវិធីនេះ រួមមាន៖ (១) វគ្គបណ្តុះបណ្តាលតាមអនឡាញ (E-learning) ស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ (២) កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធ នៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ ដើម្បីពិភាក្សាបញ្ហាគន្លឹះនៃសវនកម្មលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងដើម្បីធ្វើការបញ្ជាក់ឡើងវិញចំពោះការប្តេជ្ញាចូលរួមរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ (៣) ក្រុមសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិបានរៀបចំនូវសេចក្តីព្រាងផែនការសវនកម្ម ដោយមានការជួយគាំទ្រពីអ្នកជំនាញរបស់IDI តាមរយៈអនឡាញ (៤) កិច្ចប្រជុំស្តីពីការរៀបចំផែនការសវនកម្ម ដោយផ្តោតទៅលើការប្រមូល និងវិភាគទិន្នន័យ (៥) អនុវត្តការងារសវនកម្មជាក់ស្តែង ដោយមានការជួយគាំទ្រតាមអនឡាញពីអ្នកជំនាញរបស់IDI (៦) រៀបចំសេចក្តីព្រាងរបាយការណ៍សវនកម្ម សម្រាប់ចូលរួមកិច្ចប្រជុំត្រួតពិនិត្យ (៧) កិច្ចប្រជុំត្រួតពិនិត្យគុណភាព ដើម្បីធ្វើការត្រួតពិនិត្យទៅលើសំណេរការងារ និងលទ្ធផលសវនកម្ម។ ជាចុងក្រោយ កម្មវិធីបានរៀបចំចងក្រងនូវបទពិសោធន៍ មេរៀន និងរៀបចំកិច្ចប្រជុំដើម្បីវាយតម្លៃ និងលើកវិធានការឱ្យមានការអនុវត្តប្រកបដោយចីរភាពបន្ទាប់ពីកម្មវិធីនេះ។

លទ្ធផលសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់អាជ្ញាធរសវនកម្មជាតិ និងចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងសិក្ខាសាលាត្រីភាគីលើកទី៨ ក្របខណ្ឌស្ថាប័នសវនកម្មកំពូល កម្ពុជា ឡាវ និងវៀតណាម។

(៩) កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រោមកិច្ចសហប្រតិបត្តិការ និងគាំទ្រថវិកាពី IDI ស្ថាប័នសវនកម្មកំពូលអាស៊ាន(ASEANSAI) បានចាប់ផ្តើមអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (Cooperative Financial Audit) ដែលកម្មវិធីនេះមានរយៈពេលពីរឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩។ គោលបំណងនៃកម្មវិធីនេះ គឺដើម្បីផ្តល់ឱ្យអ្នកចូលនូវចំណេះដឹង និងជំនាញនានាដើម្បីអនុវត្តសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមISSAI។

ក្នុងការចូលរួមកម្មវិធីនេះ អាជ្ញាធរសវនកម្មជាតិបានឯកភាពចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ស្តីពីការប្តេជ្ញាចិត្ត (Statement of Commitment) និងចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨។ លើសពីនេះ អាជ្ញាធរសវនកម្មជាតិបានចាត់តាំងក្រុមសវនកម្មដើម្បីចូលរួមការបណ្តុះបណ្តាលតាមអនឡាញ ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម ISSAI និងបន្តដោយការរៀបចំផែនការសវនកម្ម (ការជ្រើសរើសអង្គភាពរងសវនកម្មដើម្បីអនុវត្តការងារសវនកម្ម) និងចុងក្រោយចូលរួមកិច្ចប្រជុំស្តីពីការរៀបចំផែនការសវនកម្ម ដែលបានរៀបចំនាអំឡុងខែវិច្ឆិកា ឆ្នាំ២០១៨។

ផ្អែកលើកម្មវិធីកិច្ចសហប្រតិបត្តិការនេះ តម្រូវឱ្យមានការត្រួតពិនិត្យគុណភាពសវនកម្ម ដើម្បីផ្តល់នូវការបញ្ជាក់ថាតើ ការអនុវត្តISSAI សម្រាប់សវនកម្មលើរបាយការណ៍សវនកម្មបានអនុវត្តបានកម្រិតណាសម្រាប់ស្ថាប័នសវនកម្មនីមួយៗ ដោយក្នុងនោះ អ្នកជំនាញរបស់ IDI បានចុះមកបំពេញការងារនៅអាជ្ញាធរសវនកម្មជាតិ និងចុងក្រោយបានចេញនូវរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពជូនអាជ្ញាធរសវនកម្មជាតិ។

(១០) កម្មវិធីកិច្ចសហប្រតិបត្តិការ IDI-ASEANSAI ស្តីពីការវាយតម្លៃតម្រូវការការអនុវត្ត ISSAI សម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ។

កម្មវិធីសហប្រតិបត្តិការ IDI ASEANSAI ស្តីពីការវាយតម្លៃតម្រូវការការអនុវត្ត ISSAI សម្រាប់ការផ្តួចផ្តើមសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុបានចាប់ផ្តើមអនុវត្ត តាមរយៈការរៀបចំសិក្ខាសាលាដើម្បីផ្តល់នូវជំនាញ និងឧបករណ៍បច្ចុប្បន្នភាពនៃការវាយតម្លៃការអនុលោមតាមISSAI (Updated iCAT)ដល់ក្រុមការងារក្នុងការអនុវត្តការវាយតម្លៃ។ ក្នុងការចូលរួមកម្មវិធីនេះ អាជ្ញាធរសវនកម្មជាតិបានចាត់តាំងក្រុមការងារដើម្បីចូលរួមសិក្ខាសាលាចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ នៅទីក្រុងបាងកក ប្រទេសថៃ និងចូលរួមអនុវត្តជាបន្តបន្ទាប់ ផ្អែកតាមផែនការសកម្មភាពរបស់កម្មវិធី។

(១១) កម្មវិធីការអប់រំវិជ្ជាជីវៈជូនសវនករនៃស្ថាប័នសវនកម្មកំពូល ។

កម្មវិធីការអប់រំវិជ្ជាជីវៈជូនសវនករនៃស្ថាប័នសវនកម្មកំពូល (Professional Education for SAI Auditors- Pilot ហៅកាត់ថា PESA-P) គឺជាគំនិតផ្តួចផ្តើមការអប់រំប្រកបដោយវិជ្ជាជីវៈដែលមានគោលបំណងបង្កើតអ្នកជំនាញសវនកម្មរបស់ SAI ឱ្យមានសមត្ថភាពដើម្បីបន្ថែមគុណតម្លៃដល់ដំណើរអាជីពរបស់SAI។ PESA-P ផ្តល់នូវឱកាសសម្រាប់ការអប់រំ ការវាយតម្លៃ និងការឆ្លុះបញ្ចាំងរួមជាមួយបទពិសោធន៍ការងារ ផ្តល់ជូននៅក្នុង SAI។ គម្រោងនេះ គឺផ្អែកលើក្របខណ្ឌសមត្ថភាពរបស់ INTOSAI ៖

(i) រួមបញ្ចូលឯកសារទូទៅចំនួនពីរ (cross cutting paper common) សម្រាប់អ្នកចូលរួមទាំងអស់ និងឯកសារចំនួន ៥ សម្រាប់អ្នកចូលរួមម្នាក់លើសវនកម្ម លើការអនុលោមតាមច្បាប់ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្មលើកិច្ចប្រតិបត្តិការ ។

(ii) សវនករដែលបានចុះឈ្មោះក្នុងគំនិតផ្តួចផ្តើម នឹងអាចទទួលបានខ្លឹមសារការអប់រំរយៈពេល ១០០ ម៉ោង (មាតិកាឌីជីថល ការរៀនសូត្រពីសង្គម ធនធានផ្សេងទៀត និងផលប័ត្រអភិវឌ្ឍន៍វិជ្ជាជីវៈដំបូង)។ ការវាយតម្លៃ សមត្ថភាពតាមអ៊ិនធឺណែតចំនួនពីរស្តីពីការបំពេញកាតព្វកិច្ចការអប់រំ និងវិញ្ញាបនបត្រនៃសមត្ថភាពលើការវាយតម្លៃ។

(iii) អ្នកចូលរួមរំពឹងថានឹងបញ្ចប់ការវាយតម្លៃ និងការអប់រំក្នុងរយៈពេល១០ ខែដោយចាប់ផ្តើមពីខែ ឧសភា ឆ្នាំ២០២១ ដល់ខែឧសភា ឆ្នាំ២០២២។

អាជ្ញាធរសវនកម្មជាតិបានចាត់តាំងគ្រូបង្គោល ៤ រូប និងអ្នកចូលរួមសរុប ១១ រូប ដើម្បីចូលរួមកម្មវិធីនេះ។

**ង. ការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត**

អាជ្ញាធរសវនកម្មជាតិ និងការិយាល័យសវនកម្មជាតិនៃប្រទេសស៊ុយអែត (SNAO) បានចុះអនុស្សរណៈនៃការយោគយល់គ្នាកាលពីខែសីហា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ អនុស្សរណៈនេះមានរយៈពេលអនុវត្តរហូតដល់ខែធ្នូ ឆ្នាំ២០១៣ និងបានពន្យារពេលរហូតដល់ឆ្នាំ២០១៤។

ក្រោយអនុស្សរណៈខាងលើត្រូវបានបញ្ចប់ ស្ថាប័នទាំងពីរបានឯកភាពបន្តអនុស្សរណៈដែលបានចុះហត្ថលេខាកាលពីខែមករា ឆ្នាំ២០១៥ ដែលមានសុពលភាពអនុវត្តរហូតដល់ខែធ្នូ ឆ្នាំ២០១៧ និងបានពន្យារពេល ១ ឆ្នាំ រហូតដល់ខែធ្នូ ឆ្នាំ២០១៨។ ចុងក្រោយ ស្ថាប័នទាំងពីរបានព្រមព្រៀងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ដែលមានសុពលភាពសម្រាប់រយៈពេលចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

គម្រោងកិច្ចសហប្រតិបត្តិការ គឺមានបំណងអភិវឌ្ឍន៍សមត្ថភាពរបស់អាជ្ញាធរសវនកម្មជាតិដើម្បីបំពេញមុខងារ និងដើរតួនាទីយ៉ាងមានប្រសិទ្ធភាពនៅក្នុងរដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។ ដើម្បីឈានដល់គោលដៅនេះ អាជ្ញាធរសវនកម្មជាតិគួរអនុវត្តការងារដើម្បីសម្រេចបាននូវគោលដៅរងដូចខាងក្រោម៖

- មានដំណើរការសវនកម្មប្រកបដោយប្រសិទ្ធភាព។
- មានសមត្ថភាព និងចំណេះដឹងដើម្បីរៀបចំរបាយការណ៍សវនកម្មដែលមានគុណភាពខ្ពស់ និងងាយយល់ ។
- មានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។

ក្នុងការសម្រេចឱ្យបាននូវគោលដៅខាងលើ SNAO ជួយគាំទ្ររួមមាន ការបង្កើនសមត្ថភាពសម្រាប់សវនកម្មលើកិច្ចប្រតិបត្តិការ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងការធានាគុណភាពសវនកម្ម។ ដូចនេះ សកម្មភាពត្រូវបានអនុវត្តសម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០២០ មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | បេសកកម្មរបស់អ្នកជំនាញ SNAO នៅអ.ស.ជ | ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ | កិច្ចប្រជុំគណៈកម្មការដឹកនាំរវាងស្ថាប័នទាំងពីរ |
|---|---|---|---|---|
| ១. | ២០១២ | ៣លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | | |
| ២. | ២០១៣ | ៣លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | ១លើក នៅប្រទេសស៊ុយអែត | |

| | | | | |
|---|---|---|---|---|
| ៣. | ២០១៤ | ៥លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | | រាជធានីភ្នំពេញ |
| ៤. | ២០១៥ | ២លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | ១លើក នៅប្រទេសស៊ុយអែត | ទីក្រុងស្តុកខុម |
| ៥. | ២០១៦ | ៦លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | ១លើក នៅប្រទេសស៊ុយអែត | រាជធានីភ្នំពេញ |
| ៦. | ២០១៧ | ៦លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | ១លើក នៅប្រទេសស៊ុយអែត | ទីក្រុងស្តុកខុម |
| ៧. | ២០១៨ | ៦លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | ១លើក នៅប្រទេសកម្ពុជា | រាជធានីភ្នំពេញ |
| ៨. | ២០១៩ | ៦លើក ដើម្បីបង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បង | ២លើក នៅប្រទេសស៊ុយអែត | ទីក្រុងស្តុកខុម |
| ៩. | ២០២០ | ១លើក និង អនឡាញ២លើក | | អនឡាញ |

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ដឹកនាំគណៈប្រតិភូអ.ស.ជ ទស្សនកិច្ច និងចូលរួមកិច្ចប្រជុំគណៈកម្មការដឹកនាំរវាង អ.ស.ជ ជាមួយSNAO ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ នៅទីក្រុងស្តុកខុម ប្រទេសស៊ុយអែត

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ និងគណៈប្រតិភូអាជ្ញាធរសវនកម្មជាតិចូលរួមកិច្ចប្រជុំគណៈកម្មការដឹកនាំ
រវាងស្ថាប័នទាំងពីរ កម្ពុជា ស៊ុយអែត ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ប្រទេសស៊ុយអែត

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ និងលោកជំទាវ Helena Lindberg ចុះអនុស្សរណៈនៃការយោគយល់គ្នា
សម្រាប់គម្រោងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នសវនកម្មទាំងពីរ កម្ពុជា ស៊ុយអែត
ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ នៅទីក្រុងស្តុកខុម ប្រទេសស៊ុយអែត

អ្នកជំនាញSNAO ចែករំលែកបទពិសោធន៍ស្តីពីការធានាគុណភាពសវនកម្មជូនមន្ត្រីជំនាញ
នៃអាជ្ញាធរសវនកម្មជាតិ ថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ នៅអាជ្ញាធរសវនកម្មជាតិ

អ្នកជំនាញSNAO ចែករំលែកបទពិសោធន៍ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ និងសវនកម្មលើព័តមានសមិទ្ធកម្ម
ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអាជ្ញាធរសវនកម្មជាតិ
ថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅអាជ្ញាធរសវនកម្មជាតិ

អ្នកជំនាញSNAO ផ្តល់នូវការបង្ហាត់បង្ហាញស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការជូនមន្ត្រីជំនាញរបស់
អាជ្ញាធរសវនកម្មជាតិ ថ្ងៃទី១៩ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ នៅអាជ្ញាធរសវនកម្មជាតិ

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ និងគណៈប្រតិភូអាជ្ញាធរសវនកម្មជាតិចូលរួមកិច្ចប្រជុំគណៈកម្មការដឹកនាំ
(SCM) រវាងស្ថាប័នទាំងពីរ កម្ពុជា ស៊ុយអែត ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ

លទ្ធផលសំខាន់នៃគម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរសវនកម្មជាតិជាមួយ SNAO មានដូចខាងក្រោម៖

- សៀវភៅណែនាំសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងអនុម័តដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។
- បង្ហាត់បង្ហាញដល់ក្រុមសវនកម្មសាកល្បងលើរបាយការណ៍ហិរញ្ញវត្ថុចំនួន ២៣ ដូចជា ៖
  -ឆ្នាំ២០១២ ចំនួន២៖ ក្រសួងព័ត៌មាន និងសាលាខេត្តកោះកុង ។
  -ឆ្នាំ២០១៣ ចំនួន២៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង សាលាខេត្តកំពត។
  -ឆ្នាំ២០១៤ ចំនួន៦៖ ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាលាខេត្តកោះកុង សាលាខេត្តព្រះសីហនុ សាលាខេត្តកំពង់ស្ពឺ។
  -ឆ្នាំ២០១៥ ចំនួន៤៖ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងក្រសួងសុខាភិបាល។
  -ឆ្នាំ២០១៦ ចំនួន៥៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាខេត្តកែប ភ្នាក់ងារកាំសាប និងសាលាខេត្តកំពង់ធំ។
  -ឆ្នាំ២០១៧ ចំនួន៤៖ គ្រឹះស្ថានបោះពុម្ព និងចែកចាយ សាលាខេត្តត្បូងឃ្មុំ សាលាខេត្តកំពង់ធំ និងសាលាខេត្តកែប។

ការបង្ហាត់បង្ហាញនេះផ្ដោតទៅលើការជ្រើសរើសភាពជាសារវន្ត ការកំណត់ហានិភ័យ បញ្ហាប្រឈមនៃការរៀបចំផែនការ ការរៀបចំផែនការ ការអនុវត្តជាក់ស្ដែង និងការរៀបចំរបាយការណ៍សវនកម្ម។

- សិក្ខាសាលាបណ្ដុះបណ្ដាលរួមបញ្ចូលការបណ្ដុះបណ្ដាលគ្រូបង្គោល។
- សិក្ខាសាលារយៈពេលខ្លីពាក់ព័ន្ធនឹងស្តង់ដារ ISSAI ដល់គ្រូបង្គោលចំនួន៦រូប។
- សិក្ខាសាលាអំពីស្តង់ដារ ISSAI ជូនថ្នាក់ដឹកនាំ អ.ស.ជ និងការបណ្ដុះបណ្ដាលអំពីការធ្វើសវនកម្មប្រើប្រាស់ស្តង់ដារ ISSAI ដល់ក្រុមធានាគុណភាពសវនកម្ម ក៏ដូចជា ការចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលដោយគ្រូបង្គោល។
- បណ្ដុះបណ្ដាលដល់ក្រុមគ្រូបង្គោលសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុចំនួន ១៥ រូប។
- ផ្ដល់ការបង្ហាត់បង្ហាញដល់ក្រុមគ្រូបង្គោលក្នុងការរៀបចំឯកសារបណ្ដុះបណ្ដាលស្ដីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។
- រៀបចំ និងអនុម័តកម្មវិធីបណ្ដុះបណ្ដាលសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។
- ក្រុមការងារត្រួតពិនិត្យ និងធានាគុណភាពត្រូវបានបង្កើតក្នុងឆ្នាំ២០១៤ និងបានទទួលការបណ្ដុះបណ្ដាលពី SNAO ក្នុងការធ្វើ Cold Review លើសវនកម្មសាកល្បង។
- ការធានាគុណភាព បានរៀបចំនីតិវិធីធានាគុណភាពសវនកម្ម ក្នុងនោះបានធ្វើការត្រួតពិនិត្យតាមបែប Cold Review ចំនួន ២ និង Hot Review ចំនួន ៤។
- គោលនយោបាយស្ដីពីការធានាគុណភាពសវនកម្ម និងផែនការយុទ្ធសាស្ត្រស្ដីពីការធានាគុណភាពពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២។
- បង្ហាត់បង្ហាញដល់ក្រុមការងារសាកល្បងរបស់អ.ស.ជ ចំនួន ៥ ក្រុម ស្ដីពីការអនុវត្តការងារសវនកម្មលើកិច្ចប្រតិបត្តិការ ដែលផ្ដោតជាសំខាន់ទៅលើបច្ចេកទេសសម្រាប់រៀបចំផែនការដូចជា៖ភស្តុតាងសវនកម្ម និងការប្រមូលទិន្នន័យ ព្រមទាំងអនុស្សរណៈនៃការសិក្សាដំបូង និងផែនការការងារ ការចុះសវនកម្ម និងរបាយការណ៍សវនកម្ម។

- ការអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ ។
- ឯកសារបណ្តុះបណ្តាលសម្រាប់សវនកម្មលើកិច្ចប្រតិបត្តិការ ការបង្ហាត់បង្ហាញដល់ក្រុមសវនកម្មរបស់អ.ស.ជ អំពីការអនុវត្តសវនកម្មលើកិច្ចប្រតិបត្តិការ និងការធានាគុណភាពសវនកម្ម។

**ច. ការិយាល័យសវនកម្មជាតិសាធារណរដ្ឋប្រជាមានិតចិន**

អាជ្ញាធរសវនកម្មជាតិ និងការិយាល័យសវនកម្មជាតិសាធារណរដ្ឋប្រជាមានិតចិន (CNAO) បានចាប់ផ្តើមចុះអនុស្សរណៈនៃការយោគយល់គ្នាកាលពីខែសីហា ឆ្នាំ២០០៧ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។ ជាបន្តបន្ទាប់ ស្ថាប័នទាំងពីរបានបន្តចុះអនុស្សរណៈកាលពីខែតុលា ឆ្នាំ២០១៣។

អនុស្សារណៈនៃការយោគយល់គ្នានេះមានសុពលភាពសម្រាប់រយៈពេល ៣ ឆ្នាំចាប់ពីកាលបរិច្ឆេទចុះហត្ថលេខា និងត្រូវបានពន្យារដោយស្វ័យប្រវត្តិសម្រាប់រយៈពេល ៣ឆ្នាំទៀត ក្នុងករណីដែលភាគីទាំងពីរពុំបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីគោលបំណង នៃការបញ្ឈប់នូវអនុស្សារណៈនេះឱ្យបានមុនរយៈពេល ៦ខែ នៃកាលបរិច្ឆេទអស់សុពលភាព។

គោលបំណងនៃអនុស្សរណៈ៖

-ការផ្លាស់ប្តូរនូវសៀវភៅ ឯកសារបណ្តុះបណ្តាល និងសៀវភៅណែនាំដែលពាក់ព័ន្ធលើវិធីសាស្ត្រ និងបច្ចេកទេសសវនកម្ម ព្រមទាំងរបាយការណ៍សវនកម្ម។

-ដំណើរទស្សនកិច្ចរវាងភាគីទាំងពីរដោយមិនមានការកំណត់ពេល។

ក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ លទ្ធផលសម្រេចបានសម្រាប់ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៩ មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | ការផ្លាស់ប្តូរដំណើរទស្សនកិច្ច និងសិក្ខាសាលា | ប្រធានបទពិភាក្សា |
|---|---|---|---|
| ១. | ២០១៣ | លោកជំទាវ LI Jianxin អគ្គនាយកសារព័ត៌មាន និងសន្និសីទកាសែត អមដោយសហការីចំនួន ៤ រូបបានបំពេញទស្សនកិច្ចចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២ នៅព្រះរាជាណាចក្រកម្ពុជា | ការគ្រប់គ្រងធនធានមនុស្ស និងការបណ្តុះបណ្តាល |
| ២. | ២០១៤ | លោកស្រី Pang Shufen អគ្គនាយករង និងសហការី៣រូបបានបំពេញទស្សនកិច្ចចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤នៅព្រះរាជាណាចក្រកម្ពុជា | សវនកម្មលើសហគ្រាស និងសវនកម្មលើសំណង់ |
| ៣. | ២០១៥ | ថ្នាក់ដឹកនាំ និងមន្ត្រីអ.ស.ជ ២ រូប បានទៅចូលរួមសិក្ខាសាលា ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ នៅប្រទេសចិន | សវនកម្មសាធារណៈ សវនកម្មលើថវិកាជាតិ សវនកម្មលើកិច្ចប្រតិបត្តិការ |
| ៤. | ២០១៦ | មន្ត្រីអ.ស.ជ ២ រូប បានទៅចូលរួមសិក្ខាសាលា ចាប់ពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៦នៅប្រទេសចិន | ការគ្រប់គ្រងសវនកម្ម ការវិភាគទិន្នន័យ សវនកម្មលើវិស័យកសិកម្ម សវនកម្មលើគម្រោងដោយហិរញ្ញប្បទានពីក្រៅប្រទេស |
| | | មន្ត្រីអ.ស.ជ ២ រូប បន្តការសិក្សាថ្នាក់ក្រោយឧត្តម សិក្សារយៈពេល២ឆ្នាំ នៅប្រទេសចិន | ជំនាញសវនកម្ម |

| | | | |
|---|---|---|---|
| ៥. | ២០១៧ | ឯកឧត្តម Li Xiaozhong អគ្គសវនករងរ CNAO អមដំណើរដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ៥ រូប បានបំពេញទស្សនកិច្ចចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ នៅព្រះរាជាណាចក្រកម្ពុជា | ការត្រួតពិនិត្យគុណភាពសវនកម្ម និងការអនុវត្តស្តង់ដារសវនកម្ម |
| | | មន្ត្រីអ.ស.ជ ២ រូប បានទៅចូលរួមសិក្ខាសាលាចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ នៅប្រទេសចិន | -មុខងារសវនកម្មជាតិ នីតិវិធី និងអាណត្តិសវនកម្មសាធារណៈ<br>-សវនកម្មលើគណនេយ្យភាព និងការបណ្តុះបណ្តាលសវនករ |
| | | មន្ត្រីអ.ស.ជ ១ រូប បន្តការសិក្សាថ្នាក់ក្រោយឧត្តមសិក្សារយៈពេល២ឆ្នាំ នៅប្រទេសចិន | ជំនាញសវនកម្ម |
| ៦. | ២០១៨ | ឯកឧត្តម ឡុង អាទិច្ចបូរា ដឹកនាំមន្ត្រីជំនាញសរុប ២០ រូប ទៅបណ្តុះបណ្តាលចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ នៅប្រទេសចិន | -សវនកម្មលើចំណូលរដ្ឋ<br>-សវនកម្មលើបំណុលសាធារណៈ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធ/វិនិយោគសាធារណៈ<br>-សវនកម្មក្នុងបរិយាសព័ត៌មានវិទ្យា និងសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា។ |
| | | មន្ត្រីអ.ស.ជ ១ រូប បន្តការសិក្សាថ្នាក់ក្រោយឧត្តម សិក្សារយៈពេល២ឆ្នាំ នៅប្រទេសចិន | ជំនាញសវនកម្ម |
| ៧. | ២០១៩ | ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនករងរ អមដោយសហការីចំនួន ១២ រូប បានទៅទស្សនកិច្ចសិក្សា និងចូលរួមសិក្ខាសាលាស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ ចាប់ពីថ្ងៃទី២៧ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅសាធារណរដ្ឋប្រជាមានិតចិន | -សវនកម្មលើធនធាន និងបរិស្ថាន<br>-សវនកម្មនៃការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ<br>-សវនកម្មលើគម្រោងវិនិយោគសាធារណៈ<br>-សវនកម្មលើការសាងសង់ផ្លូវល្បឿនលឿន |
| | | មន្ត្រីអ.ស.ជ ១ រូប បន្តការសិក្សាថ្នាក់ក្រោយឧត្តម សិក្សារយៈពេល២ឆ្នាំ នៅប្រទេសចិន | |

ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការ ដឹកនាំគណៈប្រតិភូអ.ស.ជ  បំពេញទស្សនកិច្ច និងចូលរួមវគ្គបណ្តុះបណ្តាលចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១២ ខែឧសភាឆ្នាំ២០១៨ នៅសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនករងរង ដឹកនាំគណៈប្រតិភូអ.ស.ជ ទស្សនកិច្ចសិក្សា និងចូលរួមសិក្ខាសាលាចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ នៅសាធារណរដ្ឋប្រជាមានិតចិន

ជារួម លទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរបានសម្រេចនូវលទ្ធផលគួរជាទីមោនៈ ដូចនេះ ស្ថាប័នទាំងពីរនឹងបន្តចុះអនុស្សរណៈនៃការយោគយល់គ្នាជាថ្មី។

### ធ. ក្រុមប្រឹក្សាសវនកម្មសាធារណរដ្ឋឥណ្ឌូនេស៊ី

អាជ្ញាធរសវនកម្មជាតិ និងក្រុមប្រឹក្សាសវនកម្មនៃសាធារណរដ្ឋឥណ្ឌូនេស៊ី (BPK) បានចាប់ផ្ដើមចុះអនុស្សរណៈនៃការយោគយល់គ្នាកាលពីខែវិច្ឆិកា ឆ្នាំ២០១០ នៅទីក្រុង Jahannesburg អាហ្វ្រិកខាងត្បូង។ អនុស្សរណៈនេះមានសុពលភាពរយៈពេល២ ឆ្នាំ និងពន្យារពេលដោយស្វ័យប្រវត្តិសម្រាប់រយៈពេល ២ ឆ្នាំបន្តបន្ទាប់ រហូតទាល់តែភាគីណាមួយមានបំណងបញ្ចប់អនុស្សរណៈនេះ។

គោលបំណងនៃអនុស្សរណៈនេះ ៖ គឺដើម្បីផ្ដល់ ពង្រឹង ជំរុញ និងបង្កើតឱ្យមានក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ និងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព រវាងភាគីទាំងពីរក្នុងវិស័យសវនកម្មសាធារណៈ ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា និងមានអត្ថប្រយោជន៍ទៅវិញទៅមក។ ថវិកានៃការអនុវត្តអនុស្សរណៈនេះ គឺផ្អែកលើព្រមព្រៀងគ្នា។ ក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ លទ្ធផលសម្រេចបានសម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០១៩ មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | ការផ្លាស់ប្ដូរដំណើរទស្សនកិច្ច និងសិក្ខាសាលា | ប្រធានបទពិភាក្សា |
|---|---|---|---|
| ១. | ២០១២ | បណ្ឌិត Cris Kuntadi ប្រធានមជ្ឈមណ្ឌលបណ្ដុះបណ្ដាល អមដោយសហការីចំនួន ៣ រូប បានមកបំពេញការងារនៅអាជ្ញាធរសវនកម្មជាតិចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ | ពិភាក្សាលើផែនការនៃគម្រោងកិច្ចសហប្រតិបត្តិការ |
| | | មន្ត្រីជំនាញ ៣ រូប បានផ្ដល់នូវសិក្ខាសាលាចែករំលែកចំណេះដឹងជូនមន្ត្រី អ.ស.ជ ចំនួន ២៥ រូប ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១២ | សិក្ខាសាលាស្ដីពីសវនកម្មកិច្ចប្រតិបត្តិការ |
| | | មន្ត្រីជំនាញ ៣ រូបរបស់ អ.ស.ជ ទៅទស្សកិច្ចសិក្សានៅក្រុមប្រឹក្សាសវនកម្មសាធារណរដ្ឋឥណ្ឌូនេស៊ី | ការគ្រប់គ្រងមជ្ឈមណ្ឌលបណ្ដុះបណ្ដាល |
| ២. | ២០១៣ | គណៈប្រតិភូអាជ្ញាធរសវនកម្មជាតិទស្សនកិច្ចនៅក្រុមប្រឹក្សាសវនកម្មសាធារណរដ្ឋឥណ្ឌូនេស៊ីចាប់ពីថ្ងៃទី២០ ដល់២៤ ខែឧសភា ឆ្នាំ២០១៣ | ពិភាក្សាលើផែនការនៃគម្រោងកិច្ចសហប្រតិបត្តិការ |
| ៣. | ២០១៤ | ក្រុមប្រឹក្សាសវនកម្មសាធារណរដ្ឋឥណ្ឌូនេស៊ីបានបញ្ជូនមន្ត្រីជំនាញ៦ រូប មកអាជ្ញាធរសវនកម្មជាតិ ដើម្បីផ្ដល់នូវសិក្ខាសាលាចែករំលែកចំណេះដឹង ចាប់ពីថ្ងៃទី១៦ ដល់២២ ខែមីនា ឆ្នាំ២០១៤ | សវនកម្មលើបរិស្ថាន សវនកម្មលើកិច្ចប្រតិបត្តិការ និងសវនកម្មលើដំណាំស្រូវ |
| ៤. | ២០១៥ | ក្រុមប្រឹក្សាសវនកម្មសាធារណរដ្ឋឥណ្ឌូនេស៊ីបានបញ្ជូនមន្ត្រីជំនាញ២រូប មកអាជ្ញាធរសវនកម្មជាតិដើម្បីផ្ដល់នូវសិក្ខាសាលាចែករំលែកចំណេះដឹង ចាប់ពីថ្ងៃទី២៧ ដល់៣០ ខែមេសា ឆ្នាំ២០១៥ | សវនកម្មលើបរិស្ថាន |
| ៥. | ២០១៨ | ឯកឧត្តម បណ្ឌិត អគ្គសវនកររង និងមន្ត្រីជំនាញសរុបចំនួន ១៥ រូប បានធ្វើទស្សនកិច្ចសិក្សា ចាប់ | សវនកម្មលើកិច្ចប្រតិបត្តិការ និងការរៀបចំសៀវភៅណែនាំ |

| | | | |
|---|---|---|---|
| | | ពីថ្ងៃទី២ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ នៅប្រទេសឥណ្ឌូនេស៊ី | |
| | | មន្ត្រីអ.ស.ជ ២ រូប បានទៅចូលរួមសិក្ខាសាលា ចាប់ពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៨ នៅប្រទេសឥណ្ឌូនេស៊ី | ក្របខណ្ឌវាយតម្លៃការអនុវត្ត របស់ស្ថាប័នសវនកម្មកំពូល |
| | | លោក Slamet Kurniawan អគ្គនាយក ផែនការ ស្រាវជ្រាវ និងអភិវឌ្ឍន៍ និងសហការី ២ រូបបានមកបំពេញការងារចាប់ពីថ្ងៃទី០៤ ដល់ ០៥ ខែធ្នូ ឆ្នាំ២០១៨ នៅអាជ្ញាធរសវនកម្មជាតិ | ការចែករំលែកបទពិសោធន៍ ទាក់ទងនឹងការតាមដាន និង អនុវត្តអនុសាសន៍សវនកម្ម |
| ៦. | ២០១៩ | គណៈប្រតិភូជាន់ខ្ពស់របស់ក្រុមប្រឹក្សាសវនកម្ម សាធារណរដ្ឋឥណ្ឌូនេស៊ី ដឹកនាំដោយឯកឧត្តម បណ្ឌិត មូលម៉ូហាឌី សូរីយ៉ា ជិនណាការ៉ា ប្រធាន ក្រុមប្រឹក្សា អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ សរុបចំនួន ៦ រូប បានមកធ្វើទស្សនកិច្ចជាផ្លូវការ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែ មេសា ឆ្នាំ២០១៩ នៅព្រះរាជាណាចក្រកម្ពុជា | កិច្ចប្រជុំទ្វេភាគី |
| | | សិក្ខាសាលាចែករំលែកចំណេះនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ នៅអាជ្ញាធរសវនកម្មជាតិ | ការរៀបចំគោលការណ៍ណែនាំ ស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ និងការគ្រប់គ្រងការបណ្តុះបណ្តាល |
| | | ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការ បាន ដឹកនាំគណៈប្រតិភូរបស់ អ.ស.ជ ចូលរួមដំណើរ ទស្សនកិច្ចសិក្សា ចាប់ពីថ្ងៃទី៣០ ខែមេសា ដល់ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៩ នៅសាធារណរដ្ឋ ឥណ្ឌូនេស៊ី | សវនកម្មលើថ្នាក់ក្រោមជាតិ |

ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង ដឹកនាំគណៈប្រតិភូអ.ស.ជ ទស្សនកិច្ចសិក្សានៅក្រុមប្រឹក្សាសវនកម្ម
សាធារណរដ្ឋឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨

ឯកឧត្តម បណ្ឌិត មូលម៉ូហាឌី សូរីយ៉ា ជិនណាកាវ៉ា ប្រធានក្រុមប្រឹក្សា BPK និងគណៈប្រតិភូទស្សនកិច្ចផ្លូវការ
ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ នៅព្រះរាជាណាចក្រកម្ពុជា

ជារួម លទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរបានសម្រេចនូវលទ្ធផលគួរជាទីមោនៈ ដូចនេះ ស្ថាប័នទាំងពីរនឹងបន្តអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា តាមរយៈការពិភាក្សា និងឯកភាពលើផែនការសកម្មភាពរយៈពេល ២ ឆ្នាំ (២០២១ ដល់២០២២)។

**ជ. ស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

អាជ្ញាធរសវនកម្មជាតិ និងស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានចាប់ផ្តើមចុះកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកាលពីខែមេសា ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

កិច្ចព្រមព្រៀងនេះមានសុពលភាពសម្រាប់រយៈពេល ៥ ឆ្នាំចាប់ពីកាលបរិច្ឆេទចុះហត្ថលេខា និងត្រូវបានពន្យារដោយស្វ័យប្រវត្តិសម្រាប់រយៈពេល ៥ឆ្នាំទៀត ក្នុងករណីដែលភាគីទាំងពីរពុំបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីគោលបំណង នៃការបញ្ឈប់នូវកិច្ចព្រមព្រៀងនេះឱ្យបានមុនរយៈពេល ៦ខែ នៃកាលបរិច្ឆេទអស់សុពលភាព។

គោលបំណងនៃកិចព្រមព្រៀងនេះ ៖ គឺដើម្បីផ្តល់ ពង្រឹង ជំរុញ និងបង្កើតឱ្យមានក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ និងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព រវាងភាគីទាំងពីរក្នុងវិស័យសវនកម្មសាធារណៈ ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា និងមានអត្ថប្រយោជន៍ទៅវិញទៅមក។

ក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការនេះ លទ្ធផលសម្រេចបានសម្រាប់ឆ្នាំ ២០១២ ដល់ឆ្នាំ២០២១ មានដូចខាងក្រោម៖

- ស្ថាប័នទាំងពីរបានរៀបចំកិច្ចប្រជុំទ្វេភាគីរវាងថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរ។
- ស្ថាប័នទាំងពីរបានគាំទ្រ និងជួយគ្នាទៅវិញទៅមក ក្នុងអំឡុងពេល អាជ្ញាធរសវនកម្មជាតិ ធ្វើជាប្រធាន ASEANSAI ហើយស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ធ្វើជាអនុប្រធាន ASEANSAI ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។
- រៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការ និងការផ្លាស់ប្តូររវាងអាជ្ញាធរសវនកម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នសវនកម្មរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែធ្នូ ឆ្នាំ២០១៨ និងទិសដៅការងារបន្ត ដើម្បីជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- ស្ថាប័នទាំងពីរបានចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា ឡាវ លើកទី១៣ កាលពីខែកុម្ភៈ ឆ្នាំ២០១៩ នៅប្រទេសឡាវ។
- ស្ថាប័នទាំងពីរមានបំណងបន្តចុះកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នាសារជាថ្មី នាពេលខាងមុខ។

**ឈ. ការិយាល័យសវនកម្មរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

អាជ្ញាធរសវនកម្មជាតិ និងការិយាល័យសវនកម្មរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានចាប់ផ្តើមចុះកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ កាលពីខែឧសភា ឆ្នាំ២០០៨ នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។

កិច្ចព្រមព្រៀងនេះមានសុពលភាពសម្រាប់រយៈពេល ៥ ឆ្នាំចាប់ពីកាលបរិច្ឆេទចុះហត្ថលេខា និងត្រូវបានពន្យារដោយស្វ័យប្រវត្តិសម្រាប់រយៈពេល ៥ឆ្នាំទៀត ក្នុងករណីដែលភាគីទាំងពីរពុំបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីគោលបំណង នៃការបញ្ឈប់នូវកិច្ចព្រមព្រៀងនេះឱ្យបានមុនរយៈពេល ៦ខែ នៃកាលបរិច្ឆេទអស់សុពលភាព។

គោលបំណងនៃកិច្ចព្រមព្រៀងនេះ ៖ គឺដើម្បីផ្តល់ ពង្រឹង ជំរុញ និងបង្កើតឱ្យមានក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ និងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព រវាងភាគីទាំងពីរក្នុងវិស័យសវនកម្មសាធារណៈ ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា និងមានអត្ថប្រយោជន៍ទៅវិញទៅមក។

ក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការនេះ លទ្ធផលសម្រេចបានសម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០២១ មានដូចខាងក្រោម៖

- កិច្ចប្រជុំទ្វេភាគីរវាងថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរកាលពីឆ្នាំ២០១៣។
- ស្ថាប័នទាំងពីរគាំទ្រគ្នាទៅវិញទៅមកក្នុងចូលរួមសកម្មភាព និងដឹកនាំ ASEANSAI ASOSAI។
- គណៈប្រតិភូអាជ្ញាធរសវនកម្មជាតិចំនួន ១៥ រូប ដឹកនាំដោយឯកឧត្តម អគ្គលេខាធិការបានទស្សនកិច្ចសិក្សា និងដកស្រង់បទពិសោធន៍ការងារទាក់ទងនឹងសវនកម្មលើកិច្ចប្រតិបត្តិការ ចាប់ពីថ្ងៃទី១៨ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧នៅការិយាល័យសវនកម្មរដ្ឋនៃប្រទេសវៀតណាម ។
- កិច្ចប្រជុំទ្វេភាគីរវាងថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរតាមរយៈប្រព័ន្ធវីដេអូ នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១។

ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការដឹកនាំគណៈប្រតិភូអ.ស.ជ ទស្សនកិច្ចសិក្សានៅការិយាល័យសវនកម្មរដ្ឋនៃប្រទេសវៀតណាម ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧

កិច្ចពិភាក្សាការងារទ្វេភាគីរវាងថ្នាក់ដឹកនាំនៃអាជ្ញាធរសវនកម្មជាតិជាមួយថ្នាក់ដឹកនាំនៃការិយាល័យសវនកម្មរដ្ឋនៃប្រទេសវៀតណាម នាថ្ងៃ៦ ខែសីហា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូ

### ៣. ការិយាល័យអគ្គសវនករ និងអគ្គត្រួតពិនិត្យនៃសាធារណរដ្ឋឥណ្ឌា

គណៈប្រតិភូស្ថាប័នសវនកម្មកំពូលឥណ្ឌា ដឹកនាំដោយឯកឧត្តម Vinod Rai អគ្គសវនករ និងលោកជំទាវ អមដោយមន្ត្រីជំនាញចំនួន៣ រូប មកទស្សនកិច្ច និងពិភាក្សាការងារស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ចាប់ពីថ្ងៃទី២២-២៥ ខែកុម្ភៈ ឆ្នាំ២០១៣។

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករនៃ អ.ស.ជ ជួបពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្តម Vinod Rai អគ្គសវនករនៃការិយាល័យអគ្គសវនករ និងអគ្គត្រួតពិនិត្យនៃសាធារណរដ្ឋឥណ្ឌា នៅរាជធានីភ្នំពេញ

## ង. សហប្រតិបត្តិការត្រីភាគីក្របខណ្ឌស្ថាប័នសវនកម្មកំពូលកម្ពុជា ឡាវ និងវៀតណាម

ថ្នាក់ដឹកនាំនៃស្ថាប័នសវនកម្មកំពូលកម្ពុជា ឡាវ និងវៀតណាមបានឯកភាពចុះអនុស្សរណៈនៃការយោគយល់គ្នាកាលពីខែមិថុនា ឆ្នាំ២០០៩ ក្នុងគោលបំណងផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ទាក់ទងនឹងសវនកម្មសាធារណៈ។ កិច្ចប្រជុំត្រីភាគីបានចាប់ផ្តើមអនុវត្តចាប់តាំងពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០២១ មានស្ថានភាពដូចខាងក្រោម៖

| ល.រ | កិច្ចប្រជុំត្រីភាគី | កាលបរិច្ឆេទរៀបចំ | ទីកន្លែង | ប្រធានបទពិភាក្សា |
|---|---|---|---|---|
| ១. | លើកទី១ | ខែមិថុនា ឆ្នាំ២០០៩ | វៀតណាម | តួនាទីរបស់ស្ថាប័សវនកម្មកំពូលនៅក្នុងការពង្រឹងប្រសិទ្ធភាពចំណាយសាធារណៈ |
| ២. | លើកទី២ | ខែមិថុនា ឆ្នាំ២០១០ | កម្ពុជា | តួនាទីរបស់ស្ថាប័នសវនកម្មកំពូលក្នុងការជំរុញឱ្យមានអភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ |
| ៣. | លើកទី៣ | ខែសីហា ឆ្នាំ២០១១ | ឡាវ | ការពង្រឹងទំនាក់ទំនងរវាងស្ថាប័នសវនកម្មកំពូល និងរដ្ឋសភា |
| ៤. | លើកទី៤ | ខែមិថុនា ឆ្នាំ២០១២ | វៀតណាម | ការធ្វើឱ្យប្រសើរឡើងនូវគុណភាពរបាយការណ៍សវនកម្មរបស់ស្ថាប័នសវនកម្មកំពូល |
| ៥. | លើកទី៥ | ខែវិច្ឆិកា ឆ្នាំ២០១៣ | កម្ពុជា | ការគ្រប់គ្រងគុណភាពសវនកម្ម |
| ៦. | លើកទី៦ | ខែវិច្ឆិកា ឆ្នាំ២០១៤ | ឡាវ | ការអនុវត្តនូវស្តង់ដារអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល-ISSAI |
| ៧. | លើកទី៧ | ខែវិច្ឆិកា ឆ្នាំ២០១៦ | វៀតណាម | វិធីសាស្ត្រផ្អែកលើហានិភ័យក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ |
| ៨. | លើកទី៨ | ខែវិច្ឆិកា ឆ្នាំ២០១៨ | កម្ពុជា | សវនកម្មលើការត្រៀមលក្ខណៈអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| ៩. | លើកទី៩ | ខែសីហា ឆ្នាំ២០២១ | អនឡាញ | សវនកម្មលើចំណូល តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន |

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករនៃ អ.ស.ជ និងគណៈប្រតិភូនៃស្ថាប័នសវនកម្មកំពូលកម្ពុជា ឡាវ និងវៀត
ណាមចូលរួមកិច្ចប្រជុំត្រីភាគីលើកទី៨ កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៨
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ដឹកនាំគណៈប្រតិភូ អ.ស.ជ ចូលរួមកិច្ចប្រជុំត្រីភាគីលើកទី៩
កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូ

ឋ. សហប្រតិបត្តិការត្រីភាគីកម្ពុជា ឡាវ និងវៀតណាមក្នុងក្របខណ្ឌគណៈកម្មការទី២ នៃរដ្ឋសភា

- បានចូលរួមសិក្ខាសាលារួមគ្នាស្តីពីការពង្រឹងសកម្មភាពត្រួតពិនិត្យរបស់រដ្ឋសភាលើផ្នែកថវិកា និងហិរញ្ញវត្ថុ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៩-១២ ខែមករា ឆ្នាំ២០១២ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- បានចូលរួមសិក្ខាសាលារួមគ្នា ស្តីពីតួនាទីសភា ក្នុងការរៀបចំថវិកាជាតិ៖ ការលើកកម្ពស់ការត្រួតពិនិត្យថវិកាតាមរយៈការពង្រឹងអភិបាលកិច្ចល្អ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៣-០៦ ខែមីនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- បានចូលរួមកិច្ចប្រជុំលើកទី៥ ក្របខណ្ឌគណៈកម្មការរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី១៨-២១ ខែមីនា ឆ្នាំ២០១៤ នៅប្រទេសឡាវ។
- បានចូលរួមកិច្ចប្រជុំលើកទី៦ ក្របខណ្ឌគណៈកម្មការរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី១៦-២០ ខែសីហា ឆ្នាំ២០១៥ នៅប្រទេសវៀតណាម។
- បានចូលរួមសិក្ខាសាលាលើកទី៧ ក្របខណ្ឌគណៈកម្មការទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា សាធារណ រដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី១៣ ដល់១៤ ខែមីនា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ។
- បានចូលរួមសិក្ខាសាលាលើកទី៨ ក្របខណ្ឌគណៈកម្មការទទួលបន្ទុកគណនេយ្យសាធារណៈនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុងហ្លួងព្រះបាង ប្រទេសឡាវ។

### ៧.២.៣ កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

### ក. អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

អាជ្ញាធរសវនកម្មជាតិបានចុះកិច្ចព្រមព្រៀងជាមួយអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់(GIZ) មានដូចខាងក្រោម ៖

- ដំណាក់កាលទី១ ពីខែតុលា ឆ្នាំ២០០៥ ដល់ខែធ្នូ ឆ្នាំ២០០៨
- ដំណាក់កាលទី២ ពីខែមករា ឆ្នាំ២០០៩ ដល់ខែធ្នូ ឆ្នាំ២០១១ ដោយពន្យារដល់ចុងឆ្នាំ២០១២
- ដំណាក់កាលទី៣ ពីខែមករា ឆ្នាំ២០១៣ ដល់ខែធ្នូ ឆ្នាំ២០១៤

ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសអាល្លឺម៉ង់ (GIZ) ជាអ្នកគ្រប់គ្រងគម្រោងផ្ទាល់តាមរយៈការផ្តល់នូវសេវាទីប្រឹក្សា អ្នកជំនាញការ ពិសេសមានប្រធានគ្រប់គ្រងគម្រោងផ្ទាល់ និងសហការីមួយចំនួនប្រចាំនៅអាជ្ញាធរសវនកម្មជាតិ។ ជាគោលការណ៍ ក្នុងអំឡុងពេលអនុវត្តគម្រោងក្នុងដំណាក់កាលនីមួយៗមានការធ្វើការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំស្តីពីការអនុវត្តគម្រោង (Project Progress Review) មុននឹងចុះកិច្ចព្រមព្រៀងសម្រាប់ដំណាក់កាលបន្ទាប់។ ក្រោយឆ្នាំ២០១៤ GIZ បានផ្ទេរពីការគាំទ្រទ្វេភាគីទៅការគាំទ្រថ្នាក់តំបន់វិញ តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ ASEANSAI (GIZ ASEANSAI) ដែលបានចុះហត្ថលេខាកាលពីខែវិច្ឆិកា ឆ្នាំ

២០១៣ ប៉ុន្តែគម្រោងមានទីតាំងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ គម្រោងរបស់GIZ-ASEANSAI បានដំណើរការ និងបានបញ្ចប់នៅឆ្នាំ២០១៩។ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ GIZ បានគាំទ្រសកម្មភាពដូចខាងក្រោម៖

- សិក្ខាសាលាផ្សព្វផ្សាយស្តង់ដារសវនកម្មសាធារណៈ ជូនដល់មន្ត្រីជំនាញរបស់អាជ្ញាធរសវនកម្មជាតិបានចំនួនពីរវគ្គ និង អង្គភាពរងសវនកម្ម។
- សិក្ខាសាលាស្តីពីការតាមដាន និងវាយតម្លៃ (M&E) ចាប់ពីថ្ងៃទី១៧-២១ ខែកញ្ញា ឆ្នាំ២០១២។
- មន្ត្រីជាន់ខ្ពស់ទៅទស្សនកិច្ចសិក្សា ជាមួយតំណាងគណៈកម្មការទី២នៃរដ្ឋសភា និងព្រឹទ្ធសភានៅស្ថាប័នសវនកម្មរដ្ឋ Hassen សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ចាប់ពីថ្ងៃទី១១-១៨ ខែវិច្ឆិកា ឆ្នាំ២០១២។
- សិក្ខាសាលាស្តីពីសវនកម្មលើធនាគារ នៅរាជធានីភ្នំពេញ។
- កុំព្យូទ័រយួរដៃ និងឧបករណ៍ព័ត៌មានវិទ្យាមួយចំនួន។
- បណ្តុះបណ្តាលស្តីពីសវនកម្មលើធនាគារ និងរៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មទៅលើធនាគារកណ្តាល ព្រមទាំងបានបោះពុម្ពគោលការណ៍នេះជាភាសាខ្មែរចំនួន២៥០ ច្បាប់។
- រៀបចំគោលការណ៍ណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងបានបោះពុម្ពគោលការណ៍នេះជាភាសាខ្មែរចំនួន៤៨០ច្បាប់ និងភាសាអង់គ្លេសចំនួន២៨៥ច្បាប់។ លើសពីនេះបានរៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់គោលការណ៍នេះនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤។
- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឯកសារ និងបានបោះពុម្ពគោលការណ៍ណែនាំនេះចំនួន១៧០ ច្បាប់។ លើសពីនេះ បានបំពាក់ឧបករណ៍ (ទូឯកសារ) នៅក្នុងមជ្ឈមណ្ឌលគ្រប់គ្រងឯកសារ។
- ប្រគល់រថយន្តមួយគ្រឿង និងសម្ភារផ្សេងៗរបស់គម្រោងនៅពេលគម្រោងបានបញ្ចប់។
- គាំទ្រទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សម្រាប់គណៈកម្មការទី២នៃព្រឹទ្ធសភា និងអាជ្ញាធរសវនកម្មជាតិដើម្បីស្វែងយល់ពីថវិកាឃុំ សង្កាត់ និងសវនកម្មលើឃុំ សង្កាត់ ចាប់ពីថ្ងៃទី០៨-១៧ ខែតុលា ឆ្នាំ២០១៤។
- សហការរៀបចំកិច្ចប្រជុំបូកសរុបការងារ (Retreat) រវាងអាជ្ញាធរសវនកម្មជាតិ និង GIZ ចាប់ពីថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០១៥។
- សហការរៀបចំកិច្ចប្រជុំត្រួតពិនិត្យឡើងវិញនូវការងារប្រចាំឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០១៥ ជាមួយគម្រោង GiZ ចាប់ពីថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ នៅខេត្តព្រះសីហនុ។
- ជួយការរៀនភាសាអង់គ្លេសរបស់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិ។

ទូរក្សាទុកឯកសារផ្តល់ដោយគម្រោង GiZ

ដោយឡែកឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិ និង GiZ បានសហការ និងទំនាក់ទំនង មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | សកម្មភាព | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ១. | ២០១៧ | លោកជំទាវ អគ្គសវនករ និងជាប្រធាន ASEANSAI បានអនុញ្ញាតឱ្យលោក Alexander Beetz និងសហការីជួបសំដែងការគួរសម និងពិភាក្សាការងារ | | អ.ស.ជ |
| | | លោកជំទាវ អគ្គសវនករ និងជាប្រធាន ASEANSAI បានទទួលជួបពិភាក្សាការងារជាមួយលោក Thomas Waldraff នាយកGiZ ប្រចាំនៅកម្ពុជា | ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ | អ.ស.ជ |
| ២. | ២០១៨ | លោកជំទាវ បណ្ឌិត អគ្គសវនករ បានទទួលជួបប្រជុំជាមួយនាយក GiZ ប្រចាំនៅកម្ពុជា និងប្រធានគម្រោងថ្មី | ថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០១៨ | អ.ស.ជ |
| ៣. | ២០១៩ | លោកជំទាវ បណ្ឌិត អគ្គសវនករ បានទទួលជួប និងពិភាក្សាការងារជាមួយកញ្ញា Birth Meyer ទីប្រឹក្សាគម្រោង ASEANSAI | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៩ | អ.ស.ជ |

| | | | | |
|---|---|---|---|---|
| ៤. | | លោកជំទាវ បណ្ឌិត អគ្គសវនករ បានទទួលជួប និងពិភាក្សាការងារជាមួយលោក Juergen Lehmberg ប្រធានគម្រោង GIZ សម្រាប់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ | ទី២៥ ខែមេសា ឆ្នាំ ២០១៩ | អ.ស.ជ |
| ៥ | ២០២០ | ឯកឧត្តម សួន សិទ្ធី អគ្គសវនកររង បានចូលរួមជាអធិបតីភាពនៃការបើកសិក្ខាសាលាស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិលើការអនុវត្តកិច្ចសន្យាហិរញ្ញវត្ថុ រវាងគម្រោងសម្រាប់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ( GIZ RED IV ) ជាមួយរដ្ឋបាលក្រុង ស្រុកគោលដៅនៃខេត្តព្រះវិហារ ឧត្តរមានជ័យ និងបន្ទាយមានជ័យ | ថ្ងៃទី២២ ខែមករា ឆ្នាំ ២០២០ | ខេត្តសៀមរាប |

លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរសវនកម្មជាតិ

ជារួម សម្រាប់កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរសវនកម្មជាតិមានលទ្ធផលដូចតទៅ៖

- គម្រោងGIZ-ASEANSAIបានប្រគល់សម្ភារៈព័ត៌មានវិទ្យាមួយចំនួនដែលមាននៅក្នុងគម្រោងជូនអាជ្ញាធរសវនកម្មជាតិ ។
- អាជ្ញាធរសវនកម្មជាតិបានអនុវត្ត និងចេញរបាយការណ៍សវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិលើគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (RED IV) ដូចខាងក្រោម៖
  - កិច្ចព្រមព្រៀងលេខ ៨៣៣៤១០០៦ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ ស្តីពីការផ្តល់មូលនិធិហិរញ្ញប្បទានសម្រាប់គម្រោងអភិវឌ្ឍផ្សារសហគមន៍ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។
  - កិច្ចព្រមព្រៀងលេខ ៨៣៣៤៤៧៦៨ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់មូលនិធិហិរញ្ញប្បទានសម្រាប់គម្រោងសាងសង់ទំនប់ដីក្រាលគ្រួសក្រហម និងសំណង់បង្ហៀរទឹក ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
  - កិច្ចព្រមព្រៀងលេខ៨៣៣៤៤៧៤៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់មូលនិធិហិរញ្ញប្បទានសម្រាប់គម្រោងគ្រប់គ្រងកាកសំណល់ និងកែច្នៃដីកំប៉ុស្ត ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។
  - កិច្ចព្រមព្រៀងលេខ៨៣៣៤៤៤៥៨ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់មូលនិធិហិរញ្ញប្បទានសម្រាប់គម្រោងស្តារប្រឡាយ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។
  - កិច្ចព្រមព្រៀងលេខ ៨៣៣៤១៥៧៣ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់មូលនិធិហិរញ្ញប្បទានសម្រាប់គម្រោងស្តារប្រឡាយមេសម្រាប់ប្រព័ន្ធធារាសាស្ត្រស្រោចស្រពផលិតផលស្រូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។
  - កិច្ចព្រមព្រៀងលេខ ៨៣៣៤៣៨២៦ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់មូលនិធិហិរញ្ញប្បទាន សម្រាប់គម្រោងស្តារប្រឡាយស្រោចស្រព និងបង្កើតទ្វារទឹកនិយ័តករ និងដាក់លូមូលទោល មានទ្វារទឹកនិយ័តករ ២កន្លែង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

### ខ. កិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិនៃប្រទេសស៊ុយអែត

ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (Sida) និងសហភាពអឺរ៉ុប (EU) បានចុះកិច្ចព្រមព្រៀងប្រតិភូកម្មលើជំនួយគាំទ្របន្ថែមដល់កម្មវិធីកំណែទម្រង់នៃការគ្រប់គ្រងសាធារណៈ (PFMRP) នៅកម្ពុជា។ ជំនួយគាំទ្របន្ថែម សំដៅទៅលើកម្មវិធីភាពជាដៃគូដើម្បីគណនេយ្យភាព និងតម្លាភាព ដែលបានបំពេញបន្ថែមលើជំនួយគាំទ្រថវិកាដោយផ្ទាល់របស់ EU ចំពោះ PFMRP តាមរយៈការផ្តល់ជំនួយគាំទ្រដល់ស្ថាប័នគោលដៅ ក្នុងគោលបំណងបង្កើតបាននូវបរិយាកាសអំណោយផលសម្រាប់រក្សាសុវត្ថិភាពតំណភ្ជាប់ទៅនឹងរបៀបវារៈ អភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា រួមមាន យុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ការកៀរគចំណូលក្នុងស្រុក ការត្រួតពិនិត្យថវិការបស់សភាជារួម ការត្រួតពិនិត្យផ្ទៃ

ក្រៅតាមរយៈការងារសវនកម្មថ្នាក់ជាតិ និងការពង្រឹងប្រព័ន្ធស្ថិតិ ដែលត្រូវការដើម្បីឱ្យការកំណត់គោលនយោបាយអាទិភាពនៅកម្រិតថ្នាក់ជាតិ និងកម្រិតវិស័យមានភាពសុក្រិត្យ និងផ្តល់ព័ត៌មានគ្រប់គ្រាន់។

អាជ្ញាធរសវនកម្មជាតិ គឺជាភ្នាក់ងារអនុវត្តគម្រោងដែលមានឈ្មោះថា «ពង្រឹងសមត្ថភាពនៅ អ.ស.ជ ឆ្នាំ២០១៦-២០១៩» («គម្រោង CB») លេខវិភាគទាន ៥១១០០១០៣ ក្រោមជំនួយគាំទ្របន្ថែមសម្រាប់សកម្មភាពក្នុងរយៈពេលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ គោលបំណងនៃលទ្ធផលដែលរំពឹងទុកចេញពីគម្រោងកសាងសមត្ថភាពនេះ គឺដើម្បីគាំទ្រ និងសម្រេចឱ្យបាននូវ៖

- បរិយាកាស IT និងអ៊ីនត្រាណេត ដំណើរការ និងគាំទ្រដល់ការប្រាស្រ័យទាក់ទងផ្ទៃក្នុង និងផ្ទៃក្រៅ និងមុខងារចាំបាច់របស់ស្ថាប័ន។
- ការរៀបចំគោលនយោបាយប្រាស្រ័យទាក់ទងផ្ទៃក្រៅ និងការអនុវត្ត ការគ្រប់គ្រងភាគីពាក់ព័ន្ធ។
- ការធ្វើជាប្រធានស្ថាប័នសវនកម្មកំពូលអាស៊ាន (ASEANSAI) ដែលមានវិជ្ជាជីវៈនិងសកម្មសម្រាប់រយៈពេលពីឆ្នាំ២០១៦-២០១៧។
- ផែនការយុទ្ធសាស្ត្ររយៈពេលវែងពីឆ្នាំ២០១៧ ថ្មីមួយសម្រាប់ដឹកនាំការអភិវឌ្ឍ។

ដូចនេះ សកម្មភាពត្រូវបានអនុវត្តសម្រាប់ឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ មានដូចខាងក្រោម៖

| ល.រ | ឆ្នាំ | បេសកកម្មរបស់អ្នកជំនាញ | ទស្សនកិច្ច និងវគ្គបណ្តុះបណ្តាល | ការផ្ញើរបាយការណ៍ជូន Sida | កិច្ចប្រជុំគណៈកម្មការដឹកនាំ |
|---|---|---|---|---|---|
| ១. | ២០១៧ | ៣លើក<br>នៅ អ.ស.ជ | វគ្គបណ្តុះបណ្តាលស្តីពី យេនឌ័រ នៅប្រទេសស៊ុយអ៊ែត | របាយការណ៍ប្រចាំឆ្នាំ២០១៦ នៃការអនុវត្តគម្រោង | |
| | | | គណៈប្រតិភូរបស់ អ.ស.ជ សរុបចំនួន ៦ រូប ទស្សនកិច្ចសិក្សានៅប្រទេសស៊ុយអែត | | |
| ២. | ២០១៨ | ២ លើក<br>នៅ អ.ស.ជ | | របាយការណ៍ប្រចាំឆ្នាំ២០១៧ នៃការអនុវត្តគម្រោង | កិច្ចប្រជុំប្រចាំឆ្នាំ២០១៨ |
| ៣. | ២០១៩ | ៤លើក<br>នៅ អ.ស.ជ | | របាយការណ៍ប្រចាំឆ្នាំ២០១៨ នៃការអនុវត្តគម្រោង | កិច្ចប្រជុំប្រចាំឆ្នាំ២០១៩ |
| ៤. | ២០២០ | | | របាយការណ៍ប្រចាំឆ្នាំ២០១៩ និង របាយការណ៍បញ្ចប់គម្រោង នៃការអនុវត្តគម្រោង | កិច្ចប្រជុំប្រចាំឆ្នាំ២០២០ តាមរយៈ Skype |

លទ្ធផលសម្រេចបាននៃគម្រោងកិច្ចសហប្រតិបត្តិការរួមមាន៖

- ការតម្លើងសម្ភារៈព័ត៌មានវិទ្យាទាំងផ្នែករឹង និងផ្នែកទន់ ឧបករណ៍សម្រាប់រក្សាទុកទិន្នន័យ (Back-up) កម្មវិធីប្រឆាំងមេរោគ កម្មវិធីwindows ការការពារដោយជញ្ជាំងភ្លើង (Firewall) ការរៀបចំឡើងវិញ និងធ្វើបច្ចុប្បន្នភាពគេហទំព័រ។
- ការបណ្តុះបណ្តាលមន្ត្រីដែលមានតួនាទីពាក់ព័ន្ធនឹង ICT ចំនួន០៥រូប អំពីការគ្រប់គ្រងគេហទំព័រ សេវាសារអេឡិកត្រូនិច ព្រមទាំងការភ្ជាប់ និងគ្រប់គ្រងបណ្តាញ។
- គោលនយោបាយ ICT ត្រូវបានរៀបចំ និងអនុម័ត។
- គោលនយោបាយស្តីពីទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ ត្រូវបានរៀបចំ និងអនុម័ត។
- ការរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ASEANSAI នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០១៧។
- ការបោះផ្សាយការចងក្រងឯកសារសម្រាប់អាណត្តិធ្វើជាប្រធាន ASEANSAI។
- សិក្ខាសាលាដំបូងស្តីពីការគ្រប់គ្រងលើការផ្លាស់ប្តូរ ការរៀបចំផែនការ និងការតាមដាន ត្រូវបានរៀបចំសម្រាប់មន្ត្រីគម្រោងរបស់អាជ្ញាធរសវនកម្មជាតិ។
- របាយការណ៍ស្តីពីការវាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។

### គ. ធនាគារអភិវឌ្ឍន៍អាស៊ី

អាជ្ញាធរសវនកម្មជាតិបានចុះកិច្ចព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយទទួលបានជំនួយបច្ចេកទេស តាមរយៈ TA0133 និងTA0222។ លើសពីនេះ កិច្ចព្រមព្រៀងហិរញ្ញប្បទានឆ្នាំ២០១៦-២០១៩រវាងរាជរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី អាជ្ញាធរសវនកម្មជាតិបានចូលរួមអនុវត្ត និងសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បទប្បញ្ញត្តិសម្រាប់ការអនុវត្តច្បាប់ស្តីពីសវនកម្មត្រូវបានដាក់ឱ្យអនុវត្តតាមរយៈនីតិវិធី និងផែនការសវនកម្មប្រចាំឆ្នាំរបស់អាជ្ញាធរសវនកម្មជាតិ។
- ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើការអនុលោមតាមបទប្បញ្ញត្តិ និងសវនកម្មលើកិច្ចប្រតិបត្តិការ។
- ការរៀបចំ និងអនុម័តទៅលើសៀវភៅណែនាំស្តីពីសវនកម្មលើស្រុក ខណ្ឌ និងការអនុវត្តសវនកម្មលើស្រុក ខណ្ឌ ចំនួន ១០។
- ការរៀបចំ និងអនុម័តលើផែនការយុទ្ធសាស្ត្រពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំផ្សព្វផ្សាយលើគេហទំព័ររបស់ អ.ស.ជ។
- របាយការណ៍សវនកម្មប្រចាំឆ្នាំលើការទូទាត់ថវិកាបន្តផ្ញើជូនរដ្ឋសភាក្នុងរយៈពេល ៤ ខែ បន្ទាប់ពីទទួលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផ្សព្វផ្សាយលើគេហទំព័ររបស់ អ.ស.ជ។

ក្រៅពីនេះ ថ្នាក់ដឹកនាំអ.ស.ជ បានជួបពិភាក្សាការងារជាមួយក្រុមបេសកកម្មរបស់ ADB ដូចខាងក្រោម៖

- ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង បានជួបពិភាក្សាការងារជាមួយក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដឹកនាំដោយលោក អ៊ូច ចំរើន និងសហការី កាលពីថ្ងៃទី ៣ ខែតុលា ឆ្នាំ២០១៧។

- ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញបាន ទទួលជួបក្រុមបេសកកម្មវាយតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនករង បានទទួលជួបក្រុមបេសកកម្មរបស់ធនាគាអភិវឌ្ឍន៍អាស៊ី ដឹកនាំដោយលោក អ៊ូច ចំរើន អមជាមួយនឹងលោកស្រី Agustina Musa នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ។

## ឃ. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា

- ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង និងសហការី បានទទួលជួបជាមួយក្រុមវាយតម្លៃឯករាជ្យ(EAP) ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧។
- ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការ និងមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីលទ្ធផលនៃការអនុវត្តសូចនាករសមិទ្ធកម្មរបស់សហភាពអឺរ៉ុបឆ្នាំ២០១៦ និងការរៀបចំក្របខ័ណ្ឌសូចនាករសមិទ្ធកម្មឆ្នាំ២០១៧ នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការ និងសហការីបានទទួលជួបក្រុមការងាររបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការ និងសហការីបានទទួលជួបក្រុមការងាររបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (KICPAA) កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញបាន ទទួលជួបក្រុមការងារវាយតម្លៃការអនុវត្តការគ្រប់គ្រងបំណុលរបស់ធនាគារពិភពលោក កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- លោកជំទាវ អគ្គសវនករ អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញបានទទួលជួបពិភាក្សាការងារជាមួយក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនាថ្ងៃទី១ ខែតុលា ឆ្នាំ ២០១៨ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនកររង អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញបាន ទទួលជួប ក្រុមបេសកកម្មវាយតម្លៃរបស់សហភាពអឺរ៉ុប កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០១៨ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- ឯកឧត្តម អ៊ុក សារាវុធ  អគ្គសវនកររង អមដោយថ្នាក់ដឹកនាំ និងសហការី បានទទួលជួបគណៈប្រតិភូសហភាពអឺរ៉ុប នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៩ នៅ អ.ស.ជ ។
- ឯកឧត្តម ឡុង អាទិច្ចបូរា អគ្គលេខាធិការ បានទទួលជួបពិភាក្សាការងារជាមួយតំណាងប្រតិភូសហភាពអឺរ៉ុប ដឹកនាំដោយលោក Castillo Javier និងលោក Dubbost Sebastien នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ ។

## ៨-ការងាររដ្ឋបាលទូទៅ

## ៨.១.ការគ្រប់គ្រងរដ្ឋបាល

នៅក្នុងរយៈពេល១០ឆ្នាំ អាជ្ញាធរសវនកម្មជាតិបានយកចិត្តទុកដាក់ពង្រឹងការងាររដ្ឋបាល ដើម្បីជំរុញ និងធានានិរន្តរភាពការងាររបស់ស្ថាប័នទាំងមូល។

- បានរៀបចំ និងចរាចរឯកសារផ្សេងៗជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធទាន់ពេលវេលា។
- ចូលរួមថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់ និងសន្តិសុខក្នុងបរិវេណ និងខាងក្រៅជុំវិញ។
- ទំនាក់ទំនង និងសម្របសម្រួលរាល់សកម្មភាពគ្រប់ថ្នាក់ គ្រប់ផ្នែកដែលស្ថិតនៅក្រោមឱវាទអាជ្ញាធរសវនកម្មជាតិ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលឱ្យបានទាន់ពេលវេលា។
- បានសម្របសម្រួលជូនថ្នាក់ដឹកនាំចេញទៅបំពេញបេសកកម្មក្នុង និងក្រៅប្រទេស។
- ចាត់ចែងការងារពិធីការ និងរៀបចំទិវាបុណ្យជាតិ អន្តរជាតិនានា និងពិធីផ្សេងៗទៀត
- បានរៀបចំលិខិតថ្វាយព្រះពរ ជូនពរ ថ្វាយព្រះមហាក្សត្រ និងសម្តេចម៉ែ ព្រមទាំងថ្នាក់ដឹកនាំកំពូលៗ ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ និងពិធីបុណ្យផ្សេងៗទៀត។
- បានចេញសេចក្តីសម្រេចចំនួន ២៧៤លេខ។
- បានរៀបចំ គ្រប់គ្រង និងថែរក្សាឯកសារគ្រប់ប្រភេទរបស់អាជ្ញាធរសវនកម្មជាតិឱ្យមានរបៀបរៀបរយតាមក្បួនខ្នាតបច្ចេកទេសត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសរបាយការណ៍សវនកម្ម និងកម្រងឯកសារសវនកម្ម ដែលមានសារសំខាន់ផ្សេងៗ សម្រាប់ផ្តល់ជូនមន្ត្រីតាមសំណើបានទាន់ពេលវេលា។
- បានស្រាវជ្រាវ និងចងក្រងឯកសារនានាពាក់ព័ន្ធការងារហិរញ្ញវត្ថុពី Internet ។

### ៨.១.១. ស្ថិតិមន្ត្រីរាជការ

ការគ្រប់គ្រងមន្ត្រីរាជការជាការងារគន្លឹះ ជាមួយការអនុវត្តដោយប្រុងប្រយ័ត្ន តាមរយៈឯកសារគតិយុត្តនានាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដែលនាំមកនូវភាពជោគជ័យនៃការងាររបស់ស្ថាប័ន។ អាជ្ញាធរសវនកម្មជាតិគ្រប់គ្រងមន្ត្រីរាជការតាមរយៈ៖

- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។
- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។
- លក្ខន្តិកៈដោយឡែកក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម។
- បទបញ្ជាផ្ទៃក្នុង។
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្ស។
- សៀវភៅពិពណ៌នាការងារ។
- សេចក្តីសម្រេច និងឯកសារគតិយុត្តផ្សេងៗទៀត។
- បានរៀបចំប្រឡងជ្រើសរើសមន្ត្រីថ្មីចំនួន៥៥រូប ចូលបំរើការងារក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ។
- របាយការណ៍បូកសរុបវត្តមានប្រចាំខែ និងប្រចាំឆ្នាំ។

ចាប់តាំងពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១ ស្ថានភាពមន្ត្រីរាជការមានដូចខាងក្រោម៖

| ឆ្នាំ | ចំនួនសរុប | អគ្គសវនករនិង អគ្គសវនកររង | អគ្គលេខាធិការ និងអគ្គលេខាធិការរង | ប្រធាន នាយកដ្ឋាន | ទីប្រឹក្សា | អនុប្រធាន នាយកដ្ឋាន | ប្រធាន ការិយាល័យ | អនុប្រធាន ការិយាល័យ | មន្ត្រី |
|---|---|---|---|---|---|---|---|---|---|
| ២០១២ | ២២៥នាក់ ស្រី៤៧នាក់ | ០៣ | ០៤ | ០៥ | | ១០ | ១៤ | ៤០ | ១៥០ |
| ២០១៣ | ២២៥នាក់ ស្រី៤៨នាក់ | ០៣ | ០៣ | ០៥ | | ១០ | ២០ | ៥២ | ១២៨ |
| ២០១៤ | ២១៤នាក់ ស្រី៤៦នាក់ | ០៣ | ០៣ | ០៥ | | ១០ | ២០ | ៥០ | ១២៣ |
| ២០១៥ | ២០៧ នាក់ ស្រី៤៥នាក់ | ០៣ | ០៥ | ០៥ | | ១២ | ២៣ | ៥១ | ១១០ |
| ២០១៦ | ១៩៦នាក់ ស្រី៤៦នាក់ | ០៣ | ០៥ | ០៦ | | ៣០ | ២៦ | ៥២ | ៧៤ |
| ២០១៧ | ១៩២នាក់ ស្រី៤៧នាក់ | ០៣ | ០៦ | ០៦ | ០៦ | ២៩ | ២៤ | ៥១ | ៧២ |
| ២០១៨ | ២៤៦នាក់ ស្រី៤៨នាក់ | ០៣ | ០៦ | ០៦ | ០៦ | ២៩ | ២៤ | ១០៦ | ៦៨ |
| ២០១៩ | ២៤២នាក់ ស្រី៤៦នាក់ | ០៣ | ០៦ | ០៦ | ០៦ | ២៩ | ២១ | ១០២ | ៦៧ |
| ២០២០ | ២៣៤នាក់ ស្រី៤៥នាក់ | ០៣ | ០៦ | ០៦ | ០៧ | ៣៤ | ២៨ | ៩៣ | ៦៣ |
| ២០២១ | ២៣២នាក់ ស្រី៤៦នាក់ | ០៣ | ០៦ | ០៦ | ០៧ | ៣៤ | ២៨ | ៩២ | ៦៣ |

### ៨.១.២.កម្រិតវប្បធម៌

មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិមានបទពិសោធន៍ និងចំណេះដឹងផ្នែកគណនេយ្យ ហិរញ្ញវត្ថុ សវនកម្ម គ្រប់គ្រង សេដ្ឋកិច្ច ច្បាប់ វិស្វករ និងព័ត៌មានវិទ្យា។

កម្រិតវប្បធម៌របស់មន្ត្រីអាជ្ញាធរសវនកម្មជាតិមានតួលេខ ដូចខាងក្រោម៖

- សញ្ញាបត្របណ្ឌិត ចំនួន ០៦នាក់។
- សញ្ញាបត្រមន្ត្រីជាន់ខ្ពស់ ERA ចំនួន ០៩នាក់។
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់កុំព្យូទ័រ ចំនួន ០២នាក់។
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ១៣៩នាក់ ។
- សញ្ញាបត្របរិញ្ញាបត្រ ចំនួន ៧៥នាក់។
- កម្មករជំនាញ ចំនួន ១នាក់។

### ៨.១.៣.ការលើកទឹកចិត្ត

- ការលើកទឹកចិត្ត គឺជាយុទ្ធសាស្ត្រមួយដ៏សំខាន់បំផុត នៃការគ្រប់គ្រងមន្ត្រី ដើម្បីធ្វើឱ្យកិច្ចប្រតិបត្តិការឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។ កន្លងមក ការលើកទឹកចិត្តមានបីរូបភាព ទី១.ការផ្លាស់ប្ដូរប្រភេទក្របខណ្ឌ និងការដំឡើងថ្នាក់ ទី២.ការផ្តល់គ្រឿងឥស្សរិយយស និងទី៣.ការចាត់បញ្ជូនមន្ត្រីឱ្យទៅសិក្សា ឬទៅធ្វើទស្សនកិច្ចសិក្សានៅបរទេស។ ក្នុងការអនុវត្តគោលការណ៍លើកទឹកចិត្តនេះ អាជ្ញាធរសវនកម្មជាតិផ្តោត

ការយកចិត្តទុកដាក់ជាសំខាន់ ដោយអនុលោមតាមនីតិវិធីនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការជាគោល និងច្បាប់ពាក់ព័ន្ធនានាដែលមានចែងពីការលើកទឹកចិត្តនេះ។

- បានរៀបចំឯកសារដំឡើងកាំបៀវត្សប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ និងមន្ត្រីបានទាន់ពេលវេលា។
- បានរៀបចំឯកសារដំឡើងកាំបៀវត្សតាមកម្រិតសញ្ញាបត្រជូនមន្ត្រីបានទាន់ពេលវេលា។

### ៨.១.៤.ការពង្រឹងសមត្ថភាពស្ថាប័ន

ទន្ទឹមនឹងការខិតខំបំពេញតួនាទីសវនកម្មផ្ទៃក្រៅទទួលបានលទ្ធផលល្អប្រសើរ ថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ នៅមានគោលបំណងសំខាន់បំផុតមួយ គឺការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងនោះទាមទារឱ្យមន្ត្រីមានសមត្ថភាពវិជ្ជាជីវៈពេញលេញ ដើម្បីបំពេញការងារសវនកម្មឱ្យមានគុណភាព ទាន់ពេលវេលា និងជឿទុកចុត្តបាន ឱ្យស្របជាមួយកម្មវិធីអាទិភាព និងកម្មវិធីកែទម្រង់លើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល។

ព្រមជាមួយនេះ អ.ស.ជ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៧-២០២១) និងបន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០២២-២០២៦) ដើម្បីជាត្រីវិស័យក្នុងកិច្ចប្រតិបត្តិការឲ្យទទួលបានជោគជ័យថែមទៀត ព្រមទាំងធ្វើយ៉ាងណាឱ្យអាជ្ញាធរសវនកម្មជាតិ ក្លាយជាស្ថាប័នសវនកម្មកំពូលប្រកបដោយសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងទទួលបានការគាំទ្រពីសាធារណជន និងបង្កើនផលិតភាពនៃមុខងារសវនកម្មផ្ទៃក្រៅរបស់ព្រះរាជាណាចក្រកម្ពុជា ដូចមានបង្ហាញជូនក្នុងរូបភាពដូចខាងក្រោម៖



## ៨.២.ការគ្រប់គ្រងចំណូល ចំណាយថវិកា

តាមច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរសវនកម្មជាតិមានថវិកាដោយឡែករបស់ខ្លួនផ្តល់ដោយថវិកាជាតិ។ ការគ្រប់គ្រងចំណូល និងចំណាយត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ។ ជាមួយនេះ អាជ្ញាធរសវនកម្មជាតិបានអនុវត្តនូវការគ្រប់គ្រងថវិកាក្នុងស្មារតីសន្សំសំចៃ និងប្រកបដោយប្រសិទ្ធភាពស្របតាមលក្ខខណ្ឌបច្ចេកទេសហិរញ្ញវត្ថុ ដូចជា៖

- បានបង្កើតក្រុមការងារសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា។
- បានពិនិត្យពិភាក្សាអំពីលក្ខណៈសម្បត្តិរបស់នាយកដ្ឋាននានាក្រោមឱវាទអាជ្ញាធរសវនកម្មជាតិ ដើម្បីបង្កើតឱ្យទៅជាអង្គភាពថវិកា និងបានសិក្សាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អនុវត្តថវិកាកម្មវិធី។
- បានដាក់ឱ្យអនុវត្តអង្គភាពថវិកា តាមរយៈប្រកាសអន្តរក្រសួង រវាងអាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅឆ្នាំ២០១៧។
- បានបង្កើតក្រុមការងារអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) របស់អាជ្ញាធរសវនកម្មជាតិ នៅឆ្នាំ២០១៩។
- បានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)នៅដើមឆ្នាំ២០២០ សម្រាប់កត់ត្រាកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ នូវមុខងារបី គឺ មុខងារវិភាជន៍ថវិកា មុខងារបញ្ជាទិញ និងមុខងារគណនីត្រូវសង។
- រៀបចំបរិបថនៃប្រតិបត្តិការចំណាយឱ្យស្របតាមប្រព័ន្ធ FMIS។
- បន្តពង្រឹង និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធថវិកាកម្មវិធី។
- បានធ្វើផែនការយុទ្ធសាស្ត្រថវិកា និងធ្វើគម្រោងចំណាយថវិកាប្រចាំឆ្នាំ។
- បានធ្វើកម្មវិធីចំណាយថវិកា ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។
- បានធ្វើរបាយការណ៍ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។
- បានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ស្របតាមផែនការថវិកា។
- បានធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បានធ្វើរបាយការណ៍សរុបទូទាត់ចំណាយថវិកាប្រចាំឆ្នាំ។
- បានធ្វើរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធី ប្រចាំឆមាស និងប្រចាំឆ្នាំ។
- បានអនុវត្តតាមសារាចរណែនាំស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងឆ្នាំ ២០២១។
- បានសម្របសម្រួល និងគាំទ្រផ្នែកហិរញ្ញវត្ថុ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។
- ចូលរួមរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងស្តីពីច្បាប់សវនកម្ម និងស្តង់ដារសវនកម្មដល់សិក្ខាកាមនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បានស្នើសុំថវិកាសាងសង់អគារ១ខ្នង សម្រាប់ធ្វើជាវិទ្យាស្ថានជាតិសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ និងបានសាងសង់រួចរាល់នៅចុងឆ្នាំ២០២០។

## ៨.៣.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

អាជ្ញាធរសវនកម្មជាតិបានរៀបចំកិច្ចការមួយចំនួន ក្នុងស្មារតីជានារក្សាការពារ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតនៅក្រោមការគ្រប់គ្រង និងប្រើប្រាស់របស់ខ្លួនស្របតាមវិធាន និងនីតិវិធី នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចមានខាងក្រោម៖

- ប្រមូលផ្តុំតម្រូវការ និងបែងចែកសម្ភារការិយាល័យ ប្រេងឥន្ធនៈ និងធ្វើរបាយការណ៍បញ្ចូល-បញ្ចេញប្រចាំខែ និងប្រចាំឆ្នាំ។
- គ្រប់គ្រង និងប្រើប្រាស់ចលនទ្រព្យ អចលនទ្រព្យ ថែទាំជួសជុលឧបករណ៍ សម្ភារបរិក្ខារ សម្ភារព័ត៌មានវិទ្យា រថយន្ត អគារទីស្តីការអាជ្ញាធរសវនកម្មជាតិ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- បានធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះ ក្នុងឆ្នាំនីមួយៗ និងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល សម្រាប់ឆ្នាំ២០១៩។
- បានរៀបចំបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរសវនកម្មជាតិក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) ចាប់ពីឆ្នាំ២០២១។

## ៨.៤.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តចង្កោមសកម្មភាព និងសូចនាករគន្លឹះសមិទ្ធកម្មនៃផែនការសកម្មភាពរួមប្រចាំឆ្នាំនីមួយៗ ព្រមទាំងអនុវត្តបានចំនួន១១០ចង្កោមសកម្មភាព និងបានអនុវត្តនូវការងារសំខាន់ៗមួយចំនួនទៀត រួមមាន៖

- របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ (Performance Audit) ត្រូវបានធ្វើជូនរដ្ឋសភា ព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន៣របាយការណ៍ក្នុងឆ្នាំ២០១៨, ចំនួន៤របាយការណ៍ក្នុងឆ្នាំ២០១៩ និងចំនួន៥របាយការណ៍ក្នុងឆ្នាំ២០២០
- បានរៀបចំសៀវភៅណែនាំស្តីពីការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ។
- បានរៀបចំសៀវភៅណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិលើក្រុង ស្រុក ខណ្ឌ។
- បានធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។
- បានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។
- បានរៀបចំកម្មវិធីសវនកម្មលើការប្រមូលចំណូលពន្ធដារ និងពន្ធគយ។
- បានរៀបចំកម្មវិធី និងឯកសារបណ្តុះបណ្តាលស្តីពីសវនកម្មលើកិច្ចប្រតិបត្តិការ។
- បានធ្វើសវនកម្មលើការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ចំនួន ៤ក្រសួង។
- បានរៀបចំបទបង្ហាញស្តីពីសៀវភៅណែនាំសវនកម្មលើធនាគារកណ្តាល។
- បានសិក្សា និងចងក្រងគោលការណ៍រួមលើការអនុវត្តន៍អនុសាសន៍សវនកម្មផ្ទៃក្រៅ។
- លើកកម្ពស់ការយល់ដឹងស្តីពីច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារ

សវនកម្មសាធារណៈ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយនៅតាមបណ្តាខេត្តនានា។
– ផ្សព្វផ្សាយ និងណែនាំស្តីពីបែបបទរដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស និងការកសាងសមត្ថភាពមន្ត្រីផ្នែក FMIS តាមរយៈសិក្ខាសាលា និងការបណ្តុះបណ្តាល។

ឯកឧត្តម អ៊ុក សារាវុធ អគ្គសវនករចូលរួមពិធីបើកវគ្គបណ្តុះបណ្តាល
ស្តីពី FMIS ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ រាជធានីភ្នំពេញ

វគ្គបណ្តុះបណ្តាលស្តីពី FMIS ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ រាជធានីភ្នំពេញ

### ៩. ការធានាគុណភាពសវនកម្ម

ក្នុងគោលដៅពង្រឹងនូវគុណភាពការងារសវនកម្ម និងការអនុលោមតាមស្តង់ដារសវនកម្មទូទៅ អាជ្ញាធរសវនកម្មជាតិបានសម្រេចបង្កើតនូវក្រុមការងារត្រួតពិនិត្យការធានាគុណភាពសវនកម្មនៅ ក្នុងឆ្នាំ២០១៣។ ក្រុមការងារនេះបានទទួលនូវការបណ្តុះបណ្តាលអំពីវិធីសាស្ត្រនៃការត្រួតពិនិត្យគុណភាពពីអ្នកជំនាញ នៃការិយាល័យសវនកម្មជាតិស៊ុយអែត។ អ.ស.ជ បានរៀបចំគោលការណ៍ស្តីពីការធានាគុណភាពសវនកម្ម និងបានត្រួតពិនិត្យគុណភាពការងារសវនកម្មរបស់ក្រុមសវនកម្មសាកល្បងលើរបាយការណ៍ហិរញ្ញវត្ថុមួយចំនួនទៅតាមផែនការប្រចាំរបស់ខ្លួន ដោយប្រើប្រាស់តារាងគំរូ (Template) ដែលត្រូវបានរៀបចំផ្អែកតាមស្តង់ដារសវនកម្មសម្រាប់ធ្វើការត្រួតពិនិត្យ។ នៅក្នុងឆ្នាំ២០១៦ គោលការណ៍ស្តីពីការធានាគុណភាពសវនកម្មត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងអាជ្ញាធរសវនកម្មជាតិ។ លើសពីនេះ អាជ្ញាធរសវនកម្មជាតិបានបង្កើតនូវឯកសារជាយុទ្ធសាស្ត្រមួយចំនួន រួមមាន៖ (១) គោលនយោបាយនៃការធានាគុណភាព (២) ផែនការយុទ្ធសាស្ត្រនៃការធានាគុណភាពសម្រាប់ឆ្នាំ ២០២០-២០២២ និង (៣) ផែនការធានាគុណភាពប្រចាំឆ្នាំ ។

## II- លទ្ធផលការងារសវនកម្ម

### ១-លទ្ធផលសវនកម្មតាមសំណើរបស់ក្រសួង ស្ថាប័ន

### ១.១ សវនកម្មតាមសំណើរបស់សាលាឧទ្ធរណ៍

អាជ្ញាធរសវនកម្មជាតិបានធ្វើបដិសវនកម្មលើរបាយការណ៍សវនកម្មរបស់លោក កាក់ កី យោងតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ មាត្រា ៣ ចំណុច ច "សវនកម្មតាមសំណើពិសេស" និងលិខិតលេខ២០៦រប៩.២០១៣ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍។ ការធ្វើបដិសវនកម្មលើរបាយការណ៍សវនកម្មរបស់លោក កាក់ កី គឺជាការធ្វើសវនកម្មឡើងវិញ ដោយផ្តោតជាសំខាន់ទៅលើភាពត្រឹមត្រូវនៃចរន្តទឹកប្រាក់ចេញ និងចូលក្នុងគណនី ធនាគារដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ១០១៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍សម្រាប់ការិយបរិច្ឆេទ២០០១ រហូតដល់២០១០ ដោយអនុលោមទៅតាមច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរសវនកម្មជាតិបានបញ្ចប់ការធ្វើបដិសវនកម្មដោយជោគជ័យ ដោយបានចេញនូវរបាយការណ៍សវនកម្មរបស់ខ្លួនសម្រាប់ជាមូលដ្ឋានជូនដល់សាលាឧទ្ធរណ៍ក្នុងការសម្រេចក្តីលើសំណុំរឿងព្រហ្មទណ្ឌលេខ១០១៨ នេះ។

### ១.២ សវនកម្មតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានទទួលសំណើសុំបន្តអនុស្សរណៈនៃការយោគយល់គ្នាពីអង្គការមិនមែនរដ្ឋាភិបាលបរទេសចំនួន ៥ អង្គការ។ តាមរយៈការពិនិត្យលើឯកសារស្នើសុំទាំងនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិយល់ឃើញថា អង្គការទាំងនេះស្ថិតក្នុងករណីសង្ស័យធ្វើសកម្មភាពទាញយកប្រាក់ចំណេញដែលផ្ទុយនឹងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ជាមួយនឹងមូលហេតុនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានធ្វើសំណើមកអាជ្ញាធរសវនកម្មជាតិ តាមរយៈលិខិតលេខ ៨១៣៤ អជ.កបទ.សអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីសំណើសុំចុះត្រួតពិនិត្យ និងធ្វើសវនកម្មលើអង្គការមិនមែនរដ្ឋាភិបាលបរទេសទាំងនោះ។

យោងតាមលិខិតខាងលើ និងយោងតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរ

សវនកម្មជាតិបានធ្វើសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅអង្គការចំនួន៥ រួមមាន អង្គការ JRFC-WAFC Formation et Progrès-Cambodge, Friends International, CAMBODIAN-GERMAN CULTURAL ASSOCIATION ( KDKG e.v ) និង SALASUSU សម្រាប់ការិយបរិច្ឆេទ២០១៧-២០២០។

តាមការធ្វើសវនកម្មលើអង្គការទាំងនេះ អាជ្ញាធរសវនកម្មជាតិ បានពិនិត្យឃើញថា អង្គការបានខិតខំអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាការចុះបញ្ជីពន្ធដារ ការដាក់លិខិតប្រកាសពន្ធ ការរៀបចំនូវរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុគម្រោងរបស់អង្គការ ព្រមទាំងបានអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត។ ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិក៏បានកត់សម្គាល់នូវចំណុចសំខាន់ៗមួយចំនួនដែលអង្គការគួរធ្វើការកែលម្អដូចជា៖ ការធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនទាន់សមស្រប, កង្វះខាតក្នុងការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីធនាគារ, កង្វះខាតក្នុងការភ្ជាប់សំណុំឯកសារសម្រាប់ស្នើសុំបន្តអនុស្សរណៈនៃការយោគយល់គ្នា, កង្វះខាតក្នុងការជូនដំណឹងពីការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលិកបរទេស និងបុគ្គលិកក្នុងស្រុក, កង្វះខាតឯកសារបញ្ជាក់ប្រភពចំណូលមួយចំនួន, កង្វះខាតក្នុងការគ្រប់គ្រងគណនីធនាគារ និងសាច់ប្រាក់, ការគ្រប់គ្រងអចលនទ្រព្យនៅមានកម្រិត, កង្វះខាតក្នុងការបង់ពន្ធកាត់ទុកលើការទូទាត់កម្រៃសេវាសវនកម្ម, កង្វះខាតក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ, កង្វះខាតក្នុងការដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ, កង្វះខាតការរៀបចំបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ, ប្រភពចំណូលរបស់អង្គការ ដែលមិនបានស្នើសុំ និងទទួលបានការលើកលែងពន្ធ, កង្វះខាតកាតព្វកិច្ចសារពើពន្ធលើចំណូលផ្សេងៗ, ការមិនប្រកាសពន្ធពីចំណូលភោជនីយដ្ឋាន និងចំណូលផ្សេងទៀត, ការមិនប្រកាសពន្ធកាត់ទុកលើសេវាកម្ម, ទំនាស់ផលប្រយោជន៍, ការអនុញ្ញាតឱ្យបើកភោជនីយដ្ឋានពុំបានអនុលោមតាមច្បាប់, កង្វះខាតក្នុងការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ, កង្វះខាតក្នុងការស្នើសុំកំណត់ការិយបរិច្ឆេទគណនេយ្យ, ការពុំបានកត់ត្រាបង្ហាញរបាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរ និងគិតជាប្រាក់រៀល ជាដើម។

ជាមួយនឹងសវនកម្មលើអង្គការទាំងនេះ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់អង្គការបានសហការល្អជាមួយប្រតិភូសវនកម្ម ដូចជាការផ្តល់ឯកសារ និងការជួបសម្ភាសន៍ ប៉ុន្តែទោះជាយ៉ាងណានៅអំឡុងពេលចុះប្រមូលព័ត៌មានចុះអនុវត្តសវនកម្មជាក់ស្តែង និងរៀបចំរបាយការណ៍សវនកម្មប្រតិភូសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ បានជួបប្រទះទៅនឹងបញ្ហាប្រឈម និងទទួលបានបទពិសោធន៍មួយចំនួនដូចខាងក្រោម៖

- ទីស្នាក់ការរបស់អង្គការនៅភ្នំពេញមានចំងាយឆ្ងាយពី អ.ស.ជ និងម៉ោងបំពេញការងារខុសពីម៉ោងការងាររបស់រដ្ឋ។
- ការរីករាលដាលជំងឺកូវីដ-១៩ ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ បានប៉ះពាល់ដល់ការអនុវត្តការងារសវនកម្ម (ការពិភាក្សាត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ និងអ៊ីម៉ែល) និងធ្វើឱ្យមានការយឺតយ៉ាវលើការឆ្លើយបំភ្លឺលើរបាយការណ៍សវនកម្ម។
- ការពន្យារពេលក្នុងការចេញរបាយការណ៍ការចុងក្រោយដោយសារវិធានការបិទខ្ទប់ជាដើម។
- ទទួលបានបទពិសោធន៍ថ្មីក្នុងការធ្វើសវនកម្មតាមរយៈអនឡាញជាដើម។

## ២-សកម្មភាពចុះធ្វើសវនកម្ម ឆ្នាំ២០១២-២០២១

ក្នុងរយៈពេល១០ឆ្នាំ (២០១២-២០២១) អាជ្ញាធរសវនកម្មជាតិបានចុះធ្វើសវនកម្ម និងចេញរបាយការណ៍សវនកម្មចំនួន ៦៥៤ មានដូចខាងក្រោម៖

**<u>តារាងទី៥៖ សេចក្ដីសង្ខេបចំនួនសវនកម្មដែលអនុវត្តចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១</u>**

| ល.រ | មុខសញ្ញាសវនកម្ម | ឆ្នាំ | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | |
| ១ | សេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកា | 01 | 01 | 01 | 01 | 01 | 01 | 01 | 01 | 01 | 01 | 10 |
| ២ | ក្រសួង ស្ថាប័ន | 06 | 09 | 10 | 10 | 10 | 12 | 10 | 14 | 19 | 13 | 113 |
| ៣ | អាជ្ញាធរនិងធនាគារ | 02 | 03 | 02 | 03 | 02 | 04 | 01 | 06 | 04 | 04 | 31 |
| ៤ | សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ | 06 | 08 | 07 | 08 | 09 | 13 | 03 | 15 | 13 | 12 | 95 |
| ៥ | រាជធានី ខេត្ត | 07 | 07 | 14 | 11 | 16 | 20 | 16 | 21 | 24 | 25 | 161 |
| ៦ | ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 15 | 25 | 15 | 20 | 18 | 19 | 30 | 13 | | 10 | 165 |
| ៧ | កិច្ចសន្យាសម្បទាន (វិនិយោគ) | 06 | 05 | 06 | 01 | 06 | 03 | 03 | 04 | 04 | | 43 |
| ៨ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | 01 | 05 | 05 | 01 | 01 | | | | 06 | | 20 |
| ៩ | សវនកម្មលើកិច្ចប្រតិបត្តិការ | | | | | | | 04 | 04 | 05 | 05 | 16 |
| ១០ | សវនកម្មសំណើពិសេស | | 01 | | | | | | | | 05 | 06 |
| | សរុប | 44 | 63 | 60 | 55 | 63 | 72 | 68 | 78 | 77 | 75 | 654 |

**<u>តារាងទី៦៖ លទ្ធផលនៃប្រតិបត្តិការសវនកម្មតាមបណ្ដាអង្គភាពរងសវនកម្ម (២០១២-២០២១)</u>**

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| **ឆ្នាំ២០១២** | | <u>៤៤</u> | |
| ១ | សេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ | ០១ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ០៦ | – ក្រសួងធនធានទឹក និងឧតុនិយម<br>– ក្រសួងព័ត៌មាន<br>– ក្រសួងផែនការ<br>– ក្រសួងទេសចរណ៍<br>– ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>– រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ០២ | – អាជ្ញាធរអប្សរា<br>– អាជ្ញាធរអគ្គិសនីកម្ពុជា |
| ៤ | សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ | ០៦ | – រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>– កំពង់ផែស្វយ័តក្រុងភ្នំពេញ<br>– ក្រុមហ៊ុនហ្គ្រីនត្រេដ<br>– សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>– វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា<br>– ប្រៃសណីយ៍កម្ពុជា |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ០៧ | – ខេត្តកំពង់ធំ<br>– ខេត្តព្រះសីហនុ<br>– ខេត្តសៀមរាប<br>– ខេត្តកំពង់ឆ្នាំង<br>– ខេត្តបន្ទាយមានជ័យ<br>– ខេត្តកំពង់ស្ពឺ<br>– ខេត្តតាកែវ |
| ៦ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ១៥ | – ឃុំចំនួន០៥នៃខេត្តកំពង់ធំ<br>– ឃុំចំនួន០៥នៃខេត្តព្រះសីហនុ<br>– ឃុំចំនួន០៥នៃខេត្តសៀមរាប |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០១ | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សហគមន៍ខ្នាតតូចនៅតំបន់ទន្លេសាប លេខ 0186-CAM(SF) របស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៨ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០៦ | – កិច្ចសន្យាសម្បទានវិនិយោគរវាងក្រសួងសាធារណការនិងដឹកជញ្ជូនជាមួយក្រុមហ៊ុនឌូជីហ្វ្រីសប់ចំកាត់ស្តីពីការសាងសង់ស្ពានបេតុងអាមេកាត់ព្រែកកោះប៉ោ ស្រុកដងទង់ខេត្តកោះកុង (BOT)<br>– កិច្ចព្រមព្រៀងសម្បទានរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនអេហ្សិត |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពទទួលសវនកម្ម |
|---|---|---|---|
| | | | ឱស្ស្រីឫស្សីប្បុហ្សិន ស្តីពីការចាត់ចែងជួសជុល និងថែទាំផ្លូវជាតិលេខ៤<br>–កិច្ចសន្យាសម្បទានវិនិយោគរបស់ក្រុមហ៊ុនវិនិយោគដែលប្រើប្រាស់ទីតាំងរបស់រដ្ឋ និងទទួលបានការលើកទឹកចិត្ត ដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ៖<br>• Manhattan Textiles & Garment<br>• Cambodian WS Mining Industry Holding Limited<br>• SL Garment Ppocessing Co.,Ltd & YungWah Industrial ( Cambodia ) Co.,Ltd |
| **ឆ្នាំ២០១៣** | | **៦៣** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ០៩ | – ក្រសួងយុត្តិធម៌<br>– ក្រសួងធម្មការ និងសាសនា<br>– ក្រសួងកិច្ចការនារី<br>– ក្រសួងសាធារណការ និងដឹកជញ្ជូន<br>– ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>– ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>– ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>– ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>– ក្រសួងអប់រំ យុវជន និងកីឡា |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ០៣ | – អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍<br>– អាជ្ញាធរអគ្គិសនីកម្ពុជា<br>– ធនាគារអភិវឌ្ឍន៍ជនបទ |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៨ | – ភ្នាក់ងារកម្ពុជានាវាចរ ( កាំសាប )<br>– បេឡាជាតិរបបសន្តិសុខសង្គម |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពទទួលសវនកម្ម |
|---|---|---|---|
| | | | – កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>– រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប<br>– សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>– មន្ទីរពេទ្យកុមារជាតិ<br>– សាលាកសិកម្មព្រែកលាប<br>– ទូរគមនាគមន៍កម្ពុជា |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ០៨ | – ខេត្តមណ្ឌលគិរី<br>– ខេត្តកំពត<br>– ខេត្តឧត្តរមានជ័យ<br>– រាជធានីភ្នំពេញ<br>– ខេត្តបាត់ដំបង<br>– ខេត្តស្ទឹងត្រែង<br>– ខេត្តកែប |
| ៦ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ឃុំ-សង្កាត់ | ២៥ | – ឃុំ-សង្កាត់ចំនួន០៥ នៃខេត្តមណ្ឌលគិរី<br>– ឃុំ-សង្កាត់ចំនួន០៥ នៃខេត្តកំពត<br>– ឃុំ-សង្កាត់ចំនួន០៥ នៃខេត្តឧត្តរមានជ័យ<br>– ឃុំ-សង្កាត់ចំនួន០៥ នៃខេត្តបាត់ដំបង<br>– សង្កាត់ចំនួន០៥ នៃរាជធានីភ្នំពេញ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៥ | – គម្រោងStrengthening Technical and Vocational Education លេខ 0178-CAM(SF) នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>– គម្រោងBiodiversity Conservation Corridor លេខ0241-CAM(SF) នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>– គម្រោងអភិវឌ្ឍន៍ជនបទនៅទំនាបតំបន់ទន្លេសាបលេខ0092-CAM(SF) និង 2376-CAM(SF)<br>– គម្រោងស្តារឡើងវិញផ្លូវដែកប្រទេសកម្ពុជាលេខ2288-CAM(SF)<br>– គម្រោង Enhancing Education Quality លេខ0090-CAM (SF) នៅក្រសួងអប់រំ យុវជន និងកីឡា |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
| --- | --- | --- | --- |
| ៨ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០៥ | – កិច្ចសន្យាសម្បទានវិនិយោគមជ្ឈមណ្ឌលផ្សារអូឡាំពិករបស់សាលារាជធានី<br>– កិច្ចសន្យាសម្បទានវិនិយោគផ្លូវចោមចៅ-ស្ទឹងមានជ័យរបស់សាលារាជធានី<br>– កិច្ចសន្យាសម្បទានប្រព័ន្ធត្រួតពិនិត្យជើងហោះហើររបស់ក្រុមហ៊ុនCATs<br>– កិច្ចសន្យាសម្បទានវិនិយោគផ្សារអន្តរប៉ោយប៉ែតរបស់សាលាខេត្តបន្ទាយមានជ័យ<br>– រោងចក្រកាត់ដេរ UNITED FAITH GARMENT FACTORY Co.Ltd (ធ្វើសវនកម្មលើពន្ធជាបន្ទុករបស់រដ្ឋទាក់ទងនឹងវិនិយោគកាត់ដេរ) |
| ៩ | សវនកម្មតាមសំណើពិសេស | ០១ | ការធ្វើបដិសវនកម្មលើរបាយការណ៍សវនកម្មដែលមានក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ: ១០១៨ ចុះថ្ងៃទី ២៥-១០-២១២ របស់សាលាឧទ្ធរណ៍ |
| **ឆ្នាំ២០១៤** | | **៦០** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ១០ | – ក្រសួងព័ត៌មាន<br>– ក្រសួងផែនការ<br>– ក្រសួងសុខាភិបាល<br>– ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>– ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>– ក្រសួងពាណិជ្ជកម្ម<br>– ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>– ក្រសួងធនធានទឹក និងឧតុនិយម<br>– ក្រសួងមុខងារសាធារណៈ<br>– ក្រសួងទេសចរណ៍ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ០២ | – អាជ្ញាធរអគ្គិសនីកម្ពុជា<br>– ធនាគារជាតិនៃកម្ពុជា |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៧ | – មន្ទីរពេទ្យកាល់ម៉ែត្រ<br>– សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច<br>– មន្ទីរពេទ្យព្រះកុសមៈ(TeamMate)<br>– វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (TeamMate)<br>– គ្រឹះស្ថានបោះពុម្ពផ្សាយ(TeamMate)<br>– ទូរគមនាគមន៍កម្ពុជា (សវនកម្មសាកល្បង)<br>– កំពង់ផែស្វយ័តក្រុងភ្នំពេញ(សវនកម្មសាកល្បង) |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ១៤ | – ខេត្តក្រចេះ<br>– ខេត្តកំពង់ធំ<br>– ខេត្តកំពង់ចាម<br>– ខេត្តព្រៃវែង<br>– ខេត្តស្វាយរៀង<br>– ខេត្តកណ្តាល<br>– ខេត្តសៀមរាប<br>– ខេត្តពោធិ៍សាត់<br>– ខេត្តប៉ៃលិន<br>– ខេត្តព្រះសីហនុ(សវនកម្មសាកល្បង)<br>– ខេត្តកោះកុង(សវនកម្មសាកល្បង)<br>– ខេត្តកំពង់ស្ពឺ(សវនកម្មសាកល្បង)<br>– ខេត្តព្រះវិហារ (TeamMate)<br>– ខេត្តតាកែវ (TeamMate) |
| ៦ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុងស្រុកនិងឃុំសង្កាត់ | ១៥ | – ឃុំ-សង្កាត់ចំនួន ៥ នៃខេត្តកំពង់ចាម<br>– ឃុំ-សង្កាត់ចំនួន ៥ នៃខេត្តកណ្តាល<br>– ឃុំ-សង្កាត់ចំនួន ៥ នៃខេត្តសៀមរាប |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៥ | – គម្រោងឧបត្ថម្ភស្បៀងបន្ទាន់លេខ 0302-CAM(SF) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– គម្រោងស្តារឡើងវិញផ្លូវជនបទលេខ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | 2670-CAM(SF) របស់ក្រសួងអភិវឌ្ឍន៍ជនបទ<br>– គម្រោងគ្រប់គ្រងជំងឺឆ្លងក្នុងតំបន់ដំណាក់កាលទី២លេខ0231-CAM(SF) របស់ក្រសួងសុខាភិបាល<br>– គម្រោងស្តារឡើងវិញជាបន្ទាន់ការខូចខាតដោយទឹកជំនន់លេខ Loan 2852-CAM (SF) និង Grant 0285-CAM (SF) របស់ក្រសួងសាធារណការ និងដឹកជញ្ជូន<br>– គម្រោងអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងធនធានទឹកលេខ 2673-CAM(SF) របស់ក្រសួងធនធានទឹក និងឧតុនិយម |
| ៨ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០៦ | – រោងចក្រកាត់ដេរ E Garment. Co Ltd<br>– រោងចក្រកាត់ដេរChu Hsing Garment Co Ltd<br>– រោងចក្រកាត់ដេរ Kin Tai Garment Co Ltd<br>– កិច្ចសន្យាសម្បទានដំណាំដំឡូងមី ក្រុមហ៊ុន CJ Cambodia Ltd<br>– កិច្ចសន្យាសម្បទាន ក្រុមហ៊ុន Viet Nam Kampuchea Trading & Industry Co. Ltd.<br>– កិច្ចសន្យាសម្បទានដំណាំកសិ-ឧស្សាហកម្មក្រុមហ៊ុន Coviphama Co. LTD |
| **ឆ្នាំ២០១៥** | | **៥៥** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ១០ | – ក្រសួងអប់រំ យុវជន និងកីឡា<br>– ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>– ក្រសួងសុខាភិបាល<br>– ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | យុវនីតិសម្បទា<br>– ក្រសួងសាធារណការ និងដឹកជញ្ជូន<br>– ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>– ក្រសួងបរិស្ថាន<br>– ក្រសួងធម្មការ និងសាសនា<br>– ក្រសួងអភិវឌ្ឍន៍ជនបទ<br>– រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារនិងអាជ្ញាធរ | ០៣ | – អាជ្ញាធរអប្សរា<br>– អាជ្ញាធរអគ្គិសនីកម្ពុជា<br>– អគ្គិសនីកម្ពុជា |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៨ | – មន្ទីរពេទ្យខ្មែរ - សូវៀត<br>– មន្ទីរពេទ្យកុមារជាតិ<br>– វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម<br>– ក្រុមហ៊ុន ហ្វ្រីនត្រេដ<br>– បញ្ញត្តិករទូរគមនាគមន៍<br>– សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>– សាលាជាតិកសិកម្មកំពង់ចាម<br>– មន្ទីរពេទ្យអង្គឌួង |
| ៥ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ១១ | – ខេត្តរតនគិរី<br>– ខេត្តស្ទឹងត្រែង<br>– ខេត្តមណ្ឌលគិរី<br>– ខេត្តកំពត<br>– ខេត្តកែប<br>– ខេត្តបាត់ដំបង<br>– ខេត្តសៀមរាប<br>– ខេត្តឧត្តរមានជ័យ<br>– ខេត្តបន្ទាយមានជ័យ<br>– ខេត្តត្បូងឃ្មុំ<br>– ខេត្តព្រៃវែង |
| ៦ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុង ស្រុក និងឃុំ សង្កាត់ | ២០ | – ក្រុង ស្រុក ឃុំ សង្កាត់ នៃខេត្តមណ្ឌលគិរី<br>– ក្រុង ស្រុក ឃុំ សង្កាត់ នៃខេត្តកំពត<br>– បណ្ដា ខណ្ឌ សង្កាត់នៃរាជធានីភ្នំពេញ<br>– ក្រុង ស្រុក ឃុំ សង្កាត់ នៃខេត្តបន្ទាយ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | មានជ័យ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០១ | – គម្រោង Second Rural Water Supply and Sanitation Sector Project Grant No.0156-CAM ( SF ) នៅក្រសួងអភិវឌ្ឍន៍ជនបទ |
| ៨ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០១ | – កិច្ចសន្យាស្តីពីការវិនិយោគអាជីវកម្មលើថ្មអារ របស់ក្រុមហ៊ុន Sela Meas Co.,LTD នៅខេត្ត បន្ទាយមានជ័យ |
| **ឆ្នាំ២០១៦** | | **៦៣** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ១០ | – ក្រសួងអប់រំ យុវជន និងកីឡា<br>– ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>– ក្រសួងបរិស្ថាន<br>– ក្រសួងទេសចរណ៍<br>– ក្រសួងពាណិជ្ជកម្ម<br>– ក្រសួងរ៉ែ និងថាមពល<br>– ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>– ក្រសួងកិច្ចការនារី<br>– ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>– ក្រសួងផែនការ |
| ៣ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ០២ | – ធនាគារអភិវឌ្ឍន៍ជនបទ<br>– អាជ្ញាធរអគ្គិសនីកម្ពុជា |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៩ | – ភ្នាក់ងារកម្ពុជានាវាចរកាំសាប<br>– រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប<br>– កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>– វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កសិកម្ម<br>– សាកលវិទ្យាល័យភូមិន្ទកសិកម្ម<br>– សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | – ប្រៃសណីយ៍កម្ពុជា<br>– មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា<br>– បេឡាជាតិរបបសន្តិសុខសង្គម |
| ៥ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ១៦ | – ខេត្តកំពង់ចាម<br>– ខេត្តកំពង់ធំ<br>– ខេត្តក្រចេះ<br>– ខេត្តព្រះសីហនុ<br>– ខេត្តកោះកុង<br>– ខេត្តកណ្តាល<br>– ខេត្តស្វាយរៀង<br>– រាជធានីភ្នំពេញ<br>– ខេត្តកំពង់ឆ្នាំង<br>– ខេត្តបាត់ដំបង<br>– ខេត្តពោធិ៍សាត់<br>– ខេត្តប៉ៃលិន<br>– ខេត្តកែប<br>– ខេត្តកំពង់ស្ពឺ<br>– ខេត្តតាកែវ<br>– ខេត្តព្រះវិហារ |
| ៦ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុង ស្រុក និងឃុំ-សង្កាត់ | ១៨ | – បណ្តាក្រុង ស្រុក ឃុំ សង្កាត់ សរុបចំនួន៥ នៃខេត្តកំពង់ចាម<br>– បណ្តាក្រុង ឃុំ សង្កាត់ ចំនួន៥ នៃខេត្តកណ្តាល<br>– ខណ្ឌ សង្កាត់សរុបចំនួន៨ នៃរាជធានីភ្នំពេញ |
| ៧ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០១ | គម្រោង Third Education Sector Development Program Loan No.2888-CAM (SF) នៅក្រសួងអប់រំ យុវជន និងកីឡា |
| ៨ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០៦ | – រោងចក្រកាត់ដេរ CAN SPORT SHOES Co.,LTD.<br>– រោងចក្រកាត់ដេរ SKY NICE INTERNA- TIONAL CO.,LTD នៅស្រុកអង្គស្នួល ខេត្តកណ្តាល<br>– កិច្ចសន្យា ស្តីពីការវិនិយោគទុនលើ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | ដំណាំកសិកម្ម និងកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុនតេនាវិសាលអភិវឌ្ឍន៍ នៅខេត្តពោធិ៍សាត់<br>– កិច្ចសន្យា ស្តីពីការវិនិយោគកិនថ្ម រវាងក្រសួងរ៉ែ និងថាមពល ជាមួយ ក្រុមហ៊ុន HNI Group PLC នៅ ខេត្តសៀមរាប<br>– កិច្ចសន្យាសម្បទាន ស្តីពីការវិនិយោគទុនលើដំណាំកសិកម្ម និងកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន សូស៊ីយេតេ អាគ្រីកូល ដីឡាំងដូនស៊ីន នៅខេត្តកំពង់ចាម<br>– កិច្ចសន្យា ស្តីពីការវិនិយោគទុនលើដំណាំកសិ-ឧស្សាហកម្ម ចិញ្ចឹមសត្វ និងបង្កើតរោងចក្រកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន វើលដ៏ទ្រីស្តារអ៊ិនជើធេនមេន នៅខេត្តកំពត |
| **ឆ្នាំ២០១៧** | | **៧២** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ | ០១ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ១២ | -ក្រសួងសុខាភិបាល (FA)<br>-ក្រសួងព័ត៌មាន(FA)<br>-ក្រសួងសាធារណការនិងដឹកជញ្ជូន (FA)<br>-ក្រសួងអភិវឌ្ឍន៍ជនបទ(FA)<br>-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(FA)<br>-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (FA)<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (FA) |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -ក្រសួងធនធានទឹក និងឧតុនិយម(FA)<br>-ក្រសួងអប់រំ យុវជន និងកីឡា(FA)<br>-ក្រសួងមុខងារសាធារណៈ<br>-ក្រសួងធម្មការ និងសាសនា<br>-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ០៤ | -អាជ្ញាធរអគ្គិសនីកម្ពុជា<br>-អាជ្ញាធរអប្សរា<br>-ធនាគារជាតិនៃកម្ពុជា<br>-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ |
| ៤ | សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ | ១៣ | -ក្រុមហ៊ុនហ្វ្រីនត្រេដ<br>-អគ្គិសនីកម្ពុជា<br>-រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>-មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត<br>-មន្ទីរពេទ្យកុមារជាតិ<br>-សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>-គ្រឹះស្ថានអង្គរ<br>-សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>-វិទ្យាស្ថានជាតិសុខភាពសាធារណៈ<br>-គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ<br>-បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ<br>-មន្ទីរពេទ្យកាល់ម៉ែត្រ<br>-វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ២០ | -ខេត្តមណ្ឌលគិរី<br>-ខេត្តសៀមរាប<br>-ខេត្តបាត់ដំបង<br>-ខេត្តព្រៃវែង<br>-ខេត្តស្វាយរៀង<br>-ខេត្តកំពង់ធំ(FA)<br>-ខេត្តកោះកុង(FA)<br>-ខេត្តព្រះសីហនុ<br>-ខេត្តកំពត<br>-ខេត្តកំពង់ចាម<br>-ខេត្តស្ទឹងត្រែង<br>-ខេត្តរតនគិរី |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -ខេត្តកណ្តាល<br>-ខេត្តឧត្តរមានជ័យ<br>-ខេត្តបន្ទាយមានជ័យ<br>-ខេត្តត្បូងឃ្មុំ<br>-ខេត្តកែប<br>-ខេត្តកំពង់ស្ពឺ<br>-ខេត្តតាកែវ<br>-ខេត្តព្រះវិហារ |
| ៦ | ចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុង ស្រុក ខណ្ឌ ឃុំ-សង្កាត់ | ១៩ | -ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៥ នៃខេត្តព្រៃវែង<br>-ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៥នៃខេត្តមណ្ឌលគិរី<br>-ក្រុង ស្រុក ឃុំ សង្កាត់ចំនួន៤ នៅខេត្តកែប<br>-ក្រុង ស្រុក ឃុំ សង្កាត់ចំនួន៥ នៃខេត្តកំពង់ស្ពឺ |
| ៧ | កិច្ចសន្យាសម្បទាន(វិនិយោគ) | ០៣ | -កិច្ចសន្យាវិនិយោគការអភិវឌ្ឍវិស័យកសិកម្មរបស់ក្រុមហ៊ុន អឹមឌីអេស អាហ័រណេ នីហ័រណេ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់<br>-កិច្ចព្រមព្រៀងស្តីពីការវិនិយោគសាងសង់កំពង់ផែទេសចរណ៍ របស់ក្រុមហ៊ុនស៊ូជីង ផត អ៊ីនវេសមេន ខូអិលធីឌី នៅតំបន់ចុងឃ្នៀស សង្កាត់ចុងឃ្នៀស ក្រុងខេត្តសៀមរាប<br>-កិច្ចសន្យាវិនិយោគការអភិវឌ្ឍវិស័យកសិកម្មរបស់ក្រុមហ៊ុនMaster International Cooperation Co., Ltd នៅខេត្តកំពង់ស្ពឺ |
| **ឆ្នាំ២០១៨** | | **៦៨** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ១០ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (FA)<br>-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(FA) |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -ក្រសួងបរិស្ថាន(FA)<br>-ក្រសួងសុខាភិបាល(FA)<br>-ក្រសួងទេសចរណ៍(FA)<br>-ក្រសួងពាណិជ្ជកម្ម(FA)<br>-ក្រសួងព័ត៌មាន(FA)<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(FA)<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(FA)<br>-ក្រសួងយុត្តិធម៌ |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ០១ | -អាជ្ញាធរអគ្គិសនី |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ០៣ | -គ្រឹះស្ថានអង្គរ<br>-វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា<br>-ទូរគមនាគមន៍កម្ពុជា |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ១៦ | -ខេត្តមណ្ឌលគិរី<br>-ខេត្តសៀមរាប<br>-ខេត្តបាត់ដំបង<br>-ខេត្តស្វាយរៀង<br>-ខេត្តកំពត<br>-ខេត្តពោធិ៍សាត់<br>-ខេត្តរតនគិរី<br>-ខេត្តកណ្តាល<br>-ខេត្តកំពង់ស្ពឺ<br>-ខេត្តតាកែវ<br>-ខេត្តកែប<br>-ខេត្តបន្ទាយមានជ័យ<br>-ខេត្តត្បូងឃ្មុំ<br>-ខេត្តព្រះវិហារ<br>-ខេត្តប៉ៃលិន<br>-ខេត្តកំពង់ធំ |
| ៦ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុងស្រុក ឃុំ-សង្កាត់ | ៣០ | -ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៦ នៃខេត្តកណ្តាល<br>-ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៦ នៃខេត្តកំពង់ស្ពឺ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
| --- | --- | --- | --- |
| | | | -ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៦ នៃខេត្តសៀមរាប<br>-ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៦ នៃខេត្តរតនគិរី<br>--ក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៦ នៅខេត្តត្បូងឃ្មុំ |
| ៧ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០៣ | -កិច្ចព្រមព្រៀងស្តីពីការវិនិយោគកសាងកំពង់ផែទេសចរណ៍របស់ក្រុមហ៊ុន Sea Pag Investment Co., LTD នៅខេត្តសៀមរាប<br>-កិច្ចសន្យាស្តីពីការវិនិយោគដាំដំណាំកៅស៊ូ និងអាកាស្យា រវាងក្រុមហ៊ុនសល សុភា ពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តស្ទឹងត្រែង<br>-កិច្ចសន្យាស្តីពីការវិនិយោគដាំដំណាំកៅស៊ូរវាងក្រុមហ៊ុន ដុង ណាយ អភិវឌ្ឍន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តក្រចេះ |
| ៨ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០៤ | -ការត្រៀមលក្ខណៈអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាពនៅក្រសួងផែនការ<br>-ការគ្រប់គ្រងការបំភ្លឺសាធារណៈនៅខេត្តបាត់ដំបង<br>-សាលាជាតិកសិកម្មព្រែកលៀប<br>-ការគ្រប់គ្រងគុណភាពផ្សារនៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តព្រះសីហនុ |
| **ឆ្នាំ២០១៩** | | **<u>៧៨</u>** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន | ១៤ | -រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (FA)<br>-ក្រសួងអប់រំ យុវជន និងកីឡា(FA) |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(FA)<br>-ក្រសួងបរិស្ថាន(FA)<br>-ក្រសួងសាធារណការនិងដឹកជញ្ជូន (FA)<br>-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(FA)<br>-ក្រសួងផែនការ(FA)<br>-ក្រសួងពាណិជ្ជកម្ម(FA)<br>-ក្រសួងអភិវឌ្ឍន៍ជនបទ(FA)<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(FA)<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (FA)<br>-ក្រសួងធនធានទឹក និងឧតុនិយម(FA)<br>-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ(FA)<br>-ក្រសួងធម្មការ និងសាសនា |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ៦ | -អាជ្ញាធរអប្សរា<br>-អាជ្ញាធរព្រះវិហារ<br>-ធនាគារជាតិនៃកម្ពុជា<br>-អាជ្ញាធរអគ្គិសនី<br>-ធនាគារអភិវឌ្ឍន៍ជនបទ<br>-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ១៥ | -កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>-រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>-អគ្គិសនីកម្ពុជា<br>-មន្ទីរពេទ្យកុមារជាតិ<br>-មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត<br>-គ្រឹះស្ថានអង្គរ<br>-មន្ទីរពេទ្យព្រះកុសមៈ<br>-បេឡាជាតិរបបសន្តិសុខសង្គម<br>-សាលាភូមិន្ទកសិកម្មចំការដូង<br>-សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>-បេឡាសោធនសម្រាប់អតីតយុទ្ធជន<br>-ក្រុមហ៊ុនហ្គ្រីនត្រេដ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>-វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម<br>-កំពង់ផែស្វយ័តក្រុងភ្នំពេញ |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ២១ | -ខេត្តមណ្ឌលគិរី<br>-ខេត្តសៀមរាប<br>-ខេត្តបាត់ដំបង<br>-ខេត្តស្វាយរៀង<br>-ខេត្តពោធិ៍សាត់<br>-ខេត្តរតនគិរី<br>-ខេត្តកណ្តាល<br>-ខេត្តកំពង់ស្ពឺ<br>-ខេត្តតាកែវ<br>-ខេត្តក្រចេះ<br>-ខេត្តស្ទឹងត្រែង<br>-ខេត្តកោះកុង<br>-ខេត្តព្រះសីហនុ<br>-ខេត្តកំពង់ចាម<br>-ខេត្តព្រៃវែង<br>-ខេត្តបន្ទាយមានជ័យ<br>-ខេត្តកំពង់ឆ្នាំង<br>-រាជធានីភ្នំពេញ<br>-ខេត្តកែប<br>-ខេត្តត្បូងឃ្មុំ<br>-ខេត្តឧត្តរមានជ័យ<br>-ខេត្តព្រះវិហារ<br>-ខេត្តប៉ៃលិន<br>-ខេត្តកំពង់ធំ |
| ៦ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុង ស្រុក ឃុំ សង្កាត់ | ១៣ | -១ក្រុង នៃខេត្តបាត់ដំបង<br>-៤ស្រុក នៃខេត្តបាត់ដំបង<br>-៨ខណ្ឌ នៃរាជធានីភ្នំពេញ |
| ៧ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ៤ | -កិច្ចសន្យាស្តីពីការវិនិយោគមជ្ឈមណ្ឌលពាណិជ្ជកម្មផ្សារអូឡាំពិករវាងសាលារាជធានីភ្នំពេញជាមួយក្រុមហ៊ុន ថៃ ប៊ុនរ៉ុង<br>-កិច្ចសន្យាស្តីពីការវិនិយោគដីសម្បទាន |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | សេដ្ឋកិច្ចរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន First Bio-Tech Agricultural នៅខេត្តកំពត<br>-កិច្ចសន្យាស្តីពីការវិនិយោគដាំកៅស៊ូ ប្រភេទឈើផ្សេងៗទៀត និងបង្កើតរោងចក្រកែច្នៃរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន សំរោង រ៉ាប់ប៊ើរ អ៊ិនដាសស្រ្ទី ភីធីអ៊ីអុិលជីឌីនៅខេត្តឧត្តរមានជ័យ<br>-កិច្ចសន្យាស្តីពីគម្រោងដីសម្បទានសម្រាប់វិនិយោគអភិវឌ្ឍន៍លើវិស័យកសិកម្មរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយក្រុមហ៊ុន៩៩ អភិវឌ្ឍន៍កសិកម្ម ខូអិលធីឌី នៅខេត្តកំពង់ស្ពឺ |
| ៨ | សវនកម្មលើកិច្ចប្រតិបត្តិការ | ៤ | -ការគ្រប់គ្រងផ្លូវលំជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ<br>-ប្រសិទ្ធភាពនៃការគ្រប់គ្រងច្រកចេញចូលតែមួយនៃខេត្តព្រះសីហនុ<br>-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅខេត្តឧត្តរមានជ័យ<br>-មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា |
| **ឆ្នាំ២០២០** | | **៧៧** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួងស្ថាប័ន | ១៩ | -ក្រសួងអប់រំ យុវជន និងកីឡា(FA)<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (FA)<br>-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(FA)<br>-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (FA)<br>-ក្រសួងសាធារណការនិងដឹកជញ្ជូន (FA)<br>-ក្រសួងសុខាភិបាល (FA)<br>-ក្រសួងអភិវឌ្ឍន៍ជនបទ(FA) |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -ក្រសួងពាណិជ្ជកម្ម(FA)<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(FA)<br>-ក្រសួងព័ត៌មាន(FA)<br>-ក្រសួងផែនការ(FA)<br>-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(FA)<br>-ក្រសួងធនធានទឹក និងឧតុនិយម(FA)<br>-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម(FA)<br>-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(FA)<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(FA)<br>-ក្រសួងមុខងារសាធារណៈ<br>-ក្រសួងយុត្តិធម៌<br>-ក្រសួងកិច្ចការនារី |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារ និងអាជ្ញាធរ | ៤ | -អាជ្ញាធរព្រះវិហារ<br>-ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម<br>-អាជ្ញាធរអគ្គិសនី<br>-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ១៣ | -កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>-ក្រុមហ៊ុនភ្លើនត្រេដ<br>-កំពង់ផែស្វយ័តភ្នំពេញ<br>-បេឡាជាតិរបបសន្តិសុខសង្គម<br>-វិទ្យាសាស្ត្រសុខាភិបាលខេមរភូមិន្ទ<br>-មន្ទីរពេទ្យព្រះអង្គឌួង<br>-សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>-វិទ្យាស្ថានជាតិសុខភាពសាធារណៈ<br>-គ្រឹះស្ថានអង្គរ<br>-មន្ទីរពេទ្យកុមារជាតិ<br>-និយ័តករទូរគមនាគមន៍កម្ពុជា<br>-ប្រៃសណីយ៍កម្ពុជា<br>-វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ២៤ | -ខេត្តសៀមរាប<br>-ខេត្តបាត់ដំបង<br>-ខេត្តស្វាយរៀង<br>-ខេត្តពោធិ៍សាត់<br>-ខេត្តរតនគិរី<br>-ខេត្តកណ្ដាល<br>-ខេត្តកំពង់ស្ពឺ<br>-ខេត្តតាកែវ<br>-ខេត្តក្រចេះ<br>-ខេត្តស្ទឹងត្រែង<br>-ខេត្តកោះកុង<br>-ខេត្តព្រះសីហនុ<br>-ខេត្តកំពង់ចាម<br>-ខេត្តឧត្តរមានជ័យ<br>-ខេត្តបន្ទាយមានជ័យ<br>-ខេត្តព្រៃវែង<br>-ខេត្តកំពត<br>-ខេត្តត្បូងឃ្មុំ<br>-ខេត្តកែប<br>-ខេត្តមណ្ឌលគិរី<br>-ខេត្តព្រះវិហារ<br>-ខេត្តប៉ៃលិន<br>-ខេត្តកំពង់ធំ<br>-ខេត្តកំពង់ឆ្នាំង |
| ៦ | គម្រោងរបស់ដៃគូអភិវឌ្ឍន៍ | ០៦ | -ស្រុកចំនួន២នៅ ខេត្តឧត្តរមានជ័យ<br>-ស្រុកចំនួន៤ នៅខេត្តបន្ទាយមានជ័យ |
| ៧ | កិច្ចសន្យាសម្បទាន (វិនិយោគ) | ០៤ | -កិច្ចសន្យាស្ដីពីការវិនិយោគដាំដំណាំកៅស៊ូ និងដំឡូងមី រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន ប៊ី អិន អេ (ខេម) ខប នៅខេត្តកំពង់ធំ<br>-កិច្ចសន្យាស្ដីពីការវិនិយោគដាំកៅស៊ូ និងដំណាំឧស្សាហកម្មផ្សេងៗទៀត រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុនខេនលីមីធីត នៅខេត្ត |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | សៀមរាប<br>-កិច្ចសន្យាស្តីពីគម្រោងដីសម្បទានសម្រាប់វិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិឧស្សាហកម្ម រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាមួយក្រុមហ៊ុនGREAT FIELD (CAMBODIA) INTERNATIONAL LIMITED នៅខេត្តកំពង់ស្ពឺ<br>-កិច្ចសន្យាស្តីពីការវិនិយោគទុនលើការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មចិញ្ចឹមសត្វនិងបង្កើតរោងចក្រកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយក្រុមហ៊ុន កុល វាសនា អ៊ិនវេស ឌូ អិលធីឌី នៅខេត្តកំពង់ធំ។ |
| ៨ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០៥ | -ការគ្រប់គ្រងវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍<br>-ការរៀបចំ និងការអនុវត្តថវិការបស់រដ្ឋបាលខេត្តកំពត<br>-ការគ្រប់គ្រង និងការប្រមូលចំណូលសួយសារអ៊ែ នៅខេត្តព្រៃវែង<br>-ការគ្រប់គ្រងចុះបញ្ជីដីធ្លីនៅខេត្តមណ្ឌលគិរី<br>-ការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ខេត្តកំពង់ឆ្នាំង |
| **ឆ្នាំ២០២១** | | **៧៥** | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ | ០១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ |
| ២ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រសួងស្ថាប័ន | ១៣ | -ក្រសួងអប់រំ យុវជន និងកីឡា(FA)<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (FA)<br>-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(FA)<br>-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (FA)<br>-ក្រសួងទេសចរណ៍ (FA) |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពរងសវនកម្ម |
|---|---|---|---|
| | | | -ក្រសួងព័ត៌មាន(FA)<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(FA)<br>-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(FA)<br>-ក្រសួងធនធានទឹក និងឧតុនិយម(FA)<br>-ក្រសួងរ៉ែ និងថាមពល(FA)<br>-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(FA)<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(FA)<br>-ក្រសួងផែនការ |
| ៣ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ធនាគារនិងអាជ្ញាធរ | ០៤ | -អាជ្ញាធរអគ្គិសនី<br>-អាជ្ញាធរអប្សរា<br>-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| ៤ | គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ | ១២ | -កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>-អគ្គិសនីកម្ពុជា<br>-សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>-មន្ទីរពេទ្យកុមារជាតិ<br>-សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>-រាជបណ្ឌិត្យសភាកម្ពុជា<br>-វិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា<br>-មន្ទីរពេទ្យអង្គឌួង<br>-ទូរគមនាគមន៍កម្ពុជា<br>-ប្រៃសណីយ៍កម្ពុជា<br>-មន្ទីរពិសោធន៍សំណង់ និងសាធារណការ<br>-គ្រឹះស្ថានអង្គរ |
| ៥ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់រាជធានី ខេត្ត | ២៥ | -ខេត្តសៀមរាប<br>-ខេត្តបាត់ដំបង<br>-ខេត្តស្វាយរៀង<br>-ខេត្តពោធិ៍សាត់ |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពទទួលសវនកម្ម |
|---|---|---|---|
| | | | -ខេត្តរតនគិរី<br>-ខេត្តកណ្តាល<br>-ខេត្តកំពង់ស្ពឺ<br>-ខេត្តតាកែវ<br>-ខេត្តក្រចេះ<br>-ខេត្តស្ទឹងត្រែង<br>-ខេត្តកោះកុង<br>-ខេត្តព្រះសីហនុ<br>-ខេត្តកំពង់ចាម<br>-ខេត្តឧត្តរមានជ័យ<br>-ខេត្តបន្ទាយមានជ័យ<br>-ខេត្តព្រៃវែង<br>-ខេត្តកំពត<br>-ខេត្តត្បូងឃ្មុំ<br>-ខេត្តកែប<br>-ខេត្តមណ្ឌលគិរី<br>-ខេត្តព្រះវិហារ<br>-ខេត្តប៉ៃលិន<br>-ខេត្តកំពង់ធំ<br>-ខេត្តកំពង់ឆ្នាំង<br>-រាជធានីភ្នំពេញ |
| ៦ | ចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការរបស់ក្រុង ស្រុក ខណ្ឌ និង ឃុំ-សង្កាត់ | ១០ | ខណ្ឌចំនួន១០ នៃរាជធានីភ្នំពេញ |
| ៧ | សវនកម្មលើកិច្ចប្រតិបត្តិការ | ០៥ | -ការគ្រប់គ្រងចំណូលពីវិស័យអាកាសចររបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>-ការគ្រប់គ្រងកាកសំណល់រឹងនិងរាវនៅខេត្តព្រះសីហនុ<br>-ការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ<br>- ការគ្រប់គ្រងលើកិច្ចប្រតិបត្តិការការងាររបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដី ខេត្តកំពង់ឆ្នាំង |

| ល.រ | មុខសញ្ញាសវនកម្ម | ចំនួន | ឈ្មោះអង្គភាពទទួលសវនកម្ម |
|---|---|---|---|
| | | | -សវនកម្មលើកិច្ចប្រតិបត្តិការលើការគ្រប់គ្រងសេវាទេសចរណ៍នៅខេត្តមណ្ឌលគីរី |
| ៨ | សវនកម្មតាមសំណើ | ០៥ | សវនកម្មលើអង្គការក្រៅរដ្ឋាភិបាលបរទេស សម្រាប់ការិយបរិច្ឆេទ២០១៧-២០២០ |

## III- បញ្ហាប្រឈម

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ទន្ទឹមនឹងជោគជ័យ អាជ្ញាធរសវនកម្មជាតិក៏បានជួបប្រទះបញ្ហាប្រឈមមួយចំនួនមានជាអាទិ៍៖

- ការជំរុញការអនុវត្តតាមអនុសាសន៍សវនកម្ម ទោះបីល្អប្រសើរច្រើនយ៉ាងណាក៏ដោយ ក៏នៅពុំទាន់មានភាពពេញលេញនៅឡើយ។
- សមត្ថភាពជំនាញរបស់សវនកលើប្រភេទសវនកម្មនីមួយៗនៅមានកម្រិត។
- កង្វះខាតប្រព័ន្ធបច្ចេកវិទ្យាបម្រើឱ្យការងារសវនកម្ម។
- ការរៀបចំរបាយការណ៍មានភាពយឺតយ៉ាវ គួបផ្សំនឹងការឆ្លើយតបយឺតយ៉ាវរបស់អង្គភាពរងសវនកម្មផងដែរ។
- ភាពស្មុកស្មាញនៃសវនកម្មលើកិច្ចប្រតិបត្តិការ និងការរីកចម្រើនយ៉ាងលឿននៃបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល។
- ការអនុវត្តនូវប្រព័ន្ធ FMIS និងការធ្វើសវនកម្មលើការអនុវត្តប្រព័ន្ធ FMIS។
- ការរីករាលដាលនៃជំងឺកូវីដ-១៩។

# ផ្នែកទី៣
# ទិសដៅការងារបន្ត

ផ្អែកតាមលទ្ធផលដែលសម្រេចបានក្នុងរយៈពេល១០ឆ្នាំ (២០១២-២០២១) អាជ្ញាធរសវនកម្មជាតិ ក៏នៅមានតម្រូវចាំបាច់ ដើម្បីបន្តពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួន ព្រមទាំងធ្វើឱ្យកាន់តែប្រសើរឡើងនូវកម្រិតគុណភាពសវនកម្ម។ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ទាំងនេះ អាជ្ញាធរសវនកម្មជាតិបន្តដាក់ចេញនូវទិសដៅការងារសម្រាប់រយៈពេល៥ឆ្នាំ (២០២២-២០២៦) ដូចខាងក្រោម៖

**ក- លើកកម្ពស់គុណភាព និងភាពជឿទុកចិត្តបាននៃសវនកម្មឱ្យស្របតាមស្តង់ដារវិជ្ជាជីវៈ**

- បន្តពង្រឹងការងារសវនកម្មនៅតាមក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តោតលើប្រភេទសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ លើភាពអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ លើកិច្ចប្រតិបត្តិការ និងលើសវនកម្មជាក់លាក់មួយចំនួនទៀត។
- បន្តអនុវត្តសវនកម្មលើកិច្ចប្រតិបត្តិការនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- បន្តអនុវត្តសវនកម្មពីចម្ងាយលើក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បន្តជំរុញការអនុវត្តសវនកម្មឱ្យស្របតាមស្តង់ដារ សៀវភៅណែនាំ គោលការណ៍ណែនាំ ដែលបានដាក់ឱ្យអនុវត្ត។
- បន្តធ្វើបច្ចុប្បន្នភាពជាប្រចាំលើស្តង់ដារ សៀវភៅណែនាំ គោលការណ៍ណែនាំ ស្តីពីសវនកម្ម ដើម្បីឱ្យស្របតាមការវិវឌ្ឍនៃវិស័យសវនកម្មសាធារណៈ។

**ខ- ការកសាងសមត្ថភាព ការអភិវឌ្ឍស្ថាប័ន និងនវានុវត្តន៍**

- ពិនិត្យមើលក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។
- ពិនិត្យកែសម្រួលរចនាសម្ព័ន្ធរបស់អាជ្ញាធរសវនកម្មជាតិឱ្យស្របនឹងស្ថានភាព និងតម្រូវការជាក់ស្តែង។
- ពិនិត្យឡើងវិញនូវក្រមសីលធម៌ ដើម្បីធ្វើបច្ចុប្បន្នភាពឱ្យស្របនឹងគោលការណ៍អន្តរជាតិ និងបរិបថកម្ពុជា។
- បន្តផ្សព្វផ្សាយក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិដល់មន្ត្រីសវនកម្ម។
- ដាក់ឱ្យដំណើរការវិទ្យាស្ថានជាតិសវនកម្ម។
- ពិនិត្យរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ។
- បន្តរៀបចំផែនការសកម្មភាពស្តីពីការតម្រូវការ និងការកសាងសមត្ថភាពមន្ត្រី។
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាដល់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិ និងភាគីពាក់ព័ន្ធ។
- បន្តបណ្តុះបណ្តាលស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ សវនកម្មលើកិច្ចប្រតិបត្តិការ សវនកម្មលើបរិស្ថាន សវនកម្មបច្ចេកវិទ្យាព័ត៌មាន។
- បន្តបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីជំនាញសវនកម្ម និងជំនាញពាក់ព័ន្ធផ្សេងៗ។

## គ- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រ

- កែលម្អប្រព័ន្ធទិន្នន័យពេញលេញអំពីអង្គភាពរងសវនកម្ម។
- កែលម្អប្រព័ន្ធតាមដានលទ្ធផលសវនកម្ម/ការអនុវត្តអនុសាសន៍សវនកម្ម។
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យា និងឌីជីថល។
- បន្តចូលរួមអនុវត្តការងារតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- គ្រប់គ្រង និងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋលម្អិតប្រចាំឆ្នាំ។
- រៀបចំរបាយការណ៍បូកសរុបទូទាត់ថវិកាប្រចាំឆ្នាំ។

## ឃ- ទំនាក់ទំនងជាមួយដៃគូ និងភាគីពាក់ព័ន្ធ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីសវនកម្ម និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាដល់មន្ត្រីនៃអង្គភាពរងសវនកម្ម និងភាគីពាក់ព័ន្ធ។
- បន្តទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងស្ថាប័នថ្នាក់ក្រោមជាតិ។
- បន្តទំនាក់ទំនងជាមួយស្ថាប័ននីតិប្បញ្ញត្តិ ពិសេសជាមួយគណៈកម្មការជំនាញ។
- បន្តទំនាក់ទំនងជាមួយក្រុមការងាររបស់INTOSAI ស្តីពីសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា និងតម្លៃ និងអត្ថប្រយោជន៍នៃស្ថាប័នសវនកម្មកំពូល។
- បន្តសកម្មភាពអនុវត្តការងារក្នុងនាមជាសមាជិកASOSAI និង ASEANSAI។
- បន្តចូលរួមអនុវត្តសកម្មភាពរបស់គណៈកម្មាធិការចែករំលែកចំណេះដឹង គណៈកម្មាធិការបណ្តុះបណ្តាល គណៈកម្មាធិការផែនការយុទ្ធសាស្ត្រ គណៈកម្មាធិការវិធាន និងនីតិវិធីរបស់ ASEANSAI ។
- បន្តចូលរួមកម្មវិធីសវនកម្ម និងគម្រោងកិច្ចសហប្រតិបត្តិការនានារបស់ IDI។
- ចូលរួមសិក្ខាសាលាក្របខណ្ឌគណៈកម្មាការ ទី២នៃរដ្ឋសភា កម្ពុជា ឡាវ និងវៀតណាម ។
- បន្តទំនាក់ទំនងជាមួយស្ថាប័នសវនកម្មកំពូលចិន ឥណ្ឌូនេស៊ី និងបណ្តាប្រទេសនានា។
- បន្តចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា។
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា។

# ផ្នែកទី៤
# សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល១០ឆ្នាំ (២០១២-២០២១) កន្លងមកនេះ អាជ្ញាធរសវនកម្មជាតិបានចូលរួមអនុវត្ត ដោយជោគជ័យនូវ **"កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ និងទី៦នៃរដ្ឋសភា"** និង **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤"** និងរួមគ្នាបំពេញតួនាទីជាឯកសារក្របខណ្ឌគោលនយោបាយដែលគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំ **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣"** តាមរយៈការដាក់ចេញនូវ "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ២០១៧-២០២១"របស់អាជ្ញាធរសវនកម្មជាតិសម្រាប់ជាទិសដៅកសាងសមត្ថភាពស្ថាប័ន និងអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកអនុវត្តកំណែទម្រង់ស៊ីជម្រៅ និងមុតស្រួចលើគ្រប់វិស័យ ពិសេសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ តាមរយៈនេះ អាជ្ញាធរសវនកម្មជាតិសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅរួមមាន៖

១- ការអភិវឌ្ឍស្ថាប័ន ការលើកកម្ពស់គុណភាពសវនកម្ម និងការកសាងសមត្ថភាពមន្ត្រីរាជការនៅអាជ្ញាធរសវនកម្មជាតិ ដោយចាត់ទុកថា សមិទ្ធផលនេះជាកិច្ចការចម្បងដែលត្រូវពុះពារធ្វើឱ្យខានតែបាន ដើម្បីឈានទៅសម្រេចតួនាទី បេសកកម្ម ភារកិច្ចផ្សេងៗទៀតរបស់អាជ្ញាធរសវនកម្មជាតិ តាមរយៈការអភិវឌ្ឍរចនាសម្ព័ន្ធទាំងរឹង ទាំងទន់ រៀបចំឱ្យមានក្រមសីលធម៌មន្ត្រីសវនកម្ម ឯកសារជាគោលការណ៍ ជានីតិវិធី ជាសេចក្តីណែនាំ ជាផែនការជួយគាំទ្រដល់ការងារសវនកម្មដូចបានរៀបរាប់ក្នុងរបាយការណ៍រួចហើយ។ មិនត្រឹមតែជាឯកសារ ជាទ្រឹស្តី ជាការណែនាំប៉ុណ្ណោះទេ ថែមទាំងបានចាត់តាំងអនុវត្តជាក់ស្តែង ប្រជុំបូកសរុបដកពិសោធន៍ ព្រមទាំងបណ្តុះបណ្តាលជាសិក្ខាសាលាក្នុងប្រទេស និងក្រៅប្រទេសផងដែរ។

២- ការសម្រេចបាននូវសមិទ្ធផលនៃការងារសវនកម្មយ៉ាងច្រើនសន្ធឹកសន្ធាប់ ទោះបីមានជួបប្រទះនឹងការលំបាកឧបសគ្គនានា ព្រមទាំងការផ្ទុះឡើងនៃជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏អាជ្ញាធរសវនកម្មជាតិនៅតែចុះធ្វើសវនកម្មគ្រប់ទីកន្លែង មិនថាទីជិត ឬទីឆ្ងាយ កន្លែងងាយស្រួល ឬកន្លែងលំបាកនោះឡើយ ដោយបានផលិតចេញនូវរបាយការណ៍សវនកម្មចំនួន **៦៥៤** របាយការណ៍ ដោយគិតទាំងរបាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងតាមឆ្នាំនីមួយៗ បានគ្រប់ជ្រុងជ្រោយ ត្រឹមត្រូវ និងទាន់ពេលវេលា និងតែងតែបានទទួលនូវការសរសើរពីស្ថាប័ននីតិប្បញ្ញត្តិផងដែរ។ បើបូកបញ្ចូលទាំងការបោះផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចំនួន ១៣ លេខ ផងនោះ របាយការណ៍ដែលអាជ្ញាធរសវនកម្មជាតិបានផលិតចេញរយៈពេល ១០ ឆ្នាំ នេះមានចំនួន **៦៦៧** របាយការណ៍។ សូមបញ្ជាក់ជូនជ្រាបថា ការផ្សព្វផ្សាយរបាយការណ៍លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើសចំនួនអាណត្តិ គឺមកពីក្នុងអាណត្តិមុននៅសេសសល់របាយការណ៍ចំនួន ៤ របាយការណ៍នៅមិនទាន់បានធ្វើគឺ ឆ្នាំ២០០៨ ២០០៩ ២០១០ ២០១១ ហេតុនេះត្រូវខិតខំធ្វើ ទាំងរបាយការណ៍នៅសល់ និងរបាយការណ៍ឆ្នាំ២០១២ ដើម្បីផ្សព្វផ្សាយបានទាន់ពេលវេលាតាមច្បាប់កំណត់។ សមិទ្ធផលទាំងនេះ បង្ហាញឱ្យឃើញនូវឆន្ទៈមោះមុតរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅក្រោមឱវាទ ដោយបានអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាលបានយ៉ាងល្អប្រសើរ ធ្វើឱ្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់ក្រសួង ស្ថាប័នគ្រប់គ្រងមានអនុលោមភាពកាន់តែពេញលេញ ធានាបាននូវតម្លាភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃកិច្ចដំណើរការការងារ ក៏ដូចជាកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

៣- សមិទ្ធផលដែលកើតចេញពីកិច្ចសហប្រតិបត្តិការអន្តរជាតិដែលរួមមានជាដៃគូអភិវឌ្ឍន៍ ទ្វេភាគី ត្រីភាគី ពហុភាគីជាមួយស្ថាប័នសវនកម្មកំពូលនៅអាស៊ីអាគ្នេយ៍ នៅតំបន់អាស៊ី នៅតំបន់អឺរ៉ុបបានរួមចំណែកដល់ភាពជោគជ័យរបស់អាជ្ញាធរសវនកម្មជាតិ។ ជាមួយនេះផងដែរ ការបំពេញតួនាទីជាប្រធាន ASEANSAI រយៈពេលពីរឆ្នាំ សម្រាប់អាណត្តិ ២០១៦ ដល់២០១៧ បាននាំមកនូវកិត្យានុភាពជូនព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាអាជ្ញាធរសវនកម្មជាតិ ដែលកំពុងដើរតួនាទីយ៉ាងសកម្ម ដោយស្មើសិទ្ធិ និងស្មើភាពក្នុងកិច្ចការសវនកម្មថ្នាក់តំបន់ និងនៅកម្រិតអន្តរជាតិ។

៤- កិច្ចសហការល្អយ៉ាងជិតស្និទ្ធិក្របកដោយការទទួលខុសត្រូវជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរួមចំណែកមួយយ៉ាងសំខាន់មិនអាចខ្វះបាននូវភាពជោគជ័យរបស់អាជ្ញាធរសវនកម្មជាតិ។

ក្នុងការបំពេញមុខងាររបស់ខ្លួនប្រកបដោយសមត្ថភាពវិជ្ជាជីវៈអាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងបានធ្វើរបាយការណ៍លទ្ធផលសវនកម្មជូនដល់រដ្ឋសភា និងព្រឹទ្ធសភា រាជរដ្ឋាភិបាល ដើម្បីមានមូលដ្ឋានក្នុងការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំនីមួយៗ ជំរុញអនុវត្តអនុសាសន៍សវនកម្មដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ជាពិសេសចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៅលើមាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចគ្រប់វិស័យ ពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការជំរុញការអភិវឌ្ឍដោយឈរលើមូលដ្ឋាននៃសមិទ្ធផលជាច្រើនសម្រេចបានកន្លងមក ទាំងខាងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ពិសេសគឺ **សន្តិភាព និងស្ថិរភាពនយោបាយ** ដ៏រឹងមាំជាប់មិនដាច់ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ព្រមជាមួយនេះដែរ ក៏បានជួយកែតម្រូវ និងផ្តល់អនុសាសន៍សម្រាប់អង្គភាពរងសវនកម្មផងដែរ សំដៅធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានភាពប្រសើរឡើងថែមទៀត។

សមិទ្ធផលទាំងអស់នេះ មិនអាចកាត់ផ្តាច់បានពីការឧបត្ថម្ភគាំទ្រយ៉ាងធំធេង និងថ្លៃថ្លាពីសំណាក់រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល ដែលជានិច្ចកាលជួយគាំទ្រលើកទឹកចិត្តឱ្យអាជ្ញាធរសវនកម្មជាតិបំពេញការងារដោយភាពស្វាហាប់ និងជឿទុកចិត្ត។ ទន្ទឹមនឹងនេះផងដែរ ការជួយគាំទ្រ និងផ្តល់កិច្ចសហការល្អជិតស្និទ្ធពីអង្គភាពរងសវនកម្ម ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានដល់សមិទ្ធផលរបស់អាជ្ញាធរសវនកម្មជាតិ។

ដោយមានការខិតខំរបស់អាជ្ញាធរសវនកម្មជាតិ និងការជួយគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ ដូចជា GIZ, ADB, SNAO, និងដៃគូនានាទៀត សៀវភៅណែនាំសវនកម្ម ឯកសារគតិយុត្ត និងឯកសារសវនកម្មជាច្រើនទៀត ត្រូវបានបង្កើតឡើងដើម្បីជាមូលដ្ឋានសម្រាប់សវនករអនុវត្តការងារសវនកម្មរបស់ខ្លួនឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាស្តង់ដារសវនកម្មអន្តរជាតិនានា ដែលជាគោលក្នុងការរៀបចំសៀវភៅណែនាំសវនកម្មទាំងនេះ។

ជាមួយនឹងការរីកចម្រើនលើការងារសវនកម្មដែលជាកិច្ចការមូលដ្ឋាន អាជ្ញាធរសវនកម្មជាតិបានទទួលជោគជ័យលើការងារទំនាក់ទំនងអន្តរជាតិក្នុងក្របខណ្ឌជាច្រើន ដូចជា INTOSAI ASOSAI ASEANSAI IDI និងក្របខណ្ឌត្រីភាគីរវាងស្ថាប័នសវនកម្មកំពូលកម្ពុជា វៀតណាម និងឡាវ។ ពាក់ព័ន្ធនឹងការទំនាក់ទំនងអន្តរជាតិ ក្នុងឆ្នាំ២០១៥ អាជ្ញាធរសវនកម្មជាតិ ក្រោមការដឹកនាំរបស់ **លោកជំទាវ សោម គីមសួគ៌ អគ្គសវនករ** ត្រូវបានទទួលការតែងតាំងជាប្រធាន ASEANSAI សម្រាប់អាណត្តិ ២០១៦-២០១៧ ដោយប្រកបដោយជោគជ័យ។ ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិបានចុះ និងបន្តអនុវត្ត

អនុស្សរណៈនៃការយោគយល់គ្នាជាមួយបណ្តាស្ថាប័នសវនកម្មកំពូលនានា ក្នុងគោលបំណងអភិវឌ្ឍន៍ស្ថាប័នឱ្យបានសមស្របតាមកម្រិតស្តង់ដារអន្តរជាតិ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ទន្ទឹមនឹងជោគជ័យ អាជ្ញាធរសវនកម្មជាតិក៏បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា សមត្ថភាពជំនាញរបស់សវនករនៅមានកម្រិត ការរៀបចំរបាយការណ៍មួយចំនួនមានភាពយឺតយ៉ាវគួបផ្សំនឹងការឆ្លើយតបយឺតយ៉ាវរបស់អង្គភាពរងសវនកម្ម បច្ចេកវិទ្យាព័ត៌មានមានការខ្វះខាត និងការរីករាលដាលនៃជំងឺកូវីដ-១៩។ ទោះបីជួបការលំបាក និងបញ្ហាប្រឈមយ៉ាងណាក៏ដោយក៏មិនអាចធ្វើឱ្យរាំងស្ទះនូវដំណើរការសវនកម្ម ឬដំណើរការទៅមុខរបស់អាជ្ញាធរសវនកម្មជាតិបានឡើយ ដោយអាជ្ញាធរសវនកម្មជាតិបានកំណត់ច្បាស់នូវមូលហេតុនៃបញ្ហា និងទិសដៅដែលត្រូវដើរ។

ដើម្បីបន្តការអភិវឌ្ឍន៍ស្ថាប័ន និងសមត្ថភាពជំនាញរបស់មន្ត្រី អាជ្ញាធរសវនកម្មជាតិ បានចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ (២០២២-២០២៦) សម្រាប់អនុវត្តការងារសវនកម្មប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្ត ដើម្បីរួមចំណែកជួយរាជរដ្ឋាភិបាល ជាពិសេសការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ព្រមជាមួយនឹងយុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី។

ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក ផ្អែកលើសក្តានុពលដ៏ធំធេងរបស់អាជ្ញាធរសវនកម្មជាតិ ធន្ទះដ៏មោះមុត និងទេពកោសល្យវិជ្ជាជីវៈរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទ ព្រមទាំងផ្អែកលើសមត្ថភាព ចំណេះដឹង ចំណេះធ្វើ បទពិសោធន៍ជាច្រើនឆ្នាំកន្លងមក គួបផ្សំនិងការដាក់ចេញនូវផែនការយុទ្ធសាស្ត្រត្រឹមត្រូវ ព្រមទាំងចេះជ្រើសរើស និងអនុវត្តនូវគោលការណ៍ណែនាំដែលមានស្រាប់ និងពង្រីកបន្ថែមថ្មីទៅតាមដំណាក់កាលនីមួយៗ រួមជាមួយកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា អាចជំនះបាននូវបញ្ហាប្រឈម និងឧបសគ្គនានា នាំឆ្ពោះទៅរកការសម្រេចបាននូវជោគជ័យ និងសមិទ្ធផលធំធេង ជាងនេះទៀត សំដៅចូលរួមចំណែកដើម្បីជានាសុខសន្តិភាព ស្ថិរភាព និងចីរភាពនៃកំណើនសេដ្ឋកិច្ច លើកកម្ពស់សុខុមាលភាពជូនប្រជាជន បន្តកសាងគ្រឹះដ៏រឹងមាំសម្រាប់ឈានទៅសម្រេចចក្ខុវិស័យជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ នាំកម្ពុជាឆ្ពោះទៅរកភាពសំបូរណ៍រុងរឿង។